# មិត្ត ល្អ

វត្តនិគ្រោធវ័ន គល់ទទឹង

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ គួង-សុវណ្ណ

ពុទ្ធសករាជ ២៥៥៥

-សៀវភៅ **មិត្តល្អ**

-រៀបរៀងដោយ ភិក្ខុ **សុវណ្ណជោតោ តួច-សុវណ្ណ**

**ជាអាចារ្យបង្រៀនព្រះវិន័យ ឧត្តមសិក្សានៃវត្តនិគ្រោធវ័ន**

**-អ្នកជួយពិនិត្យ**

- ភិក្ខុ **សុមេធបណ្ឌិតោ ស៊ិន ផល្លា**
- ភិក្ខុ **វិនយធរោ តុន ប៊ុនសាយ**
- ភិក្ខុ **មេត្តចិត្តោ ឆន ម៉ៅមេត្តា**
- ភិក្ខុ **ធម្មកាមោ ជឹម ផល្លី**
- ភិក្ខុ **មង្គលបាលិតោ នី សុភក្រ្ត**

**-វេយ្យាវច្ចករ ក្នុងការងារធម្មទាន**

-ឧបាសិកា **តាំង អៀងស៊ុយ** -ឧបាសិកា **តាំង ទ្រៀន**

-ឧបាសិកា **ឆ្នួន មុំ** -ឧបាសិកា **ឆ្នូ ចរិយា**

-ឧបាសិកា **អ៊ឹង រតនា** -ឧបាសិកា **ហាវ សាវ៉ុធ**

-ឧបាសក **អ៊ុំ ប៊ុនជា** ។

-ទីកន្លែងធ្វើ **វត្តនិគ្រោធវ័ន** រាជធានីភ្នំពេញ

-ធម្មទានដោយ **ពុទ្ធបរិស័ទទូទៅ**

-ពុទ្ធសករាជ **២៥៥៥**

# អារម្ភកថា

សត្វលោកគ្រប់គ្នាទាំងអស់ តែងប្រាថ្នានូវសេចក្ដីចម្រើន និងប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្ដីសុខក្នុងលោកខាងមុខផង និងប្រយោជន៍ដ៏ខ្ពង់ខ្ពស់ទៀតផង ។ ដើម្បីឱ្យបានសម្រេចនូវប្រយោជន៍ទាំងអស់នេះ ត្រូវអាស្រ័យសម្បទា (ការដល់ព្រម) មាន "**ឧដ្ឋានសម្បទា** (ដល់ព្រមដោយសេចក្ដីព្យាយាមខំធ្វើការងារ) ១ **អារក្ខសម្បទា** (ដល់ព្រមដោយការថែទាំភោគៈ ដោយការរក្សា គ្រប់គ្រង) ១ **កល្យាណមិត្តតា** (ភាពជាអ្នកមានមិត្តល្អ) ១ **សមជីវិតា** (មានការចិញ្ចឹមជីវិតស្មើ) ១ **សទ្ធាសម្បទា** (បរិបូរណ៍ដោយសទ្ធា) ១ **សីលសម្បទា** (បរិបូរណ៍ដោយសីល) ១ **ចាគសម្បទា** (បរិបូរណ៍ដោយចាគៈ) ១ **បញ្ញាសម្បទា** (បរិបូរណ៍ដោយបញ្ញា) ១" ដូច្នេះ និងបដិបត្តិក្នុងគោលធម៌ដទៃទៀត ដើម្បីបានប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ទាំងអស់នេះ ជាសំខាន់គឺ ភាពជាអ្នកមានមិត្តល្អ ។ ព្រោះហេតុនោះ ការបានពួកមិត្តដ៏មាំមួន រមែងជួយទល់ទ្រ មិនឱ្យសាបសូន្យចាកសិរី និងគុណធម៌ ដូចព្រះអង្គទ្រង់ត្រាស់ថា "**បណ្ឌិត បានពួកមិត្តដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យចាកសិរី ដូចជាកំពូល (ជហ្វា) ដែលបង្កង់នាំ**

**ទៅនូវភារៈយ៉ាងនេះឯង”** ដូច្នេះ ។

សត្វលោកគ្រប់គ្នា តែងត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាម ព្រោះជាអ្នកដើរផ្លូវឆ្ងាយគឺវដ្ដៈ ព្រោះមានអវិជ្ជាជារនាំង មានតណ្ហាជាគ្រឿងចង អន្ទោលទៅ ត្រាច់រង្គាត់ទៅក្នុងសង្សារ អស់កាលជាយូរអង្វែង ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវធម៌ទាំង ៤ យ៉ាង គឺ ចាក់ធ្លុះនូវអរិយសីល អរិយសមាធិ អរិយបញ្ញា អរិយ-វិមុត្តិ ។ ដើម្បីចាក់ធ្លុះនូវគុណធម៌ទាំងអស់នេះ ត្រូវតែប្រព្រឹត្តព្រហ្មចរិយធម៌ ប្រតិបត្តិនូវធម៌សមគួរដល់ធម៌ បានដល់ បដិបត្តិបុព្វភាគបដិបទា ដែលជាធម៌សមគួរដល់លោកុត្តរធម៌ ៩ ប្រការ ។

ដើម្បីញ៉ាំងការបដិបត្តិឱ្យបានបរិបូរណ៍ ត្រូវដើរទៅតាមមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ប្រការ ដែលឈ្មោះថាជាផ្លូវត្រង់ទៅកាន់ទិសគឺព្រះនិព្វាន ឈ្មោះថាជាទិសគ្មានភ័យ ត្រូវមានយោ-និសោមនសិការៈ ឬភាពជាអ្នកមានមិត្តល្អ ដូចដែលព្រះមានព្រះភាគត្រាស់ថា **“គុណជាតឯណា គឺការមានមិត្តល្អ មានសម្លាញ់ល្អ និងការមានគ្នើល្អ គុណជាតនេះឯង ចាត់ជាព្រហ្មចរិយធម៌ទាំងមូល, ព្រហ្មចរិយធម៌នេះឯង ប្រាកដដល់ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ**

**មានភ្លើល្អ នឹងចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨”** ដូច្នេះ ។

ក្នុងសៀវភៅនេះ ខ្ញុំព្រះករុណា បានដកស្រង់យកព្រះសូត្រដែលទាក់ទងនឹង**មិត្តល្អ** ព្រោះហេតុនោះ ទើបខ្ញុំដាក់ឈ្មោះថា **មិត្តល្អ** ដើម្បីពុទ្ធបរិស័ទសិក្សា នឹងមានសេចក្ដីពេញចិត្តក្នុងការចូលទៅសេពគប់កល្យាណមិត្ត នឹងធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ឈ្មោះថាជាផ្លូវត្រង់ទៅកាន់ទិសគឺព្រះនិព្វាន ឈ្មោះថាជាទិសគ្មានភ័យ ។

ដោយមហាកុសលចេតនាណា ដែលខ្ញុំមានសេចក្ដីជ្រះថ្លាក្នុងព្រះសទ្ធម្ម រចនានេះ សូមព្រះសទ្ធម្មតម្កល់នៅអស់កាលយូរ សូមបុញ្ញកុសលនេះ បានជាបច្ច័យនៃបញ្ញាត្រាស់ដឹងនូវសច្ចធម៌ ដល់ព្រមដោយបដិសម្ភិទា ក្នុងកាលជាអនាគត ។ ម្យ៉ាងទៀត សូមពួកញាតិមួយអន្លើដោយសព្វសត្វទាំងអស់អនុមោទនា ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ ។

ថ្ងៃ ១១ កើត ខែផល្គុន ព.ស.២៥៥៥

**ភិក្ខុ សុវណ្ណជោតោ ភួង~សុវណ្ណ**

## ធុរៈច្បាប់ចំពោះសម្ពាហុលភិក្ខុ

តត្រាយមាទិ ភវតិ ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។

គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រីយ៍ ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ (ម្នាលភិក្ខុ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

បដិសន្ថារវុត្យស្ស អាចារកុសលោ សិយា
តតោ បាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សតិ ។

ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

-អារម្ភកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ក

**I. មិត្តកថា**

១-ពាក្យថា មិត្ត ... ... ... ... ... ... ... ... ... ... ... ... ... ១

២-សេចក្ដីចម្រើនព្រោះការសេពគប់មិត្តល្អ .... ... ... .... ២

៣-មិត្តល្អជាព្រហ្មចរិយធម៌ទាំងមូល ... ... ... ... ... ... ១១

៤-ការសេពគប់មិត្ត ... ... ... ... ... ... ... ... ... ... ... ... ១៤

៥-ការមិនសេពគប់ពាលនិងការសេពគប់បណ្ឌិត ... ... ... ១៨

៥.១-បុគ្គលពាលនិងលក្ខណៈរបស់បុគ្គលពាល ... ... ១៨

៥.២-បុគ្គលជាបណ្ឌិតនិងលក្ខណៈរបស់បណ្ឌិត ... ... ២១

៦-បុគ្គលដែលគួរសេពគប់និងមិនគួរសេពគប់ ... ... ... ... ២៥

-រឿង កូនសេក ... ... ... ... ... ... ... ... ... ... ... ២៦

-រឿង ដំរីឈ្មោះមហិឡាមុខៈ ... ... ... ... ... ... ... ៣៤

-រឿង សេះឈ្មោះបណ្ឌវៈ ... ... ... ... ... ... ... ... ៣៨

៧-ប្រភេទនៃមិត្តសម្លាញ់ ... ... ... ... ... ... ... ... ... .... ៤០

៧.១-ហេតុ ៦ ប្រការតែងបំផ្លាញបុរសឱ្យវិនាស ... ... ៤០

**មាតិកា** **ទំព័រ**

៧.២-មិត្តប្លួម ៤ ពួក ... ... ... ... ... ... ... ... ... ..... ៤២

៧.៣-មិត្តមានសន្តានល្អ ... ... ... ... ... ... ... ... .... ៤៦

៨-តួនាទីរបស់មិត្ត ... ... ... ... ... ... ... ... ... ... ... ... ៤៩

៩-មិត្តាមិត្តជាតក ... ... ... ... ... ... ... ... ... ... ... .... ៥១

១០-ព្រះគាថាក្នុងកោសម្ពិកន្ធកៈ ... ... ... ... ... ... ..... ៥៧

១១-បឋមសខាសូត្រ ... ... ... ... ... ... ... ... ... ... .... ៦១

១២-ទុតិយសខាសូត្រ ... ... ... ... ... ... ... ... ... ... ៦៣

១៣-ទុតិយសេក្ខសូត្រ ... ... ... ... ... ... ... ... ... .. ៦៥

១៤-ការមានមិត្តល្អជាព្រហ្មចរិយធម៌ទាំងមូល ... ... .... ៧៤

១៥-បឋមសុរិយូបមសូត្រ ... ... ... ... ... ... ... ... ... .. ៧៧

១៦-មេឃិយសូត្រ ... ... ... ... ... ... ... ... ... ... ... ... ៧៨

**II. អត្ថបទកំណាព្យ**

១-មិត្តប្លួម ៤ ប្រការ ... ... ... ... ... ... ... ... ... ... .... ១៣១

២-មិត្តមានសន្តានល្អ ៤ ប្រកា ... ... ... ... ... ... ... .... ១៣២

៣-ការគប់មិត្ត (ជាដើម) ... ... ... ... ... ... ... ..... ១៣២

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**សូមនមស្ការ ចំពោះព្រះមានព្រះភាគ**
**ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។**

# មិ ត្ត ល្អ

## I. មិត្តកថា

### ១~ពាក្យថា មិត្ត

*ពាក្យថា មិត្ត នេះ មានពន្យល់ក្នុងវចនានុក្រមខ្មែរ ថា :*

*មិត្ត មិត បា. ឬ សំ. (ន.) អ្នកដែលរាប់អានគ្នាជិតដិត, មនុស្សដែលស្រឡាញ់រាប់រកគ្នាយ៉ាងជិតស្និទ្ធ, សម្លាញ់; មិត្តមានពីរយ៉ាងគឺ កល្យាណមិត្ត មិត្តដែលមានអធ្យាស្រ័យល្អ; បាបមិត្ត មិត្តដែលមានអធ្យាស្រ័យអាក្រក់ : បុគ្គលគួរកុំសេពគប់បាបមិត្ត គួរសេពគប់តែកល្យាណមិត្ត, ប៉ុន្តែគួរប្រយ័ត្នកុំធ្វើបាបមិត្ត ឲ្យក្លាយជាសត្រូវឡើយ (ព.ពុ.) ។*

*ក្នុងគម្ពីរអភិធានវណ្ណនា ទំព័រ៤៥១ ពន្យល់ថា ៖*

**មិត្ត** *(មិទ ស្នេហេ + ត) សម្លាញ់, មិត្ត, សហាយ,*

អ្នកដែលរាប់អានគ្នា, **មិទតិ សនេហតីតិ មិត្តោ** : អ្នកស្រឡាញ់គ្នា ឈ្មោះថា មិត្ត ។ **មិនោតិ បក្ខិបតីតិ មិត្តោ** : អ្នកគប់រកគ្នា ឈ្មោះថា មិត្ត ។ **អត្តនិ បរំ មិទតិ ពន្ធតីតិ មិត្តោ** : អ្នកចងនូវជនដទៃរបស់ខ្លួន ឈ្មោះថា មិត្ត ។

## ២-សេចក្តីចម្រើនព្រោះការសេពគប់មិត្តល្អ

ព្រះមានព្រះភាគអង្គណា ជាព្រះសយម្ភូ ឥតមានគ្រូអាចារ្យ បានត្រាស់ដឹងសច្ចធម៌ដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនផង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងសច្ចៈនោះផង ទ្រង់ដល់នូវភាវៈស្ទាត់ក្នុងពលៈទាំងឡាយផង ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា ពុទ្ធ ។

ទ្រង់ព្រះនាមថា **ព្រះពុទ្ធ** ព្រោះហេតុព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះហេតុព្រះអង្គញុំាងពួកសត្វឲ្យត្រាស់ដឹង ។ **ព្រះពុទ្ធ**អង្គនោះ ទ្រង់ជាព្រះសាស្តា ទ្រង់ប្រៀនប្រដៅសព្វសត្វដោយប្រយោជន៍ក្នុងបច្ចុប្បន្នប្រយោជន៍ក្នុងលោកខាងមុខ និងប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះនិព្វាន តាមសមគួរ ។ ទ្រង់ត្រាស់ចំពោះការសេពគប់មិត្តថា៖

“បុគ្គលគប់រកបុគ្គលណាៗ ជាសប្បុរស ឬជាអសប្បុ-

រស មានសីល ឬមិនមានសីល រមែងលុះនូវអំណាចនៃបុគ្គលនោះៗ ឯង ។ បុគ្គលធ្វើបុគ្គលបែបណាឲ្យជាមិត្តផង សេពគប់បុគ្គលបែបណាផង បុគ្គលនោះ រមែងប្រាកដដូចបុគ្គលនោះដែរ ព្រោះថាការនៅរួមគ្នា រមែងប្រាកដដូច្នោះ ។ អាចារ្យដែលកូនសិស្សពាល់ត្រូវហើយ រមែងប្រឡាក់កូនសិស្សដែលមិនទាន់ប្រឡាក់ កាលកូនសិស្សពាល់ត្រូវអាចារ្យដទៃ រមែងប្រឡាក់ដូចព្រួញលាបថ្នាំពិស ប្រឡាក់បំពង់ព្រួញដូច្នោះ អ្នកប្រាជ្ញមិនត្រូវមានសម្លាញ់ដ៏លាមក ព្រោះខ្លាចអំពីការប្រឡាក់ ។ ជនណាខ្ចប់ត្រីស្អុយដោយស្បូវភ្លាំង ស្បូវភ្លាំងរបស់ជននោះ ទៅជាមានក្លិនស្អុយផ្សាយទៅ យ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាល ក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ ស្លឹកឈើរបស់ជននោះ ទៅជាមានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បណ្ឌិតកាលដឹងច្បាស់នូវភាពនៃខ្លួនដែលប្រែប្រួលបាន ដូចជាកញ្ចប់នៃស្លឹកឈើ មិនត្រូវសេពគប់អសប្បុរសទេ ត្រូវសេពគប់តែពួកសប្បុរស ។ ព្រោះថាពួកអសប្បុរសតែងនាំទៅកាន់នរក ពួកសប្បុរសតែងឲ្យដល់សុគតិ” ។

ក្នុងសម្បទា ៨ យ៉ាង ទ្រង់ត្រាស់នូវគោលធម៌សម្រាប់ប្រតិបត្តិដើម្បីសេចក្តីចម្រើន និងប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងលោកខាងមុខផង ក្នុងនោះក៏មាននូវភាពជាអ្នកមានមិត្តល្អ (កល្យាណមិត្តតា) មួយផងដែរ ។

"បុគ្គលអ្នកប្រឹងប្រែង មានវិធានការ មិនបណ្តែតបណ្តោយក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យដែលខ្លួនរកបានមក មានសទ្ធា បរិបូរណ៍ដោយសីល ឈ្លាសក្នុងសំដី លះបោលសេចក្តីកំណាញ់ ជម្រះនូវផ្លូវសម្រាប់ទៅកាន់លោកខាងមុខ ឲ្យមានសួស្តីជានិច្ច ធម៌ទាំង ៨ យ៉ាងនេះ នាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរ ដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមថាសច្ចៈ ទ្រង់សម្តែងហើយដល់កុលបុត្តអ្នកមានសទ្ធានៅគ្រប់គ្រងផ្ទះ, មួយទៀត ការបរិច្ចាគ និងបុណ្យដ៏សេសនេះ តែងចម្រើនដល់ពួកគ្រហស្ថ ដើម្បីសេចក្តីចម្រើន និងប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងលោកខាងមុខផង យ៉ាងនេះ ។

*ភាពជាអ្នកមានមិត្តល្អ នេះ ពិតជានាំឲ្យបានសម្រេចនូវប្រយោជន៍ទាំង ៣ ព្រោះបានការណែនាំល្អ ។ បើយើងសេព*

គប់ខុស គឺសេពគប់បាបមិត្ត បានការណែនាំខុស រមែង សាបសូន្យចាកប្រយោជន៍ ។ ដូចជាមហាធនសេដ្ឋីបុត្រ ៖

ក្នុងអដ្ឋកថាធម្មបទ មានសម្ដែងថា មហាធនសេដ្ឋីបុត្រ មានទ្រព្យ ១៦០ កោដិ តែមិនបានការណែនាំល្អពីមាតាបិតា សេពគប់មិត្តមិនល្អ មិនប្រព្រឹត្តព្រហ្មចរិយធម៌ ។ មាតាបិតារបស់គេគិតថា "ក្នុងត្រកូលរបស់យើង មានគំនរភោគៈជាច្រើន, យើងនឹងប្រគល់គំនរភោគៈនោះទុកក្នុងដៃបុត្ររបស់យើង ធ្វើឲ្យប្រើប្រាស់យ៉ាងសប្បាយ, កិច្ចដោយការងារយ៉ាងដទៃមិនត្រូវមាន", ដូច្នេះហើយទើបឲ្យគេសិក្សាសិល្បៈត្រឹមតែការរាំ ច្រៀង និងប្រគំតែម្យ៉ាង ។ ខាងក្រោយមកមាតាបិតាក៏បានស្លាប់ទៅ ។ បុត្រសេដ្ឋីនោះ សេពគប់ជាមួយមិត្តមិនល្អដែលជាបាបមិត្ត បានញ៉ាំងទ្រព្យសម្បត្តិ ១៦០ កោដិ នោះឲ្យសាបសូន្យហើយ គេនាំភរិយាទៅនៅអាស្រ័យជញ្ជាំងផ្ទះរបស់ជនដទៃ កាន់បំណែកអម្បែង ត្រាច់ទៅសូមទាន ។

គ្រានោះ ព្រះសាស្ដាទតព្រះនេត្រឃើញគេឈរទៀបទ្វាររោងឆាន់ ចាំទទួលភោជនដែលសល់អំពីភិក្ខុកំលោះ និងសាមណេរឲ្យ ក្នុងថ្ងៃមួយទើបទ្រង់ធ្វើការញញឹមព្រះឱស្ឋ ។

លំដាប់នោះ ព្រះអានន្ទត្ថេរ ទូលសួរដល់ហេតុដែលទ្រង់ញញឹម ចំពោះព្រះអង្គ ។ ព្រះសាស្ដាកាលនឹងត្រាស់ប្រាប់ហេតុដែលទ្រង់ញញឹម ទើបត្រាស់ថា "ម្នាលអានន្ទ អ្នកចូរមើលបុត្រសេដ្ឋីអ្នកមានទ្រព្យច្រើននេះ ញុំាងទ្រព្យ ១៦០ កោដិ ឲ្យអស់ទៅ នាំភរិយាត្រាច់សូមទាននៅក្នុងនគរនេះឯង; ក៏បើបុត្រសេដ្ឋីមិនញុំាងទ្រព្យឲ្យអស់ទៅទេ នឹងប្រកបការងារក្នុងបឋមវ័យ ក៏នឹងបានជាសេដ្ឋីកំពូល ក្នុងនគរនេះឯង ។ ក៏បើនឹងចេញបួស ក៏នឹងបានសម្រេចអរហត្ត, សូម្បីភរិយារបស់គេក៏នឹងតាំងនៅក្នុងអនាគាមិផល ។ បើមិនញុំាងទ្រព្យឲ្យអស់ទៅទេ នឹងប្រកបការងារក្នុងមជ្ឈិមវ័យ នឹងបានជាសេដ្ឋីទី២, ចេញបួសនឹងបានជាអនាគាមី, សូម្បីភរិយារបស់គេ ក៏នឹងតាំងនៅក្នុងសកទាគាមិផល ។ បើមិនញុំាងទ្រព្យឲ្យអស់ទៅទេ ប្រកបការងារក្នុងបច្ឆិមវ័យ នឹងបានជាសេដ្ឋីទី៣, សូម្បីចេញបួស ក៏នឹងបានជាសកទាគាមី, សូម្បីភរិយារបស់គេ ក៏នឹងតាំងនៅក្នុងសោតាបត្តិផល ។ តែឥឡូវនេះ បុត្រសេដ្ឋីនោះ សាបសូន្យហើយចាកភោគៈជារបស់គ្រហស្ថ ទាំងសាបសូន្យហើយចាកសាមញ្ញផល ។ ក៏ឯគ្រាសាបសូន្យហើយ ទើបដូចជាសត្វក្រៀលក្នុង

ភក់ស្ងួត ដូច្នោះ ។

នៅក្នុងមិត្តសូត្រ ព្រះមានព្រះភាគ ត្រាស់ថា ៖

សត្ថោ បសវតោ មិត្តំ មាតា មិត្តំ សកេ ឃរេ

សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ

សយំកតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ ។

បក្ខពួក ជាមិត្តរបស់អ្នកដើរផ្លូវ មាតា ជាមិត្តក្នុងផ្ទះរបស់ខ្លួន អ្នកដែលមានចិត្តប្រព្រឹត្តទៅស្មើគ្នា ជាមិត្តរបស់អ្នកដែលមានធុរៈកើតឡើងរឿយៗ បុណ្យទាំងឡាយដែលគេធ្វើហើយដោយខ្លួនឯង ជាមិត្តជាប់តាមទៅក្នុងភពខាងមុខ ។

ក្នុងព្រះអដ្ឋកថា សារត្ថប្បកាសិនី ពន្យល់ថា ៖

បទថា សត្ថោ បានដល់ អ្នកធ្វើដំណើររួមគ្នា ឬធ្វើដំណើរដោយស្មុង ឬថា អ្នកធ្វើដំណើរដោយរទេះ ។ បទថា មិត្តំ បានដល់ កាលរោគកើតឡើងហើយ បុគ្គលឈ្មោះថាជាមិត្ត ព្រោះនាំទៅដោយអង្រឹងស្នែង ឬដោយយានដទៃឲ្យដល់ទីដែលក្សេម ដោយការរួចផុតភ័យ ។ បទថា សកេ ឃរេ ក្នុងផ្ទះរបស់ខ្លួន សេចក្ដីថា កាលរោគបែបនោះកើតឡើង

ហើយ ក្នុងផ្ទះរបស់ខ្លួន ជនទាំងឡាយមានបុត្រនិងភរិយាជាដើម រមែងរង្កៀស តែមាតា រមែងសម្អាតសូម្បីនូវវត្ថុមិនស្អាតរបស់បុត្រ ហាក់បីដូចជាដុំចន្ទន៍ ព្រោះដូច្នោះ មាតានោះ ទើបឈ្មោះថា ទាំងជាមិត្ត ទាំងជាសម្លាញ់ ក្នុងផ្ទះរបស់ខ្លួន ។ បទថា អត្ថជាតស្ស ប្រែថា របស់បុគ្គលដែលមានធុរៈកើតឡើង អធិប្បាយថា បុគ្គលណា រមែងនាំកិច្ចនោះទៅធ្វើឲ្យសម្រេច បុគ្គលនោះឈ្មោះថា សម្លាញ់ ឈ្មោះថា មិត្ត ព្រោះសេចក្តី គឺញុំាងកិច្ចទាំងឡាយឲ្យសម្រេចរួមគ្នា ។ ប៉ុន្តែថា ជនទាំងឡាយដែលជាសម្លាញ់ក្នុងការផឹកទឹកស្រវឹង មានសុរាជាដើម មិនឈ្មោះថាជាមិត្តទេ ។ បទថា សម្បរាយិកំ បានដល់ ជាប្រយោជន៍ក្នុងភពខាងមុខ ។

*ការសេពគប់ខុស ដូចជាស្តេចអជាតសត្តុជាដើម បដិបត្តិខុសក្នុងបិតា (គឺសម្លាប់បិតា) ព្រោះតែសេពគប់ជាមួយភិក្ខុទេវទត្ត ដែលជាបាបមិត្ត ត្រូវសាបសូន្យចាកសាមញ្ញផល ។*

ក្នុងសាមញ្ញផលសូត្រ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ជីករំលើងគុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ

ព្រះរាជាអង្គនេះ មិនផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតា ដែលជាព្រះធម្មរាជ ប្រកបដោយធម៌ទេ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដែលប្រាសចាកធូលី ប្រាសចាកមន្ទិលនឹងកើតដល់ព្រះរាជាអង្គនោះ លើអាសនៈនេះមិនខានឡើយ" ដូច្នេះ ។

ព្រោះហេតុនោះ បុគ្គលគប្បីវៀរពួកបុគ្គលដែលមិនមែនជាមិត្តចេញ ហើយសេពគប់តែមិត្តល្អប៉ុណ្ណោះ ។

*ក្នុងមានោជជាតក ព្រះសាស្តាទ្រង់ត្រាស់នូវព្រះគាថានេះចំពោះភិក្ខុទាំងឡាយថា ៖*

និហីយតិ បុរិសោ និហីនសេវី
ន ច ហាយេថ កទាចិ តុល្យសេវី
សេដ្ឋមុបគមញ្ច ឧទេតិ ខិប្បំ
តស្មា អត្តនោ ឧត្តរិំ ភជេថ ។

"បុរសអ្នកគប់រកនូវជនថោកទាប រមែងសាបសូន្យ បុគ្គលគប់រកនូវជនស្មើៗគ្នា រមែងមិនសាបសូន្យ ក្នុងកាលណាឡើយ គប់រកនូវជនដែលប្រសើរជាង រមែងចម្រើនឆាប់រួសរាន់ ព្រោះហេតុនោះ បុគ្គលគួរតែគប់រកនូវបុគ្គលដែលប្រសើរជាងខ្លួន" ។

ក្នុងអដ្ឋកថាពន្យល់ថា បទថា **និហីយតិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ជម្មតាថា អ្នកសេពគប់ជនថោកទាប រមែងសាបសូន្យទៅ គឺវិនាសអស់ អធិប្បាយថា ដល់សេចក្ដីវិនាស ។ បទថា **តុល្យសេវី** សេចក្ដីថា អ្នកគប់រកជនស្មើៗគ្នាដោយខ្លួន ដោយគុណសេចក្ដីល្អទាំងឡាយ មានសីលជាដើម នឹងមិនសាបសូន្យឡើយ ។ តែគេនឹងមានសេចក្ដីចម្រើនតែម្យ៉ាង ។ បទថា **សេដ្ឋនុបគមំ** សេចក្ដីថា កាលចូលទៅរកអ្នកដែលខ្ពង់ខ្ពស់ជាងខ្លួន ដោយគុណសេចក្ដីល្អមានសីលជាដើមនោះឯង ។ បទថា **ឧទេតិ ខិប្បំ** សេចក្ដីថា នឹងចូលដល់គេដោយគុណសេចក្ដីល្អ មានសីលជាដើម ដោយឆាប់រហ័សនោះឯង ។

*ការបានពួកមិត្តដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត រមែងជួយទល់ទ្រ មិនឲ្យសាបសូន្យបាកសិរី ដូចជាក្នុងកុក្កុជាតក ព្រះពោធិសត្វ ពោលថា ៖*

បង្កង់ទាំងឡាយណាចំនួន ៣០ ខ្ទឹមស្មុទ្ធ ឥតមានស្រាយ ឋិតនៅតំរៀបគ្នាជុំវិញ (កំពូលនោះ) បង្កង់ទាំងឡាយនោះ ទល់ទ្រផង គាបដោយកម្លាំងផង ឋិតនៅស្មើភាគគ្នា ទើបមិនធ្លាក់

របួតអំពីខាងលើមក ។ បណ្ឌិត បានពួកមិត្តដ៏មាំមួន មាន សភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យចាកសិរី ដូចជាកំពូល (ជហ្វា) ដែលបង្កង់ នាំទៅនូវការៈយ៉ាងនេះឯង ។

ភាពនៃបុគ្គលដែលជានេយ្យបុគ្គល (បុគ្គលដឹងធម៌ដែល គួរនឹងណែនាំបាន) មិនអាចវៀរចាកកល្យាណមិត្តបានទេ កាល សាកសួរដោយឧទ្ទេស ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា សេពគប់រកចូលទៅអង្គុយជិតកល្យាណមិត្តទាំងឡាយ ទើប មានការត្រាស់ដឹងធម៌បានដោយលំដាប់ ។

ក្នុងព្រះសូត្រខ្លះ ព្រះមានព្រះភាគ ទ្រង់សម្តែងការ អាស្រ័យ គប់រកកល្យាណមិត្តទុកខាងដើម ហើយទ្រង់សម្តែង សេចក្តីព្យាយាមទុកកណ្តាល ហើយទើបត្រាស់ប្រាប់ព្រះ-អរហត្ត ក្នុងខាងក្រោយ ។

## ៣-មិត្តល្អជាព្រហ្មចរិយធម៌ទាំងមូល

ការប្រព្រឹត្តិព្រហ្មចរិយធម៌ ត្រូវអាស្រ័យកល្យាណមិត្ត ជាសំខាន់ មិនអាចវៀរចាកកល្យាណមិត្តបានទេ ព្រោះគុណ-ជាតឯណា គឺការមានមិត្តល្អនេះឯង ចាត់ជាព្រហ្មចរិយធម៌

ទាំងមូល ដូចដែលព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទ ថា "ម្នាលអានន្ទ គុណជាតឯណា គឺការមានមិត្តល្អ មានសម្លាញ់ល្អ និងការមានក្លើល្អ គុណជាតនេះឯង ចាត់ជាព្រហ្មចរិយធម៌ទាំងមូល ។ ម្នាលអានន្ទ ព្រហ្មចរិយធម៌នេះឯង ប្រាកដដល់ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានក្លើល្អ នឹងចម្រើននូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ នឹងធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ " ដូច្នេះ ។

តាមប្រក្រតី កល្យាណមិត្តនេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល សុតៈ ចាគ វិរិយ សតិ សមាធិ និងបញ្ញា, រមែងបបួលក្នុងវត្ថុដែលមានប្រយោជន៍តែម្យ៉ាង ។ ដូចព្រះមាន-ព្រះភាគ ត្រាស់ទុកថា "ភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ គួរគោរព គួរសរសើរ ឧស្សាហ៍ប្រៀនប្រដៅ អត់ធន់ចំពោះពាក្យសំដី ជាអ្នកនិយាយពាក្យជ្រាលជ្រៅ ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរ" ដូច្នេះ ។

ក្នុងសុត្តន្តបិដក លេខ១៥០ ទំព័រ២៤៩ ព្រះអង្គត្រាស់ពីអាហាររបស់វិជ្ជានិងវិមុត្តិ រមែងមាន ពេញបរិបូរណ៍ ចាប់ដើម

តាំងពីសប្បុរិសសំសេវៈ (ការសេពគប់សប្បុរស) ដែលជាកល្យាណមិត្តហ្នឹងឯង ។ ព្រះអង្គត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ សប្បុរិសសំសេវៈពេញបរិបូរណ៍ រមែងញុំាងសទ្ធម្មស្សវនៈឲ្យពេញបរិបូរណ៍ សទ្ធម្មស្សវនៈពេញបរិបូរណ៍ហើយ រមែងញុំាងសទ្ធាឲ្យពេញបរិបូរណ៍ សទ្ធាពេញបរិបូរណ៍ហើយ រមែងញុំាងយោនិសោមនសិការៈឲ្យពេញបរិបូរណ៍ យោនិសោមនសិការៈពេញបរិបូរណ៍ហើយ រមែងញុំាងសតិនិងសម្បជញ្ញៈឲ្យពេញបរិបូរណ៍ សតិនិងសម្បជញ្ញៈពេញបរិបូរណ៍ហើយ រមែងញុំាងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូរណ៍ ការសង្រួមឥន្ទ្រិយពេញបរិបូរណ៍ហើយ រមែងញុំាងសុចរិត ៣ ឲ្យពេញបរិបូរណ៍ សុចរិត ៣ ពេញបរិបូរណ៍ហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូរណ៍ សតិប្បដ្ឋាន ៤ ពេញបរិបូរណ៍ហើយ រមែងញុំាងពោជ្ឈង្គ ៧ ឲ្យពេញបរិបូរណ៍ ពោជ្ឈង្គ ៧ ពេញបរិបូរណ៍ហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញបរិបូរណ៍ ដោយប្រការដូច្នេះឯង ។ អាហាររបស់វិជ្ជានិងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូរណ៍យ៉ាងនេះ ។

# ៤-ការសេពគប់មិត្ត

ក្នុងការសេពគប់មិត្តនេះ សំខាន់ណាស់ ដូចបានបញ្ជាក់ខ្លះៗមកហើយ បើយើងយកបុគ្គលបែបណាជាមិត្តផង សេពគប់នូវមិត្តបែបណាផង យើងនោះឯងនឹងប្រាកដស្មើដោយមិត្តនោះៗ ព្រោះការនៅរួមនឹងក្លាយទៅជាបែបគ្នានោះពិត ។ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែង មានក្នុងសុត្តន្តបិដក លេខ ៥៣ ទំព័រ៩១ ថា ៖

កាលបើបុគ្គលមិនធ្វើបាបទេ តែទៅសេពគប់នឹងបុគ្គលធ្វើបាប បុគ្គលនោះត្រូវអ្នកផងរង្កៀស ព្រោះអំពើអាក្រក់ផង តំណិះដំនៀល រមែងចម្រើនឡើងដល់បុគ្គលនោះផង ។ បុគ្គលយកបុគ្គលបែបណាជាមិត្តផង សេពគប់នូវមិត្តបែបណាផង បុគ្គលនោះឯង នឹងប្រាកដស្មើដោយមិត្តនោះៗ ព្រោះការនៅរួមនឹងក្លាយទៅជាបែបគ្នានោះពិត ។ បុគ្គលបាប កាលបើបុគ្គលស្អាតដទៃមកសេពគប់ហើយ បុគ្គលបាប ត្រូវបុគ្គលស្អាត (នោះ) មកកប់ប្រសព្វហើយ រមែងប្រឡាក់នូវបុគ្គលមកកប់ប្រសព្វ(នោះ) ដែលគេមិនបានប្រឡាក់(ដោយបាបធម៌) ផង ដូចព្រួញដែលគេលាបថ្នាំពិស កាលប្រឡាក់នូវបំពង់ព្រួញ

ដូច្នោះឯង ។ អ្នកប្រាជ្ញ ព្រោះខ្លាចការប្រឡាក់ (ដោយបាបធម៌) ទើបមិនយកបុគ្គលបាបជាសម្លាញ់ឡើយ ។ នរជនណាខ្ចប់ត្រីស្អុយដោយចុងស្បូវ ស្បូវក៏មានក្លិនស្អុយផ្សាយចេញទៅយ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាលក៏យ៉ាងនោះដែរ ។ នរជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ ស្លឹកឈើក៏មានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពគប់នឹងអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ហេតុនោះ បណ្ឌិតដឹងនូវការសម្រេចនៃផលរបស់ខ្លួន ដូចជាកញ្ចប់នៃស្លឹកឈើហើយ មិនគប្បីសេពគប់នឹងពួកអសប្បុរសឡើយ គួរសេពគប់តែនឹងពួកសប្បុរស ។ (ព្រោះ)ពួកអសប្បុរសតែងនាំទៅកាន់នរក ពួកសប្បុរសតែងញុំាងសត្វឲ្យទៅកាន់ស្ថានសួគ៌ ។

ដូច្នេះ ការសេពគប់នូវមិត្តអាក្រក់ ជាបុគ្គលពាល ឬហៅថា អសប្បុរស មិនសេពគប់នូវមិត្តល្អ ជាបណ្ឌិត ឬហៅថា សប្បុរស ជាហេតុនាំឲ្យវិនាស មិនមែនជាមង្គលទេ ។

**ក្នុងបរាភវសូត្រ ព្រះអង្គទ្រង់ត្រាស់ថា ៖**

អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្ត, សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្តអសប្បុរស គាប់ចិត្តក្នុងធម៌ឬមួយរបស់ ហេតុនោះទាំងអស់ នាំឲ្យវិនាស ។

<u>ក្នុងបរមត្ថជោតិកា ខុទ្ទក-អដ្ឋកថា ពន្យល់ថា</u> ៖

សាស្តាទាំង ៦ ឬក៏បុគ្គលសូម្បីពួកដទៃអ្នកប្រកបព្រមដោយកាយកម្ម វចីកម្ម និងមនោកម្ម ដែលមិនស្ងប់ ឈ្មោះថាអសប្បុរស, អសប្បុរសទាំងនោះជាទីស្រឡាញ់ របស់បុគ្គលនោះ ដូចអចេលកកោរក្ខត្តិយៈជាដើម ជាទីស្រឡាញ់របស់បុគ្គលទាំងឡាយមានស្តេចសុនក្ខត្តៈជាដើម ។

ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ឬក៏បុគ្គលសូម្បីពួកដទៃ អ្នកប្រកបព្រមហើយដោយកាយកម្ម វចីកម្ម មនោ-កម្ម ដែលស្ងប់ហើយ ឈ្មោះថា សប្បុរស, មិនធ្វើសប្បុរសទាំងនោះ ឲ្យជាទីស្រឡាញ់ អធិប្បាយថា មិនធ្វើសប្បុរសទាំងនោះឲ្យជាទីស្រឡាញ់ គឺជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីពេញចិត្តនៃខ្លួន ។

ក៏សេចក្ដីផ្សេងគ្នានៃពាក្យក្នុងគាថានេះ គប្បីជ្រាបថា ទ្រង់ធ្វើហើយដោយអំណាចនៃវេនេយ្យសត្វ, មួយវិញទៀត អធិប្បាយថា មិនធ្វើសប្បុរសទាំងឡាយ គឺមិនសេពគប់សប្បុរសទាំងឡាយ ដោយប្រការដូច្នេះ ដូចលោកអ្នកដឹងសព្ទទាំងឡាយពណ៌នាថា ធ្វើព្រះរាជាឲ្យជាទីស្រឡាញ់ក្នុងអត្ថនេះថា រមែងសេពគប់ព្រះរាជា ។

បទថា បិយំ សេចក្ដីថា ស្រឡាញ់ សប្បាយចិត្ត បាមោជ្ជៈ ។ ទិដ្ឋិ ៦២ ឬអកុសលកម្មបថ ១០ ឈ្មោះថា ធម៌របស់អសប្បុរស ។ រមែងពេញចិត្ត រមែងសង្ឃឹមក្នុងចិត្ត រមែងប្រាថ្នា រមែងសេពធម៌របស់អសប្បុរសនោះ ។

ឋានៈទាំង ៣ យ៉ាង គឺ បុគ្គលមានពួកអសប្បុរសជាទីស្រឡាញ់ ១ មិនធ្វើសេចក្ដីស្រឡាញ់ចំពោះពួកសប្បុរស ១ ពេញចិត្តចំពោះធម៌របស់ពួកអសប្បុរស ១ ទ្រង់ត្រាស់ថា ជាប្រធាននៃសេចក្ដីវិនាស ដោយគាថានេះ ដោយប្រការដូច្នេះ ។ ក៏អ្នកប្រកបព្រមដោយឋានៈទាំង ៣ យ៉ាងនោះ រមែងវិនាស គឺរមែងខូចខាត រមែងមិនដល់សេចក្ដីចម្រើនក្នុងលោកនេះ ឬក្នុងលោកខាងមុខ ព្រោះដូច្នោះ ទើបហៅថា ជាប្រធាននៃ

សេចក្តីវិនាស ។ ចំណែកសេចក្តីពិស្តារក្នុងគាថានេះ ខ្ញុំនឹងពោលក្នុងគាថាវណ្ណនាថា ការសេពគប់ជនពាល ១ ការសេពគប់បណ្ឌិត ១ ។

ក្នុងមង្គលសូត្រ ព្រះអង្គត្រាស់ថា ៖

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនេយ្យានំ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

## ៥_ការមិនសេពគប់ពាលនិងការសេពគប់បណ្ឌិត

### ៥.១-បុគ្គលពាលនិងលក្ខណះរបស់បុគ្គលពាល

ការមិនគប់រក ការមិនមានបុគ្គលពាលនោះជាសម្លាញ់ ការមិនចូលជាពួកជាមួយនឹងបុគ្គលពាលនោះ ឈ្មោះថា កិរិយាមិនសេពគប់ ។ សត្វទាំងឡាយឯណាមួយ ជាអ្នកប្រកប

ដោយអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម, សត្វទាំងឡាយនោះ ឈ្មោះថា ពាល ។ មួយវិញទៀត គ្រូទាំងឡាយ ៦ នាក់ នេះគឺ បូរណកស្សប, មក្ខលិគោសាល, និគ្រន្ថនាដបុត្រ, សញ្ជ័យវេលដ្ឋបុត្រ, បកុធកច្ចាយន, អជិតកេសកម្ពល, និងបាបបុគ្គលទាំងឡាយដទៃទៀតក្រៅពីគ្រូទាំង ៦ នោះ មានភិក្ខុទេវទត្ត និងកោកាលិកភិក្ខុជាដើម គប្បីជ្រាបថា "បុគ្គលពាល" ។ មែនពិត ពួកបុគ្គលពាលទាំងអស់នោះឯង លោកហៅថា "ពាល" ព្រោះមិនរស់នៅដោយការរស់នៅដែលប្រកបដោយបញ្ញា រស់នៅដោយហេតុត្រឹមតែការដកដង្ហើម ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ លោកពោលថា "ជនទាំងឡាយឯណារស់នៅ អធិប្បាយថា ចិញ្ចឹមជីវិតនៅដោយហេតុត្រឹមតែការដកដង្ហើមចេញ-ចូល មិនមែនរស់នៅដោយការនៅប្រកបដោយបញ្ញាដ៏ប្រសើរឡើយ, ហេតុនោះជនទាំងឡាយនោះ ទើបឈ្មោះថា ជនពាល" ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ ក៏លោកពោលហើយថា " ពល ធាតុ ប្រព្រឹត្តទៅក្នុងអត្ថថា ប្រាណ, ប្រាណ គឺការរស់នៅ និងការដកដង្ហើម,

បុគ្គលឯណា តែងរស់នៅ គឺដកដង្ហើមចូលនិងដកដង្ហើមចេញ, មានពាក្យដែលលោកពោលទុកថា "ចិញ្ចឹមជីវិតដោយហេតុត្រឹមតែការដកដង្ហើមចូល-ចេញ, មិនមែនរស់នៅដោយការរស់នៅប្រកបដោយបញ្ញាដ៏ប្រសើរឡើយ" ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បុគ្គលពាល ។

ចំណែកលក្ខណៈរបស់បុគ្គលពាល គប្បីជ្រាបដោយអំណាចនៃទុច្ចរិត មានការគិតរឿងដែលគិតមិនល្អជាដើម ។ មែនពិត បុគ្គលពាល សូម្បីកាលគិត ក៏រមែងគិតតែរឿងដែលគិតមិនល្អ ដោយអំណាចនៃអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិតែប៉ុណ្ណោះឯង, សូម្បីកាលនិយាយ ក៏រមែងនិយាយចំពោះតែពាក្យដែលនិយាយអាក្រក់ ផ្សេងដោយវចីទុច្ចរិត មានមុសា-វាទជាដើមប៉ុណ្ណោះឯង, សូម្បីកាលធ្វើ ក៏រមែងធ្វើចំពោះតែកម្មដែលធ្វើអាក្រក់ ដោយអំណាចនៃកាយទុច្ចរិត មានបាណាតិ-បាតជាដើមប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ ទុច្ចរិតទាំងឡាយមានការគិតរឿងដែលគិតមិនល្អជាដើម របស់បុគ្គលនោះ ទើបលោកហៅថា "ពាលលក្ខណៈ" ព្រោះវិគ្រោះថា "បុគ្គលពាល

ជាហេតុដែលបុគ្គលកំណត់ គឺដឹងបាន” ដូច្នេះ ហៅថា “ពាល-និមិត្ត” ព្រោះហេតុនៃការស្គាល់ច្បាស់នូវបុគ្គលពាល និងហៅថា “ពាលាបទាន” ព្រោះបុគ្គលពាលប្រព្រឹត្តមិនដែលខាន ។

ព្រោះហេតុនោះ ក្នុងពាលបណ្ឌិតសូត្រ ក្នុងឧបរិបណ្ណាសកៈ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មានហេតុជាគ្រឿងចំណាំថាពាល (ពាលលក្ខណ) មានហេតុជាគ្រឿងសម្គាល់ថាពាល (ពាល-និមិត្ត) មានចរិតជាពាល (ពាលាបទាន) ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាង តើអ្វីខ្លះ ? ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលក្នុងលោកនេះ ជាអ្នកគិតគំនិតអាក្រក់ ១ និយាយសំដីអាក្រក់ ១ ធ្វើអំពើអាក្រក់ ១ ” ដូច្នេះ ។

## ៥.២-បុគ្គលជាបណ្ឌិតនិងលក្ខណៈរបស់បណ្ឌិត

សត្វទាំងឡាយឯណាមួយ ជាអ្នកប្រកបដោយកុសល-កម្មបថ ១០ មានការវៀរចាកការសម្លាប់សត្វជាដើម, សត្វទាំងឡាយនោះ ឈ្មោះថា បណ្ឌិត ។ មា្យ៉ងទៀត ព្រះពុទ្ធ

ព្រះបច្ចេកពុទ្ធ ព្រះមហាសាវ័ក ៨០ ព្រះសាវ័ករបស់ព្រះ-តថាគតទាំងឡាយដទៃទៀត និងគ្រូសុនេត្រ និងអកិត្តិតាបស ជាដើម ក្នុងអតីតកាល គប្បីជ្រាបថា "ជាបណ្ឌិត" ។ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ទាំងអស់នោះ លោកហៅថា "ជាបណ្ឌិត" ព្រោះធ្វើដំណើរទៅក្នុងប្រយោជន៍ទាំងឡាយ ដោយបញ្ញាគតិ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ លោកពោលថា "ជនទាំងឡាយណាទៅ អធិប្បាយថា "ធ្វើដំណើរទៅក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយិកភព ដោយបញ្ញាគតិ ព្រោះហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា បណ្ឌិត " ។ សូម្បីក្នុងគម្ពីរសទ្ទនីតិ លោកក៏ពោលទុកថា " បឌិ ធាតុ ប្រព្រឹត្តទៅក្នុងកិរិយាទៅ, បញ្ញាឯណា រមែងទៅ គឺធ្វើដំណើទៅក្នុងប្រយោជន៍ទាំងឡាយ សូម្បីដ៏ល្អិតសុខុម គឺដឹងនូវអាការៈសូម្បីមានការបៀតបៀនជាដើមនូវអរិយសច្ចទាំងឡាយ មានសេចក្តីទុក្ខជាដើម ហេតុនោះ បញ្ញានោះ ទើបឈ្មោះថា បណ្ឌា, បុគ្គលណាទៅគឺធ្វើដំណើរទៅ បានដល់ ប្រព្រឹត្តទៅដោយបញ្ញា ដែលមានឈ្មោះ

ថា បណ្ឌា ហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា បណ្ឌិត, ម្យ៉ាងទៀត បុគ្គលឯណាទៅ គឺធ្វើដំណើរទៅដោយញាណគតិ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា " **បណ្ឌិត** " ។

ចំណែកលក្ខណៈរបស់បណ្ឌិត គប្បីជ្រាបដោយអំណាចនៃសុចរិតទាំងឡាយ មានការគិតនូវរឿងដែលគិតល្អជាដើម ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុក ក្នុងពាលបណ្ឌិតសូត្រ យ៉ាងដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត មានហេតុជាគ្រឿងចំណាំថាជាបណ្ឌិត (បណ្ឌិតលក្ខណា) មានហេតុជាគ្រឿងសម្គាល់ថាជាបណ្ឌិត (បណ្ឌិតនិមិត្ត) មានចរិតជាបណ្ឌិត (បណ្ឌិតាបទាន) ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាង តើអ្វីខ្លះ ?, ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតក្នុងលោកនេះ ជាអ្នកគិតគំនិតល្អ (សុចិន្តិតចិន្តី) ១ និយាយសម្តីល្អ (សុភាសិតភាសី) ១ ធ្វើអំពើល្អ (សុកតកម្មការី) ១ " ដូច្នេះ ។ ក៏ពាក្យថា **សុចិន្តិតចិន្តី** ដូច្នេះ ជាដើម បណ្ឌិតគប្បីប្រកបដោយអំណាចនៃសុចរិត មានមនោសុចរិតជាដើម ដូច្នេះឯង ។

ន័យដទៃទៀត ជនទាំងឡាយឯណា រមែងបានទទួល

នូវប្រយោជន៍ទាំងឡាយ ២ គឺប្រតិបត្តិដើម្បីបានទទួលនូវប្រយោជន៍ទាំង ២ នោះ, ជនទាំងឡាយនោះ ឈ្មោះថា បណ្ឌិត ព្រោះព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងឧភោអត្ថសូត្រ ក្នុងកោសលសំយុត្ត យ៉ាងដូច្នេះថា ៖

"ធីរជន លោកហៅថា "បណ្ឌិត" ព្រោះទាញយកប្រយោជន៍ (ទាំង ២) បាន គឺប្រយោជន៍ក្នុងបច្ចុប្បន្ននិងប្រយោជន៍ក្នុងសម្បរាយិកភព" ។

ជនទាំងឡាយឯណា កាត់ចោលនូវប្រយោជន៍ទាំង ២ យ៉ាង កាន់យកនូវហេតុមិនមែនជាប្រយោជន៍ទាំង ២ យ៉ាង, ជនទាំងឡាយនោះ ឈ្មោះថា ពាល ។ មែនពិត ជនទាំងឡាយនោះ លោកហៅថា "ពាល" ក៏ព្រោះកាន់យកនូវហេតុដែលមិនមែនជាប្រយោជន៍ទាំងឡាយ ២ ប្រការ និងលោកហៅថា "ពាល" ក៏ព្រោះកាត់ផ្តាច់ចោលនូវប្រយោជន៍ទាំងឡាយ ២ ប្រការ ។ កិរិយាស័ព្ទថា " លន្តិ " នោះ ចាត់ចូលក្នុងពួកធាតុមាន ភូ ធាតុ ជាដើម ដោយការបន្ទាប់ថា " លា ធាតុ មាន ទ្វិស័ព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅក្នុងអត្ថថា កាន់យក " ។

កិរិយាសព្ទថា " លុនន្តិ " នោះ ចាត់ចូលក្នុងពួកធាតុ មាន កី ធាតុ ជាដើមដោយការបង្គាប់ថា "លុ ធាតុ មាន ទ្វិ សព្ទ ជាបទប្រៀបធៀបប្រព្រឹត្តទៅក្នុងអត្ថថា កាត់ចោល" ដូច្នេះ ។

## ៦.បុគ្គលដែលគួរសេពគប់និងមិនគួរសេពគប់

បណ្តាជនពាលនិងបណ្ឌិតទាំង ២ ពួកនោះ ពួកបណ្ឌិតប៉ុណ្ណោះ គឺបុគ្គលត្រូវសេពគប់, ពួកជនពាល គឺបុគ្គលមិនត្រូវសេពគប់ឡើយ, ព្រោះពួកជនពាល ប្រៀបដូចជាត្រីស្អុយ, បុគ្គលអ្នកសេពគប់ជាមួយជនពាលនោះ ប្រៀបដូចស្លឹកឈើដែលសម្រាប់ខ្ចប់នូវត្រីស្អុយ ដែលដល់ហើយនូវភាពជាអ្នកគឺពួកវិញ្ញូជនគប្បីបោះបង់ចោល និងស្អប់ខ្ពើម ។ (ចំណែក) បណ្ឌិត ប្រៀបដូចជាគ្រឿងក្រអូប មានក្រស្នានិងមាលាជាដើម, បុគ្គលអ្នកសេពគប់ជាមួយនឹងបណ្ឌិតនោះ ក៏ប្រៀបដូចជាស្លឹកឈើដែលសម្រាប់ខ្ចប់នូវគ្រឿងក្រអូប មានក្រស្នា និងមាលាជាដើម ដែលដល់ហើយនូវភាពជាអ្នកគួរសរសើរ និងគួរជាទីពេញចិត្តនៃពួកវិញ្ញូជន ។ ក៏បុគ្គលណា សេពគប់

នូវបុគ្គលណា, បុគ្គលនោះ រមែងមានបុគ្គលនោះជាគតិដោយពិត ។ ក៏ដើម្បីនឹងសម្តែងនូវសេចក្តីនេះ គប្បីពណ៌នារឿងកូនសេកជាដើម ( ដូចតទៅនេះ )

## រឿង កូនសេក

បានឮមកថា ក្នុងអតីតកាល បានមានកូនសត្វសេក ២ បងប្អូននឹងគ្នា (នៅ) ក្នុងព្រៃរកា ក្បែរសានុបពត៌ ។ ក៏ក្នុងទីខាងលើខ្យល់នៃបព្វតា បានមានផ្ទះជាទីនៅអាស្រ័យរបស់ចោរ ៥០០ នាក់, ក្នុងទីខាងក្រោមខ្យល់ មានអាស្រមជាទីនៅអាស្រ័យរបស់តាបសឥសី ៥០០ រូប ។ ក្នុងពេលដែលរោមស្លាបរបស់កូនសត្វសេកទាំងឡាយ មិនទាន់ដុះនៅឡើយ ក៏មានខ្យល់ព្យុះកំបុតត្បូងកើតឡើង ។ កូនសេកទាំង ២ នោះ ត្រូវខ្យល់ព្យុះកំបុតត្បូងនោះ ផាត់ទៅធ្លាក់ហើយ (ក្នុងទី) ផ្សេងៗ ពីគ្នា ។ បណ្តាកូនសេកទាំង ២ នោះ កូនសេក ១ បានធ្លាក់ទៅក្នុងចន្លោះនៃគ្រឿងសស្ត្រាវុធ ក្នុងផ្ទះរបស់ចោរ ព្រោះធ្លាក់ទៅក្នុងទីនោះ ទើបពួកចោរដាក់ឈ្មោះថា “សត្តិគុម្ព”

ជាត់ធំឡើងហើយ ក្នុងចន្លោះនៃពួកចោរទាំងនោះ ។ កូនសេក ១ បានធ្លាក់ទៅក្នុងចន្លោះនៃផ្កាឈើ លើផ្ទៃនៃវាលដីខ្សាច់ ក្បែរអាស្រម ព្រោះហេតុដែលធ្លាក់ទៅក្នុងទីនោះ ទើបបានពួក-តាបសឥសី ដាក់ឈ្មោះថា "បុប្ផកៈ" បានជាត់ធំឡើងហើយក្នុងចន្លោះនៃពួកតាបសឥសីទាំងនោះ ។

ក្នុងគ្រានោះ ព្រះរាជាទ្រង់ព្រះនាមបញ្ចាលៈ ក្នុងនគរឈ្មោះឧត្តរបញ្ចាលៈ ទ្រង់ប្រដាប់គ្រឿងអលង្ការសព្វគ្រប់ហើយ ទ្រង់ស្តេចយាងឡើងកាន់ព្រះរាជរថ យាងទៅកាន់ព្រៃដើម្បីទ្រង់បរបាញ់សត្វ ហើយទ្រង់មានព្រះរាជឱង្ការថា "សត្វ-ម្រឹគរត់ចេញទៅតាមប្រឡោះនៃបុគ្គលណា, បុគ្គលនោះឯងនឹងត្រូវមានទោស (អាជ្ញា) " ដូច្នេះ ហើយទ្រង់ស្តេចយាងចុះអំពីព្រះរាជរថ ទ្រង់បានកាន់ធ្នូ គង់នៅហើយក្នុងទីកំបាំង ។

ក្នុងខណៈនោះ ម្រឹគទ្រាយ១, កាលបើពួកមនុស្សកំពុងវាយគុម្ពោតព្រៃ ក៏បានក្រោកឡើង សំឡឹងរកមើលផ្លូវដើម្បីនឹងទៅ ក៏ឃើញថា ទីស្ថានដែលព្រះរាជាទ្រង់គង់នៅប៉ុណ្ណោះជាទីដែលស្រឡះ (ទំនេរ) ទើបបែរមុខឆ្ពោះទៅទិសខាងនោះ

ហើយស្ទុះបោលគេចទៅ ពួកមនុស្ស ក៏បានធ្វើការចំអកជាមួយនឹងព្រះរាជា ។ ព្រះអង្គទ្រង់តាំងព្រះទ័យថា "អញនឹងចាប់ម្រឹគទ្រាយនោះឲ្យបាន ក្នុងពេលឥឡូវនេះ" ហើយទើបស្តេចទ្រង់ឡើងរាជរថ ហើយទ្រង់ដេញតាមម្រឹគទ្រាយទៅយ៉ាងលឿន ។ ពួកបុរស មិនអាចតាមជាប់ព្រះអង្គបានឡើយ។ ព្រះរាជាទ្រង់មាននាយសារថីជាគម្រប់ ២ ទតមិនឃើញម្រឹគទ្រាយហើយ ទើបទ្រង់ស្តេចយាងត្រឡប់មកវិញ ទ្រង់ស្រង់ទឹក និងសោយទឹក ក្នុងជ្រោះភ្នំដែលជាទីគួរមនោរម្យហើយស្តេចទ្រង់បន្ទំក្រោមម្លប់ឈើ ក្បែរផ្ទះនៃចោរ ។

គ្រានោះ ពួកចោរ ក៏បានចូលទៅកាន់ព្រៃទាំងអស់គ្នាហើយ, ខាងក្នុងផ្ទះ នៅសល់តែសេកឈ្មោះសត្តិគុម្ព: ជាមួយនឹងអ្នកចំអិនភត្តម្នាក់ ។ សេកសត្តិគុម្ព: ហើរចេញពីផ្ទះ ឃើញព្រះរាជាទ្រង់បន្ទំយ៉ាងដូច្នោះហើយ ក៏ (ហើរ) ចូលផ្ទះ បាននិយាយជាភាសាមនុស្ស ជាមួយនឹងអ្នកជាំស្លថា "ពួកយើងនឹងសម្លាប់ព្រះរាជាចោល ប្រមូលយកសំពត់នឹងគ្រឿងអលង្ការរបស់ព្រះអង្គ ហើយចាប់ព្រះអង្គត្រង់កព្រះបាទ ទាញ

អូសមកហើយ យកស្លឹកឈើទាំងឡាយមកគ្របបិទបាំង ក្នុងទីកន្លែងមួយ" ។ ព្រះរាជាទ្រង់តើនពីព្រះបន្ទំហើយ ទ្រង់ព្រះ-សណ្ដាប់សំឡេងនោះ ទ្រង់ជ្រាបថា "ទីកន្លែងនេះ មានភ័យចំពោះមុខ" ហើយទ្រង់មានព្រះទ័យភ័យខ្លាច ទើបទ្រង់ស្ដេចឡើងកាន់រាជរថ ហើយទ្រង់ចៀសចេញពីទីនោះ ស្ដេចក៏បានយាងទៅដល់អាស្រមរបស់តាបសឥសី ។

ក្នុងគ្រានោះ ពួកតាបសឥសីទៅហើយដើម្បីប្រយោជន៍ដល់ផលាផល, ក្នុងអាស្រម នៅសល់តែសត្វសេកឈ្មោះបុប្ផកៈប៉ុណ្ណោះ ។ សត្វសេកឈ្មោះបុប្ផកៈនោះ ឃើញព្រះរាជាហើយ ក៏បានធ្វើនូវបដិសណ្ឋារៈ ដោយន័យមានជាដើមថា ៖

> បពិត្រមហារាជ ព្រះអង្គទ្រង់ស្ដេចយាងមកប្រពៃហើយ មួយទៀត ព្រះរាជដំណើររបស់ព្រះអង្គមិនមែនទាស់ទេ " ។

ព្រះរាជា ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងបដិសណ្ឋារៈរបស់សត្វសេកឈ្មោះបុប្ផកៈនោះហើយ ទ្រង់ត្រាស់សរសើរ

នូវសេកឈ្មោះបុប្ផកៈ ទ្រង់បានតិះដៀលនូវសេកឈ្មោះសត្តិគុម្ពៈក្រៅនេះ ដោយព្រះតម្រាស់ថា

"សត្វបក្សីជាតិ ២ នេះ ជាសត្វដ៏ល្អប្រកបដោយធម៌ដ៏ក្រៃលែងតើហ្ន៎, ចំណែកតែបក្សីសេកក្រៅពីនេះ និយាយតែពាក្យអាក្រក់ " ។

សេកឈ្មោះបុប្ផកៈ ស្តាប់នូវព្រះរាជឱង្ការនោះហើយទើបបានក្រាបទូលថា "បពិត្រព្រះមហារាជ ទូលព្រះបង្គំ មានមាតាជាមួយគ្នានឹងសត្វសេកឈ្មោះសត្តិគុម្ពនោះ, ប៉ុន្តែសេក-សត្តិគុម្ពនោះធាត់ធំឡើងហើយ ក្នុងសំណាក់នៃពួកមនុស្សមិនល្អ ត្រូវពួកមនុស្សមិនល្អទាំងនោះដឹកនាំហើយ ដោយចោរធម៌, (ចំណែក) ទូលព្រះបង្គំ ធាត់ធំឡើងហើយក្នុងសំណាក់មនុស្សល្អ ត្រូវបានពួកមនុស្សល្អទាំងនោះ ដឹងនាំហើយដោយឥសីធម៌, ហេតុនោះ ទើបទូបព្រះបង្គំទាំង ២ ផ្សេងពីគ្នាដោយធម៌ " ដូច្នេះហើយ កាលសម្តែងធម៌ដល់ព្រះរាជា ទើបបានពោលគាថាទាំងនេះថា

"បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់រកនូវបុគ្គល

បែបណាៗ ទោះជាសប្បុរស ឬអសប្បុរស មានសីល ឬ ឥតសីល រមែងលុះក្នុងអំណាចបុគ្គលនោះឯង ។ បុគ្គល ធ្វើបុគ្គលបែបណាឲ្យជាមិត្ត និងចូលទៅគប់រកនូវបុគ្គល បែបណា, បុគ្គលនោះ ក៏មានអាការៈបែបនោះដែរ, ព្រោះ កិរិយានៅរួម ក៏រមែងប្រាកដដូច្នោះ ។ អាចារ្យត្រូវកូន សិស្សគប់រក រមែងប្រឡាក់នូវកូនសិស្សអ្នកគប់រក, ត្រូវ កូនសិស្សប៉ះពាល់ហើយ រមែងប្រឡាក់នូវកូនសិស្ស ដែលមិនបានប្រឡាក់ហើយ ប្រៀបឧបមាដូចជាកូនសរ ដែលជ្រលក់ដោយថ្នាំពិស តែងប្រឡាក់បំពង់សរដូច្នោះ ឯង, ព្រោះភ័យខ្លាចអំពីការប្រឡាក់ អ្នកប្រាជ្ញ ទើបមិន យកបុគ្គលលាមកជាសម្លាញ់សោះឡើយ ។ ជនណាខ្ចប់ នូវត្រីស្អុយដោយចុងស្បូវភ្លាំង, សូម្បីស្បូវភ្លាំង ក៏មាន ក្លិនស្អុយផ្សាយចេញទៅដែរ យ៉ាងណាមិញ, ការចូលទៅ សេពគប់នូវបុគ្គលពាល (របស់ជននោះ) ក៏យ៉ាងដូច្នោះ ដែរ ។ ជនណា ខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ, សូម្បី ស្លឹកឈើក៏មានក្លិនក្រអូបផ្សាយចេញទៅដែរ យ៉ាងណា

មិញ, ការចូលទៅសេពគប់នូវអ្នកប្រាជ្ញ (របស់ជននោះ) ក៏យ៉ាងនោះដូច្នោះដែរ ។ ព្រោះហេតុនោះ បុគ្គលជាបណ្ឌិត ដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើហើយ មិនគួរសេពគប់នូវពួកអសប្បុរស គួរសេពគប់តែពួកសប្បុរស, (ត្បិត) ពួកអសប្បុរស តែងនាំទៅកាន់នរក, ពួកសប្បុរស តែងផ្តល់នូវសុគតិ" ។

បណ្តាបទទាំងនោះ បទថា **សន្តំ** បានដល់ សប្បុរស ។ បទថា **អសំ** បានដល់ អសប្បុរស ។ បទថា **សេវមានោ** បានដល់ អាចារ្យ ។ បទថា **សេវមានំ** បានដល់ អន្តេវាសិក។ បទថា **សម្ផុដ្ឋោ** បានដល់ អាចារ្យដែលអន្តេវាសិក ពាល់ត្រូវហើយ ។ ពីរបទថា **សម្ផុសំ បរំ** បានដល់ បុគ្គលដទៃ គឺអន្តេវាសិកដែលប៉ះពាល់នូវអាចារ្យ ។ បទថា **អលិត្តំ** មានសេចក្តីថា អាចារ្យនោះ រមែងប្រឡាក់នូវអន្តេវាសិកនោះ, ជាអ្នកដែលបាបធម៌មិនបានប្រឡាក់ហើយ ប្រៀបដូចជាកូនសរដែលកំណាច គឺដែលជ្រលក់ហើយដោយថ្នាំពិស ប្រឡាក់នូវបំពង់សរដែលមិនបានប្រឡាក់យ៉ាងដូច្នោះឯង ។ មែនពិត

បុគ្គលអ្នកសេពគប់នូវបុគ្គលពាល សូម្បីមិនបានធ្វើនូវអំពើអាក្រក់ ក៏រមែងបានទទួលនូវការពោលតិះដៀល និងការនិន្ទាថា "ជាអ្នកសេពគប់ជាមួយនឹងបុគ្គលពាល" ដូច្នេះដែរ, ហេតុនោះទើបលោកបុច្ឆកៈពោលថា " **ឯវំ ពាលូបសេវនា** " ។ (ចំណែក) បុគ្គលអ្នកសេពគប់ជាមួយនឹងអ្នកប្រាជ្ញ សូម្បីមិនអាចដើម្បីនឹងកើតជាអ្នកប្រាជ្ញបាន ក៏រមែងបានទទួលនូវឈ្មោះសំឡេងដ៏ល្អថា "ជាអ្នកសេពគប់ជាមួយនឹងកល្យាណមិត្ត" ដូច្នេះដែរ ។ ហេតុនោះ ទើបលោកបុច្ឆកៈ ពោលថា " **ឯវំ ធីរូបសេវនា** " ។

បទថា **បត្តបុដស្សេវ** គឺដូចជាស្លឹកឈើដែលសម្រាប់ខ្ចប់នូវគន្ធជាតិ មានក្រស្នាជាដើមនុ៎ះឯង ។

បទថា **សម្បាកំ** គឺ ដឹងថាខ្លួនអប់រំហើយ ដោយអំណាចនៃការជាប់ជំពាក់ជាមួយនឹងកល្យាណមិត្ត ។

បទថា **សន្តោ** មានសេចក្តីថា ពួកជនជាសម្មាទិដ្ឋិរមែងញ៉ាំងពួកសត្វដែលអាស្រ័យនឹងខ្លួន ឲ្យដល់ឋានសួគ៌តែម្យ៉ាង។

ព្រះរាជាទ្រង់ជ្រះថ្លាហើយ ក្នុងធម្មកថារបស់សត្វលោក

ឈ្មោះបុប្ផកៈនោះហើយ ទ្រង់ថ្វាយបង្គំនូវពួកតាបសឥសី ដែលត្រឡប់មកវិញ ហើយទ្រង់មានព្រះរាជឱង្ការថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើនទាំងឡាយ បើព្រះគុណម្ចាស់ទាំងឡាយ អនុគ្រោះយើងខ្ញុំ ក៏សូមគង់នៅក្នុងនគររបស់យើងខ្ញុំ " ដូច្នេះហើយ ក៏ស្ដេចយាងទៅកាន់ព្រះនគរ ទ្រង់ព្រះរាជទានអភ័យដល់សត្វសេកទាំងឡាយហើយ ទ្រង់ត្រាស់ឲ្យគណៈតាបសឥសី ដែលមកហើយ ក្នុងព្រះនគរនោះនៅក្នុងព្រះរាជឧទ្យាន ទ្រង់បានទំនុកបម្រុងរហូតដល់អស់ព្រះជន្មាយុហើយ ទ្រង់បំពេញផ្លូវទៅកាន់ឋានសួគ៌ ។ ចំណែកសត្វសេកបុប្ផកៈអាស្រ័យនៅក្នុងព្រៃ ទៅហើយតាមយថាកម្ម ។

រឿងសត្វសេក ក្នុងអដ្ឋកថាសត្តិគុម្ពជាតក
ក្នុងវីសតិនិបាត ចប់ ។

## រឿង ដំរីឈ្មោះមហិឡាមុខ

ក្នុងអតីតកាល ព្រះរាជាព្រះបាទព្រហ្មទត្ត ក្នុងព្រះនគរពារាណសី បានមានដំរីមង្គល ឈ្មោះមហិឡាមុខ ជាសត្វមានសីល បរិបូរណ៍ដោយមារយាទ មិនចេះបៀតបៀនអ្នកណាម្នាក់

ឡើយ ។

ក្រោយមក ថ្ងៃមួយ ក្នុងពេលរាត្រី ពួកចោរមកហើយ បានអង្គុយប្រឹក្សាគ្នា នៅក្បែររោងដំរីរបស់ព្រះរាជាអង្គនោះ ថា "ពួកយើង ត្រូវទំលាយឧម្មង្គ (រូង) យ៉ាងដូច្នេះ, ត្រូវធ្វើកម្ម គឺការកាត់ទីតយ៉ាងដូច្នេះ, ការដែលពួកយើងទំលាយនូវឧម្មង្គ និងធ្វើការកាត់ទីតហើយ លួចយកនូវកណ្ឌ ទើបគួរ, កាល នឹងលួចយក ត្រូវតែសម្លាប់ និងវាយដំ (ម្ចាស់ទ្រព្យ) ហើយ ទើបលួចយកទៅ, កាលធ្វើយ៉ាងនេះ នឹងមិនមានអ្នកណា អាចដើម្បីនឹងក្រោកឡើង (បាន), ក៏ធម្មតាចោរ មិនត្រូវមាន សីលាចារវត្តឡើយ, ត្រូវតែជាអ្នកកំណាច ឃោរឃៅ កាច សាហាវ" ដូច្នេះ ។ ពួកចោរទាំងនោះ ប្រឹក្សាគ្នាយ៉ាងដូច្នេះ ហើយ ក៏បានណាត់គ្នាទៅវិញទៅមកស្រេច ទើបនាំគ្នាទៅ ។ ពួកចោរទាំងនោះមកប្រឹក្សាគ្នាក្នុងទីនោះ ដោយឧបាយនេះឯង អស់ជាច្រើនថ្ងៃ , ដំរីបានស្តាប់ពាក្យរបស់ពួកចោរទាំងនោះ ហើយ ក៏សម្គាល់ថា "ពួកចោរទាំងនោះ ញុំាងអញឲ្យសិក្សា" ហើយគិតថា "ក្នុងពេលឥឡូវនេះ អញត្រូវតែជាសត្វកំណាច

កាច យោរយៅសាហាវ” ដូច្នេះហើយ ក៏បានទៅជាសត្វយ៉ាងនេះ ។ ដំរីនោះ បានយកប្រមោយចាប់អ្នកថែរក្សាដំរីដែលមកហើយ ។ អំពីព្រឹកព្រលឹមស្រោងហើយបានបោកទៅលើផែនដីឲ្យស្លាប់ ។

ពួកមនុស្ស បានក្រាបទូលហើយដល់ព្រះរាជា ។ ព្រះរាជា ទ្រង់បានបញ្ជូននូវអមាត្យម្នាក់ទៅ ដោយព្រះរាជ-ឱង្ការថា “នែបណ្ឌិត អ្នកចូរទៅចុះ, ចូល (ពិនិត្យ) ឲ្យដឹងថា ព្រោះហេតុអ្វី ? បានជាដំរីនោះក្លាយទៅជាសត្វកាចសាហាវដូច្នេះ ” ។

អមាត្យនោះទៅហើយ ក៏មិនឃើញមានរោគក្នុងខ្លួននៃដំរី ទើបគិតថា “ដំរីនេះ បានកាចសាហាវហើយ ព្រោះហេតុអ្វី ? ដូច្នេះ កាលពិចារណាទៅ ទើបធ្វើការសន្និដ្ឋានថា “ដំរីនោះ ពិតជាបានស្តាប់ពាក្យអាក្រក់របស់ជនពួកខ្លះ ក្នុងទីមិនឆ្ងាយដោយពិត ទើបបានក្លាយទៅជាសត្វកាចសាហាវ” ហើយបានសួរពួកជនអ្នកថែរក្សាដំរីថា “តើមានបុគ្គលណាខ្លះធ្លាប់និយាយអ្វីៗ ក្នុងពេលរាត្រី នៅក្បែររោងដំរីដែរឬទេ? ” ។

ពួកអ្នកថែរក្សាដំរីពោលថា "បពិត្រនាយ មានពួកចោរ បាន មកប្រឹក្សាគ្នា" ។ អមាត្យនោះ ទៅក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ក្នុងខ្លួនដំរីមិនមានការចំឡែកអ្វីដទៃ ឡើយ, ដំរីនោះ បានស្ដាប់ពាក្យរបស់ពួកចោរហើយ ទើបបាន ជាសត្វកាចសាហាវ, ឥឡូវនេះ គួរតែនិមន្តពួកសមណៈ និង ព្រាហ្មណ៍ អ្នកមានសីល ឲ្យគង់នៅក្បែររោងដំរី ហើយសូមឲ្យ រៀងសីលនិងមារយាទ" ។ ព្រះរាជាទ្រង់ត្រាស់ឲ្យធ្វើហើយ យ៉ាងដូច្នោះ ។ សមណៈនិងព្រាហ្មណ៍ទាំងឡាយនោះ បាន ពោលរៀងសីលថា "អ្នកមិនគួរចាប់អ្នកណាម្នាក់ឡើយ, មិនគួរ សម្លាប់អ្នកណាម្នាក់ឡើយ, គួរជាអ្នកបរិបូរណ៍ដោយសីល និងមារយាទ ប្រកបដោយខន្តី មេត្តា និងសេចក្ដីអនុគ្រោះ" ។ ដំរីស្ដាប់ពាក្យនោះហើយ ទើបសម្គាល់ថា "សមណៈ និង ព្រាហ្មណ៍ទាំងនេះ ញ៉ាំងអញឲ្យសិក្សា" ហើយគិតថា "តាំងតែ អំពីពេលនេះទៅ អញត្រូវតែមានសីល" ដូច្នេះ ហើយក៏បាន ក្លាយទៅជាសត្វមានសីល ។

# រឿង សេះឈ្មោះបណ្ឌវៈ

ក្នុងអតីតកាល បានមានព្រះរាជាទ្រង់ព្រះនាមថាសាមៈ ក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វបានជាអមាត្យអ្នកបង្រៀនអត្ថនិងធម៌របស់ព្រះរាជាអង្គនោះ ។ ក៏ព្រះរាជាទ្រង់មានសេះមង្គល ឈ្មោះបណ្ឌវៈ ។ អ្នកគង្វាលសេះរបស់ព្រះអង្គ ឈ្មោះ **គិរិទត្ត** ជាមនុស្សខ្វក ។ សេះឃើញអ្នកគង្វាលសេះនោះចាប់ខ្សែបង្ហៀរ (ដឹក) នាំមុខហើយ ក៏សម្គាល់ថា "អ្នកគង្វាលសេះនេះ ញុំាងអញឲ្យសិក្សា" ដូច្នេះហើយ ទើបយកតម្រាប់តាមអាការៈរបស់អ្នកគង្វាលសេះនោះ បានក្លាយទៅជាសេះ-ខ្វក ។ ព្រះរាជា ទ្រង់ជ្រាបថា សេះរបស់ព្រះអង្គនោះខ្វកហើយ ទើបទ្រង់បានត្រាស់បញ្ជូនពេទ្យទៅ (ឲ្យត្រួតពិនិត្យមើល) ។ ពួកពេទ្យទាំងនោះទៅហើយ មិនឃើញរោគនៅក្នុងខ្លួនរបស់សេះនោះ ទើប(ត្រឡប់មក) ក្រាបទូលព្រះរាជាថា "ទូលព្រះបង្គំ មិនឃើញរោគរបស់សេះនោះទេ" ។ ព្រះរាជាទ្រង់បញ្ជូននូវព្រះពោធិសត្វទៅ ដោយព្រះរាជឱង្ការថា "ចូរអ្នកទៅ (ត្រួតពិនិត្យមើលឲ្យ) ដឹងនូវហេតុក្នុងដំណើរនោះ" ។

ព្រះពោធិសត្វនោះទៅហើយ បានដឹងថា សេះនោះដើរខ្ចកៗ ព្រោះការនៅរួមជាមួយគ្នានឹងអ្នកគង្វាលសេះជើងខ្ចក យ៉ាងដូច្នេះ ក្រាបទូលថា "បពិត្រព្រះមហារាជ សេះមានជើងខ្ចក យ៉ាងដូច្នោះ ព្រោះទោសនៃការនៅរួមជាមួយគ្នា (នឹងអ្នកគង្វាលសេះជើងខ្ចក)" ដូច្នេះហើយទើបបានក្រាបទូលព្រះរាជាទៀតថា "សេះនោះ បាននូវអ្នកគង្វាលសេះដែលល្អហើយ ក៏នឹងក្លាយជាសេះដូចដើមវិញ" ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាឲ្យធ្វើយ៉ាងដូច្នោះហើយ សេះបានតាំងនៅក្នុងភាពប្រក្រតីវិញ ។

(រឿងសេះបណ្ឌវៈ ក្នុងអដ្ឋកថាគិរិទត្តជាតក ក្នុងទុកនិបាត)

ព្រោះហេតុនោះ អ្នកប្រាជ្ញ ដឹងនូវការសម្រេចនៃផលរបស់ខ្លួន ដូចជាកញ្ចប់នៃស្លឹកឈើហើយ មិនគប្បីសេពគប់នឹងពួកអសប្បុរសឡើយ គួរសេពគប់តែនឹងពួកសប្បុរសប៉ុណ្ណោះ ។ (ព្រោះ) ពួកអសប្បុរសតែងនាំទៅកាន់នរក ពួកសប្បុរស តែងញុំាងសត្វឲ្យទៅកាន់ស្ថានសួគ៌ ។

# ៧-ប្រភេទនៃមិត្តសម្លាញ់

## ៧.១-ហេតុ ៦ ប្រការតែងបំផ្លាញបុរសឱ្យវិនាស

មិត្តសម្លាញ់មានច្រើនប្រភេទ ដូចដែលព្រះមានព្រះ-ភាគ ទ្រង់ត្រាស់ចំពោះសិង្គាលកមាណព មានក្នុងសុត្តន្តបិដក លេខ១៩ ទំព័រ៧៥ ថា "បុគ្គលខ្លះ ជាមិត្តសម្លាញ់បានតែក្នុងពេងសុរាក៏មាន បុគ្គលខ្លះជាសម្លាញ់ៗ តែនៅចំពោះមុខក៏មាន បុគ្គលណាកាលបើប្រយោជន៍(ខ្លួន)កើតឡើង ទើបធ្វើជាសម្លាញ់ បុគ្គលនោះមកជាសម្លាញ់នឹងខ្លួនក៏មាន ។ កិរិយាដេកដល់ថ្ងៃ ១ ការធ្វើសេវនកិច្ចជាមួយប្រពន្ធអ្នកដទៃ ១ ភាវៈជាអ្នកមានពៀរច្រើន ១ ភាវៈជាអ្នកធ្វើអំពើឥតប្រយោជន៍ ១ បាបមិត្ត ១ ភាវៈជាអ្នកកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ យ៉ាងនុ៎ះ រមែងបំផ្លាញបុរស (ឲ្យវិនាស) ។ នរជនដែលមានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ មានមារយាទ និងគោចរអាក្រក់ តែងវិនាសចាកលោកទាំងពីរ គឺលោកនេះ និងលោកខាងមុខ ។ ល្បែងភ្នាល់ ល្បែងស្រី និងល្បែងសុរា ១ របាំនិងចំរៀង ១ ការដេកថ្ងៃ ១ ការឲ្យគេបម្រើខ្លួនក្នុងកាល

មិនគួរ ១ ពួកមិត្តអាក្រក់ ១ ភាវៈជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នេះតែងបំផ្លាញបុរសឲ្យវិនាស ។ ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ចនឹងស្រីដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោក-ទាប (ខាតលក្ខណ៍) មិនសេពគប់នឹងបុគ្គលដែលមានសេចក្តីចម្រើន (គ្រប់លក្ខណ៍) យសរបស់ពួកជននោះតែងសាប-សូន្យដូចព្រះចន្ទ្រខាងរនោច ។ ជនដែលជាអ្នកផឹកសុរា ជាអ្នកខ្សត់ទ្រព្យ ជាអ្នកឥតមានកន្លល់ដោយការងារចិញ្ចឹមជីវិតមានតែស្រវឹងជានិច្ច ប្រាសចាកសេចក្តីចម្រើន លិចចុះក្នុងបំណុល ដូចដុំថ្មលិចទៅក្នុងទឹក បុគ្គលនោះ តែងធ្វើការងារឲ្យវឹកវរដល់ខ្លួនដោយឆាប់ ។ បុគ្គលដេកក្នុងវេលាថ្ងៃ ជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ចជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះត្រជាក់ណាស់

ក្តៅណាស់ ល្ងាចណាស់ ។ ជនណាមួយធ្វើនូវកិច្ចការរបស់បុរស មិនអើពើនូវត្រជាក់ និងក្តៅ ក្រៃលែងជាងស្មៅ (ទៅទៀត) ជននោះរមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។

## ៧.២-មិត្តប្លម ៤ ពួក

ម្នាលគហបតិបុត្ត អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ៤ ពួកនេះ គឺអ្នកត្រូវស្គាល់ **អញ្ញទត្ថុហរោ** (មនុស្សដែលគិតយកតែប្រយោជន៍ខ្លួន) ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១, អ្នកត្រូវស្គាល់ **វចីបរមោ** (មនុស្សល្អតែសំដី) ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១, អ្នកត្រូវស្គាល់ **អនុប្បិយភាណី** (មនុស្សដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត) ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១, អ្នកត្រូវស្គាល់ **អបាយសហាយោ** (មនុស្សជាសម្លាញ់ក្នុងការដឹកនាំឲ្យវិនាសភោគៈទាំងឡាយ) ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១ ។

ម្នាលគហបតិបុត្ត មនុស្សគិតយកតែប្រយោជន៍ខ្លួន

មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញូម(នោះ) អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺ មិត្តគិតយកតែប្រយោជន៍ខ្លួន ១, មិត្តប្រាថ្នាយករបស់ច្រើន ដោយ(ឲ្យ)របស់តិចតួច ១, ទាល់តែមានភ័យទើបជួយធ្វើកិច្ចរបស់មិត្ត ១, សេពគប់មិត្ត ព្រោះហេតុតែប្រយោជន៍ ១ ។ ម្នាលគហបតិបុត្ត មិត្តគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតិបុត្ត **មិត្តល្អតែសំដី** មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ គឺ មិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ ១, ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក ១, សង្គ្រោះដោយអំពើឥតប្រយោជន៍ ១, កាលកិច្ចទាំងឡាយកើតឡើងភ្លាមៗ ក៏សម្តែងអាងរបស់ខូចខាត[១] ១, ម្នាលគហបតិបុត្ត មិត្តល្អតែសំដី

---

[១] ពឹងការអ្វីមិនបាន បើត្រូវរកអ្វីៗ ក៏ប្រាប់ថារបស់នោះខូច នេះបាត់នោះជាដើម ។

មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ បើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម ១, មិត្តធ្វើអំពើល្អក៏យល់ព្រមតាម ១, ពណ៌នាគុណមិត្តតែក្នុងទីចំពោះមុខ ១, ពោលទោសមិត្តក្នុងទីកំបាំងមុខ ១ ។ ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិន-មែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹក-ស្រវឹង គឺសុរាមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១, ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវការត្រាច់ទៅតាមច្រក-ល្ហកខុសកាល ១, ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែង

មហោស្រព ១, ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវល្បែងភ្នាល់ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ ក្នុងផ្លូវវិនាសមិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់បានសម្តែងសេចក្តីនេះ លុះព្រះសុគតសាស្តាសម្តែងសេចក្តីនេះហើយ ទើបទ្រង់សម្តែងពាក្យគាថាព័ន្ធតទៅទៀតថា ៖

បុគ្គលដែលជាមិត្តគិតយកតែប្រយោជន៍ខ្លួន ១ បុគ្គលដែលជាមិត្តល្អតែសំដី ១ បុគ្គលដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត ១ បុគ្គលដែលជាសម្លាញ់ក្នុងផ្លូវវិនាស ១ បណ្ឌិតដឹងថា បុគ្គលទាំង ៤ ពួកនុ៎ះ មិនមែនជាមិត្ត ហើយគប្បីចៀសវាងឲ្យឆ្ងាយ ដូចជាអ្នកដំណើរ ចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ ។

## ៧.៣-មិត្តមានសន្តានល្អ

ម្នាលគហបតិបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ គឺ មិត្តមានឧបការៈ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១, មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១, មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១, មិត្តមានសេចក្តីឈឺឆ្អាល អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ ។

ម្នាលគហបតិបុត្ត **មិត្តមានឧបការៈ** ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ រក្សាមិត្តដែលធ្វេស-ប្រហែស ១, រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១, ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ ១, កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់កោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ។ ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១, ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១, មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ១, សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត (ស៊ូប្តូរជីវិត) ១ ។ ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ ហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១, ដឹកនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ១, ឲ្យបានស្តាប់ពាក្យដែលមិនធ្លាប់បានស្តាប់ ១, ប្រាប់ផ្លូវឋានសួគ៌ ១ ។ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១, ជួយត្រេកអរ ព្រោះមិត្ត

បានសេចក្តីចម្រើន ១, ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត ១, សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ។ ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈ្លើឈ្លាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់បានសម្តែងសេចក្តីនេះ លុះព្រះសុគតជាសាស្តាត្រាស់សេចក្តីនេះហើយ ទើបទ្រង់សម្តែងពាក្យជាគាថាព័ន្ធតទៅទៀតថា (ជាសេចក្តីប្រែ) :

មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្តីឈ្លើឈ្លាល ។ បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះថាជាមិត្តមែនទែន ហើយគប្បីចូលទៅអង្គុយជិតស្និទ្ធស្នាល ដូចជាមាតានិងបុត្តដែលកើតពីទ្រូង ។ អ្នកប្រាជ្ញបរិបូរណ៍ដោយសីល តែងរុងរឿងដូចជាភ្លើងដែលភ្លឺដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរដូចជាឃ្មុំដូច្នោះឯង ។ ភោគៈទាំងឡាយតែងដល់នូវការពូនជាគំនរ ដូចជាដំបូកដែលកណ្តៀរកពូនដូច្នោះឯង ។ គ្រហស្ថក្នុងត្រកូល បានសន្សំភោគៈទាំងឡាយយ៉ាង

នេះហើយ ទើបអាង(តាំងខ្លួន) ។ កុលបុត្តដែលចែកភោគៈទាំងឡាយជា ៤ ចំណែកគឺ បរិភោគទាំងឡាយ ១ ចំណែក ប្រកបការងារពីរចំណែក ទាំងតម្កល់ទុកនូវចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ (ទៅខាងមុខ) កុលបុត្រនោះឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន[២] ។

## ៨.តួនាទីរបស់មិត្ត

ក្នុងសិង្គាលកសូត្រ ព្រះអង្គត្រាស់ពីតួនាទីរបស់មិត្តចំពោះសិង្គាលកមាណព ថា "ម្នាលគហបតិបុត្ត មិត្តអមាត្យជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ

---

[២] ចំណែកទី ១ បរិភោគប្រើប្រាស់ចាយវាយ ចំណែកទី ២ ទី ៣ ប្រកបការងារ គឺប្រកបកសិកម្ម និងពាណិជ្ជកម្មផ្សេងៗ ចំណែកជាគម្រប់ ៤ ទុកសម្រាប់ការពារអន្តរាយផ្សេងៗ មានអន្តរាយអំពីស្តេចជាដើម ។ ម្យ៉ាងទៀត ឱ្យរំលែកអំពីចំណែកទាំង ៤ នោះ ធ្វើកុសល ឬឱ្យជាថ្លៃគ្រឿងស្លៀកពាក់ និងឈ្នួលកោរកាត់ ។ អដ្ឋកថា ។

៥ យ៉ាង គឺ

១-ទានេន : *ដោយការឲ្យរបស់*

២-បិយវជ្ជេន : *ដោយការនិយាយតែពាក្យគាប់ចិត្ត*

៣-អត្ថចរិយាយ : *ដោយការប្រព្រឹត្តិឲ្យជាប្រយោជន៍*

៤-សមានត្តតាយ : *ដោយការប្រព្រឹត្តិខ្លួនស្មើ*

៥-អវិសំវាទនតាយ : *ដោយការមិនកុហកបញ្ឆោត ។*

*ម្នាលគហបតិបុត្ត មិត្តអមាត្យ ជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងគឺ*

១-បមត្តំ រក្ខន្តិ : *រក្សាមិត្តដែលធ្វេសប្រហែស*

២-បមត្តស្ស សាបតេយ្យំ រក្ខន្តិ : *ជួយថែទាំទ្រព្យសម្បត្តិរបស់មិត្ត ដែលធ្វេសប្រហែស*

៣-ភីតស្ស សរណំ ហោន្តិ : *ជាទីពឹងរបស់មិត្តដែលមានភ័យ*

៤-អាបទាសុ នវិជហន្តិ : *មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ*

៥-អបរាបជំបិស្ស បដិបូជេន្តិ : រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ។

ម្នាលគហបតិបុត្ត មិត្តអមាត្យ ជាទិសខាងជើង ដែលកុលបុត្តត្រូវប្រតិបត្តិដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងនេះ ទិសខាងជើងនុ៎ះដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេមឥតមានភយន្តរាយយ៉ាងនេះ ។

នៅក្នុងមិត្តាមិត្តជាតក ព្រះសាស្តាត្រាស់ថា "អ្នកដែលមិនមែនមិត្ត និងអ្នកដែលជាមិត្ត គប្បីដឹងបានដោយអាការ ៣២ប្រការ" ។

## ៩_មិត្តាមិត្តជាតក

ព្រះសាស្តា កាលស្តេចទ្រង់គង់នៅក្នុងវត្តជេតវនមហាវិហារ ទ្រង់ប្រារព្ធអមាត្យ អ្នកប្រព្រឹត្តប្រយោជន៍របស់ព្រះបាទកោសល ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យចាប់ផ្តើមថា **កានិ កម្មានិ កុព្វានំ** ដូច្នេះ ។

បានឮថា អមាត្យនោះ បានមានឧបការៈចំពោះព្រះរាជាជាច្រើន ព្រះរាជាក៏បានប្រទានសក្ការរាប់រកគេយ៉ាងក្រៃលែង ពួកអមាត្យដ៏សេសអត់ទ្រាំមើលមិនបាន ទើបនាំគ្នាទូលញុះញង់ថា "បពិត្រព្រះអង្គដ៏ចម្រើន អមាត្យឈ្មោះឯណោះ នឹងធ្វើសេចក្ដីវិនាសដល់ព្រះអង្គ" ព្រះរាជាទ្រង់កំណត់ពិចារណាមើលអមាត្យនោះ ក៏មិនឃើញទោសតិចតួចទ្រង់ព្រះតម្រិះថា យើងមិនឃើញទោសតិចតួចរបស់អមាត្យនេះ ធ្វើយ៉ាងណាហ្ន៎ យើងទើបនឹងអាចដឹងថា អមាត្យនេះជាមិត្តឬមិនមែនមិត្ត ទ្រង់គិតថា វៀរព្រះតថាគតចេញហើយអ្នកដទៃមិនអាចដឹងបញ្ហានេះបាន យើងនឹងទៅទូលសួរ លុះសោយព្រះក្រយាហារព្រឹកស្រេចហើយ ក៏ចូលទៅគាល់ព្រះសាស្ដា ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្ដេចហ្ន៎ទើបនឹងអាចដឹងថា អ្នកណាជាមិត្ត ឬមិនមែនមិត្តរបស់ខ្លួន" ។

លំដាប់នោះ ព្រះសាស្ដាត្រាស់ចំពោះព្រះរាជាថា មហាបពិត្រ សូម្បីបណ្ឌិតក្នុងកាលមុន ក៏គិតបញ្ហានេះ ហើយសួរពួកបណ្ឌិត ដឹងបានដោយបណ្ឌិតទាំងនោះប្រាប់ វៀរពួកដែលមិនមែនមិត្តចេញ សេពគប់តែមិត្តប៉ុណ្ណោះ, ព្រះរាជាទូល

អាពាធនាឲ្យទ្រង់សម្ដែងរឿងរ៉ាវ ព្រះអង្គទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅនេះ ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាអមាត្យទូន្មានអត្ថធម៌ចំពោះព្រះរាជា គ្រានោះ ក្នុងព្រះនគរពារាណសី មានអមាត្យម្នាក់ ប្រព្រឹត្តប្រយោជន៍ចំពោះព្រះ-រាជា ពួកអមាត្យដ៏សេសនាំគ្នាទូលញុះញង់ព្រះរាជា ព្រះរាជាទ្រង់មិនឃើញទោសរបស់អមាត្យនោះ ទ្រង់ព្រះតម្រិះថាធ្វើដូចម្ដេចហ្ន៎ យើងទើបនឹងអាចដឹងថាអមាត្យនេះ ជាមិត្តឬមិនមែនមិត្ត កាលនឹងត្រាស់សួរព្រះមហាសត្វ បានត្រាស់ព្រះគាថាទី ១ ថា ៖

បណ្ឌិត អ្នកមានប្រាជ្ញាឃើញ ឬឮ ពួកជនកំពុងធ្វើនូវអំពើអ្វីៗ គប្បីដឹងថា ជាអមិត្តបាន តើវិញ្ញូជនគប្បីព្យាយាម ដូចម្ដេច ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុរសអ្នកជាបណ្ឌិត មានបញ្ញា ឃើញបុរសអ្នកធ្វើការងារអ្វីៗ ដោយចក្ខុបានស្ដាប់រឿងនោះដោយត្រចៀក គប្បីដឹងថា អ្នកនេះមិនមែន

មិត្តរបស់យើង វិញ្ញូជនគប្បីព្យាយាមយ៉ាងណា ដើម្បីស្គាល់អ្នកនោះ ។

លំដាប់នោះ ព្រះមហាសត្វ កាលនឹងត្រាស់ប្រាប់លក្ខណៈរបស់អ្នកដែលមិនមែនមិត្តដល់ព្រះរាជា បានត្រាស់ព្រះគាថាថា ៖

បុគ្គលជាសត្រូវ ឃើញបុគ្គលនោះហើយ មិនញញឹម ១ មិនទទួលត្រេកអរនឹងសំដីបុគ្គលនោះ ១ មិនឲ្យភ្នែកដល់បុគ្គលនោះ ១ ប្រព្រឹត្តទទឹងទាស់ ១ ។

បុគ្គលដែលអែបអបនឹងពួកសត្រូវរបស់បុគ្គលនោះ ១ មិនសេពគប់នឹងពួកមិត្តរបស់បុគ្គលនោះ ១ រារាំងពួកជនអ្នកនិយាយសរសើរ ១ សរសើរពួកជនអ្នកជេរ ១ ។

មិនប្រាប់សេចក្ដីកំបាំងដល់បុគ្គលនោះ ១ មិនលាក់សេចក្ដីកំបាំងរបស់បុគ្គលនោះ ១ មិនសរសើរការងាររបស់បុគ្គលនោះ ១ មិនសរសើរប្រាជ្ញារបស់បុគ្គលនោះ ១ ។

ត្រេកអរនឹងសេចក្ដីវិនាសរបស់បុគ្គលនោះ ១ មិន-ត្រេកអរនឹងសេចក្ដីចម្រើនរបស់បុគ្គលនោះ ១ បានភោជនចំឡែក មិននឹកនាដល់បុគ្គលនោះ ១ មិនអនុគ្រោះបុគ្គលនោះ

*អំពីរបស់នោះថា ឱមិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។*

*បណ្ឌិត ឃើញ ឬឮហើយ ស្គាល់ថាជាអមិត្តបាន ដោយអាការទាំង ១៦ នេះ ដែលតម្កល់នៅក្នុងអមិត្ត ដោយប្រការដូច្នេះ ។*

*ព្រះមហាសត្វត្រាស់ព្រះគាថា ៥ គាថាទាំងនេះហើយ ដែលព្រះរាជាត្រាស់សួរដល់លក្ខណៈរបស់មិត្ត ដោយព្រះ-គាថានេះទៀតថា ៖*

*បណ្ឌិតអ្នកមានប្រាជ្ញា ឃើញ ឬឮ ពួកជនកំពុងធ្វើការងារអ្វីៗ គប្បីដឹងថា ជាមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្តេច ។*

*(ព្រះមហាសត្វ) ទើបត្រាស់គាថាដែលនៅសល់ថា ៖*

*បុគ្គលជាមិត្ត តែងនឹករលឹកដល់មិត្តដែលនៅបែកគ្នា ១ ត្រេកអរនឹងមិត្តដែលមកដល់ ១ ជាអ្នករាប់អានចំពោះមិត្តនោះ ១ ទទួលរីករាយដោយវាចា ១ ។*

*គប់រកនឹងពួកមិត្តរបស់មិត្តនោះ ១ មិនសេពគប់នឹងពួកអមិត្តរបស់មិត្តនោះ ១ ហាមឃាត់នូវពួកអ្នកជេរ ១ សរសើរពួកជនដែលនិយាយសរសើរ ១ ។*

ប្រាប់សេចក្តីកំបាំងដល់មិត្តនោះ ១ បិទបាំងសេចក្តីកំបាំងរបស់មិត្តនោះ ១ សរសើរការងាររបស់មិត្តនោះ ១ សរសើរប្រាជ្ញារបស់មិត្តនោះ ១ ។

ត្រេកអរនឹងសេចក្តីចម្រើនរបស់មិត្តនោះ ១ មិនត្រេកអរនឹងសេចក្តីវិនាសរបស់មិត្តនោះ ១ បានភោជនចំណែកតែងនឹកនាដល់មិត្តនោះ ១ អនុគ្រោះមិត្តនោះអំពីរបស់នោះថា ឱមិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

បណ្ឌិតឃើញ ឬឮហើយ ស្គាល់ថាជាមិត្ត ដោយអាការទាំង ១៦ នេះ ដែលតម្កល់នៅក្នុងមិត្ត ដោយបការៈដូច្នេះ ។

ព្រះរាជា មានព្រះទ័យសរសើរពាក្យរបស់ព្រះមហាសត្វបានព្រះរាជទានយសដ៏ធំក្រៃលែងដល់ព្រះមហាសត្វហើយ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកហើយត្រាស់ថា មហាបពិត្រ បញ្ហានេះបានតាំងឡើងស្ងប់ក្នុងកាលមុនយ៉ាងនេះ បណ្ឌិតទាំងឡាយពោលដល់បញ្ហានេះថា អ្នកដែលមិនមែនមិត្ត និងអ្នកដែលជាមិត្ត នឹងគប្បីដឹងបានដោយអាការ ៣២ ទាំងនេះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជា

ក្នុងកាលនោះ បានមកជាព្រះអានន្ទ ចំណែកអមាត្យដែលជា
បណ្ឌិត បានមកជាយើងតថាគតនេះឯង ។

ចប់ អដ្ឋកថា មិត្តាមិត្តជាតក ។

## ១០~ព្រះគាថាក្នុងគោសម្ពិកក្ខន្ធកៈ

*(វិនយបិដក ភាគ៨ ទំព័រ៣៤៥)*

សចេ លភេថ និបកំ សហាយំ
សទ្ធិញ្ចរំ សាធុវិហារិធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។

បើបុគ្គលបានសម្លាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា បុគ្គលនោះ អាចគ្របសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្តីត្រេកអរ មានស្មារតី គប្បីត្រាច់-ទៅជាមួយនឹងសម្លាញ់នោះចុះ ។

នោ ចេ លភេថ និបកំ សហាយំ
សទ្ធិញ្ចរំ សាធុវិហារិធីរំ

រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

*បើបុគ្គលមិនបានសម្លាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះ គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្ដេចលះបង់ដែនដែលខ្លួនឈ្នះហើយ ត្រាច់ទៅតែម្នាក់ឯង (ពុំនោះសោត) ប្រៀបដូចជាស្ដេចដំរីដ៏ប្រសើរ ត្រាច់ទៅម្នាក់ឯងក្នុងព្រៃ ។*

ឯកស្ស ចរិតំ សេយ្យោ
នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

*កាលដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាល គ្មានសហាយតាគុណទេ[៣], ម្យ៉ាងទៀត*

---

៣ អដ្ឋកថាធម្មបទថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ហៅថាសហាយតាគុណ ។

បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរីដ៏ប្រសើរ មានសេចក្ដីខ្វល់ខ្វាយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

<u>ក្នុងអដ្ឋកថា សមន្តប្បាសាទិកា ពន្យល់ថា</u> ៖

បាទគាថាថា សចេ លភេថ និបកំ សហាយំ (បើបុគ្គលបានសម្លាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន) ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្ដែងគុណនៃសម្លាញ់ដែលជាបណ្ឌិត និងទោសនៃសម្លាញ់ដែលជាពាល ។

បាទគាថាថា អភិភុយ្យ សព្វានិ បរិស្សយានិ (បុគ្គលនោះ អាចគ្របសង្កត់នូវសេចក្ដីអន្តរាយទាំងពួងបាន) មានសេចក្ដីថា គប្បីញាំញីអន្តរាយដែលប្រាកដ និងអន្តរាយដែលលាក់កំបាំងចេញ មានចិត្តរីករាយជាមួយនឹងសម្លាញ់នោះ មានសតិត្រាច់ទៅ ។

ត្រើនបទថា រាជាវ រដ្ឋំ វិជិតំ (ប្រៀបដូចជាស្ដេច (លះបង់)នូវដែនដែលខ្លួនឈ្នះហើយ) មានសេចក្ដីថា ព្រះរាជាទ្រង់ព្រះនាមថា មហាជនក និងព្រះមហារាជាទ្រង់ព្រះនាមថា

*អវិន្ទម: ទ្រង់លះព្រំដែន គឺដែនដីជាទីត្រេកអររបស់ព្រះអង្គ ចេញ ត្រាច់ទៅតែម្នាក់ឯងយ៉ាងណា, គប្បីត្រាច់ទៅដូច្នោះ ។*

*ពីរបទថា* មាតង្គរញ្ញេវ នាគោ *(ដំរីដ៏ប្រសើរក្នុងព្រៃ) មានសេចក្តីថា ដូចជាដំរីដ៏ប្រសើរលះហ្វូង ត្រាច់ទៅក្នុងព្រៃ ។*

*សត្វមានប្រមោយ ហៅថា ដំរី ។*

*ពាក្យថា* នាគ *នេះ ជាឈ្មោះនៃអ្នកដ៏ប្រសើរ ។ មានពាក្យអធិប្បាយថា ប្រៀបដូចជាដំរីដ៏ប្រសើរដែលចិញ្ចឹមមាតា ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង ។ ទាំងមិនបានធ្វើបាបទាំងឡាយ យ៉ាងណា; មួយទៀត ដំរីបារិលេយ្យកៈ ត្រាច់ទៅក្នុងព្រៃ តែម្នាក់ឯង, ទាំងមិនបានធ្វើបាបទាំងឡាយយ៉ាងណា; បុគ្គល គប្បីត្រាច់ទៅតែម្នាក់ឯង, ទាំងមិនគប្បីធ្វើបាបទាំងឡាយ ក៏យ៉ាងនោះដែរ ។*

*<u>ព្រោះហេតុនោះ</u> បុគ្គលបានដឹង គុណនៃសម្លាញ់ដែលជាបណ្ឌិត និងទោសនៃសម្លាញ់ដែលជាពាលហើយ គប្បីសេពគប់តែនឹងសម្លាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញចុះ ។*

ឥឡូវនេះ សូមពុទ្ធបរិស័ទសិក្សានូវព្រះសូត្រ ដែលជាប់ទាក់ទងនឹងមិត្តល្អ តទៅទៀត ៖

## ១១-បឋមសខាសូត្រ

(សុត្តន្តបិដក លេខ៤៧ ទំព័រ៥៩)

ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការ គួរសេពគប់ ។ ប្រកបដោយអង្គ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺមិត្តឲ្យនូវរបស់ដែលគេឲ្យបានដោយកម្រ ១ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ១ អត់ធន់ចំពោះហេតុដែលគេអត់ធន់បានដោយកម្រ ១ បើកបង្ហាញសេចក្តីកំបាំងរបស់ខ្លួនដល់គ្នា ១ បិទសេចក្តីកំបាំងរបស់គ្នា ១ មិនលះគ្នាក្នុងគ្រាមានសេចក្តីអន្តរាយ ១ មិនមើលងាយគ្នា ព្រោះអស់ភោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយអង្គ ៧ ប្រការនេះឯង គួរសេពគប់ ។

មិត្តឲ្យនូវរបស់ដែលគេឲ្យបានដោយកម្រផង ធ្វើនូវអំពើ
ដែលគេធ្វើបានដោយកម្រផង មួយទៀត អត់ធន់ចំពោះ

ពាក្យដែលពោលអាក្រក់ និងហេតុអត់ធន់បានដោយកម្រផង ប្រាប់សេចក្ដីកំបាំងរបស់ខ្លួនដល់គ្នាផង បិទសេចក្ដីកំបាំងរបស់គ្នាផង មិនលះគ្នាក្នុងគ្រាមានសេចក្ដីអន្តរាយផង មិនមើលងាយគ្នា ព្រោះអស់ភោគៈផង ហេតុទាំងនេះ មានក្នុងបុគ្គលណា ក្នុងលោកនេះ បុគ្គលមានសភាពដូច្នោះនោះ ហៅថា មិត្ត ជនអ្នកមានប្រាជ្ញានូវមិត្ត គប្បីសេពគប់ ។

<u>នៅក្នុងអដ្ឋកថា មនោរថបូរណី លោកពន្យល់ថា</u> ៖

បទថា ទុទ្ទំ វត្ថុមានតម្លៃច្រើន ដែលលះបង់បានកម្រ ។ បទថា ទុក្ករំ ករោតិ សេចក្ដីថា រមែងធ្វើកិច្ចកម្មដែលធ្វើមិនបានងាយៗ ។ បទថា ទុក្ខមំ ខមតិ សេចក្ដីថា រមែងអត់ទ្រាំបានយ៉ាងកម្រ ដើម្បីប្រយោជន៍ដល់សម្លាញ់ ។ បទថា គុយ្ហមស្ស អាវិករោតិ មានសេចក្ដីថា រមែងបើកបង្ហាញសេចក្ដីកំបាំងរបស់ខ្លួនដល់សម្លាញ់នោះ ។ បទថា គុយ្ហមស្ស បរិគូហាតិ សេចក្ដីថា មិនប្រាប់សេចក្ដីកំបាំងរបស់សម្លាញ់នោះដល់ពួកអ្នកដទៃ ។ បទថា ឱណោឆ ជាតិ-

មញ្ញតិ បានដល់ កាលភោគសម្បត្តិរបស់សម្លាញ់នោះ អស់ទៅហើយ ក៏មិនមើលងាយសម្លាញ់នោះ ព្រោះសេចក្តីសាបសូន្យអស់នោះ គឺមិនធ្វើការជាន់ឈ្លី និងមើលងាយក្នុងខ្លួនសម្លាញ់នោះ ។

## ១២_ទុតិយសខាសូត្រ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៧ ប្រការ បុគ្គលអ្នកស្វែងមិត្ត ទោះបីលោកបណ្តេញបំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រក ចូលទៅអង្គុយជិត ។ ប្រកបដោយអង្គ ៧ ប្រការ តើដូចម្តេចខ្លះ ។ ភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ និងជាទីគាប់ចិត្ត ១ គួរគោរព ១ គួរសរសើរ ១ ឧស្សាហ៍ប្រៀនប្រដៅ ១ អត់ធន់ចំពោះពាក្យ ១ ជាអ្នកនិយាយពាក្យជ្រៅ ១ មិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការនេះឯង បុគ្គលអ្នកស្វែងរកមិត្ត បើទុកជាលោកបណ្តេញ បំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រក ចូលទៅអង្គុយជិត ។

បិយោ គរុ ភាវនីយោ វត្តា ច វចនក្ខមោ
គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ,
យស្មឹ ឯតានិ ឋានានិ សំវិជ្ជន្តីធ បុគ្គលេ
សោ មិត្តោ មិត្តកាមេន អត្ថកាមានុកម្បកោ
អបិ នាសិយមានេន ភជិតព្វោ តថាវិធោ ។

*ភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង មិនដឹកនាំក្នុងហេតុដែលមិនគួរផង, ហេតុទាំងនេះ មានក្នុងបុគ្គលណា ក្នុងលោកនេះ បុគ្គលជាអ្នកប្រាថ្នានូវប្រយោជន៍ អ្នកធ្វើនូវសេចក្តីអនុគ្រោះ មានសភាពដូច្នោះនោះ ឈ្មោះថា ជាមិត្ត បុគ្គលអ្នកមានសេចក្តីត្រូវការដោយមិត្ត ទោះបីជាលោកធ្វើឲ្យវិនាស ក៏គួរតែតាមសេពគប់ ។ (បិដក ៤៧, ៦០)*

*នៅក្នុងអដ្ឋកថា មនោរថបូរណី លោកពន្យល់ថា ៖*

*បទថា វត្តា បានដល់ អ្នកឆ្លាតក្នុងពាក្យ ។*

បទថា វចនក្ខមោ មានសេចក្តីថា ភិក្ខុមែងអត់ធន់ពាក្យសម្តី គឺធ្វើតាមឱវាទដែលលោកឲ្យ ។ បទថា គម្ភីរំ បានដល់ ពាក្យដែលបិទបាំង ជ្រាលជ្រៅ ដែលអាស្រ័យឈាន អាស្រ័យវិបស្សនា មគ្គផល និងនិព្វាន ។

## ១៣_ទុតិយសេក្ខសូត្រ

(សុត្តន្តបិដក លេខ៥៣ ទំព័រ១៥)

ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុជាសេក្ខៈ មិនទាន់សម្រេចអរហត្តផលនៅឡើយ ហើយប្រាថ្នាធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ម្នាលភិក្ខុទាំង-ឡាយ តថាគតធ្វើបច្ច័យខាងក្រៅឲ្យជាហេតុហើយ មិនឃើញហេតុដទៃ សូម្បីតែហេតុមួយ ដែលមានឧបការៈច្រើនយ៉ាងនេះឲ្យដូចជាភាពនៃបុគ្គលមានកល្យាណមិត្តនេះឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត ទើបលះបង់អកុសល ចម្រើនកុសលបាន ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែង

សេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

កល្យាណមិត្តោ យោ ភិក្ខុ សប្បតិស្សោ សគារវោ
ករំ មិត្តានំ វចនំ សម្បជានោ បតិស្សតោ
ចាបុណោ អនុបុព្វេន សព្វសំយោជនក្ខយំ ។

ភិក្ខុណាមានកល្យាណមិត្ត មានសេចក្តីកោតក្រែង ប្រកបដោយសេចក្តីគោរព ធ្វើតាមពាក្យរបស់កល្យាណមិត្ត ជាអ្នកមានសេចក្តីដឹងខ្លួន មានស្មារតី ភិក្ខុនោះទើបគួរដល់នូវកិរិយាអស់នូវសំយោជនៈទាំងពួង ដោយលំដាប់បាន ។

នៅក្នុងអដ្ឋកថា បរមត្ថទីបនី ពន្យល់ថា ៖

បទថា ពាហិរំ បានដល់ ហេតុដែលមានខាងក្រៅអំពីសន្តានខាងក្នុង ។ បទថា កល្យាណមិត្តតា បានដល់ បុគ្គលដែលបរិបូរណ៍ដោយគុណមានសីលជាដើម ជាអ្នកកម្ចាត់សេចក្តីអាក្រក់ ជាអ្នកគាំទ្រប្រយោជន៍ ជាមិត្តមានឧបការៈគ្រប់វត្ថុគ្រប់យ៉ាង ឈ្មោះថា ជាកល្យាណមិត្ត ។ ភាពជាកល្យាណមិត្តនោះ ឈ្មោះថា កល្យាណមិត្តតា ។

ក្នុងបទថា កល្យាណមិត្តតា នោះ មានអធិប្បាយដូចនេះ តាមប្រក្រតីកល្យាណមិត្តនេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល សុតៈ ចាគ វីរិយ សតិ សមាធិ និងបញ្ញា កល្យាណមិត្ត ព្រោះដល់ព្រមដោយសទ្ធា រមែងជឿការត្រាស់ដឹងរបស់ព្រះតថាគត រមែងមិនលះបង់ការស្វែងរកប្រយោជន៍សុខ ក្នុងសត្វទាំងឡាយដែលកើតឡើង ព្រោះហេតុនៃការត្រាស់ដឹងដ៏ប្រពៃនោះ, ព្រោះដល់ព្រមដោយសីល ទើបរមែងជាទីស្រឡាញ់ និងជាទីគោរពរបស់មិត្តព្រហ្មចារីទាំង-ឡាយ ជាអ្នកគួរលើកតម្កើង ចាំដាស់តឿន ក្រើនរំលឹកតិះដៀលបាប ចាំទូន្មាន អត់ធន់ពាក្យសំដី, ព្រោះដល់ព្រមដោយសុតៈ ទើបជាអ្នកពោលពាក្យដែលជ្រាលជ្រៅ មានខន្ធ អាយតនៈ សច្ចៈ បដិច្ចសមុប្បាទ ជាដើម, ព្រោះដល់ព្រមដោយចាគៈ ទើបជាអ្នកមានសេចក្ដីប្រាថ្នាតិច ជាអ្នកសន្ដោស មានសេចក្ដីស្ងប់ស្ងាត់ មិនជាប់ជំពាក់ (ដោយពួក), ព្រោះដល់ព្រមដោយវីរិយ ទើបជាអ្នកប្រឹងប្រែង ព្យាយាមក្នុងការបដិបត្តិ (ជា) ប្រយោជន៍ដល់ខ្លួន និងអ្នកដទៃ, ព្រោះដល់ព្រម

ដោយសតិ ទើបជាអ្នកមានសតិខ្ជាប់ខ្ជួន ជាអ្នកដល់ព្រមដោយសេចក្តីហ្មត់ចត់ គឺសតិយ៉ាងក្រៃលែង ជាអ្នករលឹកបាន ចាំបានសូម្បីវត្ថុដែលធ្វើ សូម្បីពាក្យដែលនិយាយយូរមក ហើយ, ព្រោះដល់ព្រមដោយសមាធិ ទើបជាអ្នកមិនរាយមាយ ជាអ្នកមាំទាំ មានចិត្តរឹងប៉ឹង, និងព្រោះដល់ព្រមដោយបញ្ញា ទើបរមែងដឹងវត្ថុដែលមិនវិបរិត ។ កល្យាណមិត្តនោះ ស្វែងរកគតិធម៌ទាំងដែលជាកុសល និងអកុសលដោយសតិ ដឹងប្រយោជន៍សុខរបស់សត្វទាំងឡាយ តាមសេចក្តីពិតដោយបញ្ញា ជាអ្នកមានចិត្តមិនរាយមាយក្នុងអារម្មណ៍នោះ ដោយសមាធិ ទូន្មានសត្វទាំងឡាយចាកវត្ថុមិនជាប្រយោជន៍ ដោយសេចក្តីព្យាយាម រមែងបបួលក្នុងវត្ថុដែលមានប្រយោជន៍តែម៉្យាង ។ ដូចព្រះមានព្រះភាគ ត្រាស់ទុកថា ៖

ភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ គួរគោរព គួរសរសើរ ឧស្សាហ៍ប្រៀនប្រដៅ អត់ធន់ចំពោះពាក្យសំដី ជាអ្នកនិយាយពាក្យជ្រាលជ្រៅ ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាកល្យាណមិត្ត រមែង លះអកុសល ចម្រើនកុសល ព្រោះហេតុនោះ បុគ្គលជា កល្យាណមិត្ត អាស្រ័យភិក្ខុជាកល្យាណមិត្ត ញ៉ាំងកម្ម-ស្សកតាញាណឲ្យកើត រមែងធ្វើសទ្ធាដែលកើតឡើងហើយឲ្យ គង់វង់ កើតសទ្ធាហើយក៏ចូលទៅរក គ្រាចូលទៅរកហើយ រមែងស្តាប់ធម៌ គ្រាស្តាប់ធម៌នោះហើយ រមែងបានសទ្ធាក្នុង ព្រះតថាគត ដោយការបានសទ្ធានោះ ទើបលះបង់ការនៅគ្រប់ គ្រងផ្ទះ ចេញបួសធ្វើបារិសុទ្ធិសីល ៤ ឲ្យដល់ព្រម សមាទាន ធុតធម៌ (ធម៌ដែលកំចាត់កិលេស) ប្រព្រឹត្តទៅតាមកម្លាំង ជា អ្នកបានកថាវត្ថុ ១០ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ចូលទៅ តាំងសតិទុក មានសម្បជញ្ញៈ ចម្រើនពោធិបក្ខិយធម៌រហូត មួយយប់ទល់ភ្លឺ មិនយូរឡើយធ្វើវិបស្សនា អាចកាត់ផ្តាច់អកុ-សលទាំងអស់ ដោយការសម្រេចអរិយមគ្គ និងញ៉ាំងកុសល-ធម៌ទាំងពួងឲ្យចម្រើន ដល់សេចក្តីបរិបូរណ៍ដោយភាវនា ។ សមដូចព្រះមានព្រះភាគ ត្រាស់ទុកថា “ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ មាន

សម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានសីលសង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូរណ៍ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ" ។ គុណជាតនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ ។ល។ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានកថាផូរផង់ ជាទីសប្បាយទូលាយចិត្ត ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយតែម៉្យាង ដើម្បីនិព្វាន ។ ហើយពោលនូវកថាមានសភាពយ៉ាងនេះ គឺ

១.អប្បិច្ឆកថា ពោលពាក្យនាំឲ្យមានសេចក្ដីប្រាថ្នាតិច

២.សន្តុដ្ឋិកថា ពោលពាក្យដែលដឹកនាំឲ្យសន្ដោស

៣.បវិវេកកថា ពោលពាក្យដែលដឹកនាំឲ្យស្ងៀត

៤.អសំសគ្គកថា ពោលពាក្យដែលដឹកនាំមិនឲ្យ
ប្រទ្បូកប្រទ្បំដោយពួក

៥.វិរិយារម្ភកថា ពោលពាក្យដែលដឹកនាំឲ្យប្រារព្ធ

សេចក្តីព្យាយាម

៦. សីលកថា ពោលពាក្យដែលដឹកនាំឲ្យតាំងនៅក្នុងសីល

៧. សមាធិកថា ពោលពាក្យដែលដឹកនាំឲ្យធ្វើចិត្តឲ្យស្ងប់

៨. បញ្ញាកថា ពោលពាក្យដែលដឹកនាំឲ្យកើតបញ្ញា

៩. វិមុត្តិកថា ពោលពាក្យដែលដឹកនាំធ្វើចិត្តឲ្យផុតចាកកិលេស

១០. វិមុត្តិញ្ញាណទស្សនកថា ពោលពាក្យដែលដឹកនាំឲ្យកើតសេចក្តីដឹង សេចក្តីឃើញក្នុងការផុតចាកកិលេស ។

ដោយកថាមានសភាពបែបនេះ ភិក្ខុនឹងបានតាមប្រាថ្នា បានដោយងាយ បានដោយមិនលំបាក ។ ពាក្យដែលភិក្ខុមានមិត្តល្អ ។ល។ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះអកុសលធម៌ទាំងឡាយ ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ។

សេចក្ដីដែលភិក្ខុមានមិត្តល្អ ។ល។ បែរទៅរកមិត្តល្អ នឹងជាអ្នកមានបញ្ញា នឹងជាអ្នកប្រកបដោយឧទយត្ថគាមិនីបញ្ញា (ដឹងសេចក្ដីកើតនិងសេចក្ដីសាបសូន្យ) ដើម្បីឲ្យដល់សេចក្ដីអស់ទុក្ខដោយប្រពៃ ដែលជាការត្រាស់ដឹងយ៉ាងប្រសើរ គប្បីជ្រាបនិមិត្ត គឺការរួចផុតចាកវដ្ដទុក្ខទាំងអស់ថា កល្យាណមិត្តតា យ៉ាងនេះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យមានជាអាទិថា "ម្នាលអានន្ទ ព្រោះអាស្រ័យតថាគតដែលជាកល្យាណមិត្ត បានជាពួកសត្វដែលមានជាតិជាធម្មតា មានជរាជាធម្មតា រមែងរួចស្រឡះចាកជាតិជរាទៅបាន" ។ សមដូចព្រះមានព្រះភាគ ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាកល្យាណមិត្ត រមែងលះអកុសល ចម្រើនកុសល ដូច្នេះ ។

គប្បីជ្រាបសេចក្ដីនៃគាថាតទៅនេះ ៖

បទថា សប្បតិស្សោ ឈ្មោះថា សប្បតិស្សោ ព្រោះប្រព្រឹត្តទៅមួយអន្ទើដោយសេចក្ដីកោតក្រែង គឺការទទួលស្ដាប់ ។ ជាអ្នកបង្អោនទទួលឱវាទនៃកល្យាណមិត្ត ។ អធិ-

ប្បាយថា ជាអ្នកប្រដៅងាយ ។ម្យ៉ាងទៀត អ្នកឲ្យឱវាទ ឈ្មោះបតិស្សៈ ព្រោះប្រាថ្នាឲ្យកើតប្រយោជន៍សុខ ។ ឈ្មោះ សប្បតិស្សៈ ព្រោះប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីប្រាថ្នា នោះ ប្រកបដោយសេចក្ដីគោរព និងសេចក្ដីអើពើ ។ ច្រើន ដោយសេចក្ដីគោរពកោតក្រែងក្នុងគ្រូ ។ បទថា សគារវោ បានដល់ ប្រកបដោយគារវធម៌ ៦ យ៉ាង ។ បទថា ករំ មិត្តានំ វចនំ បានដល់ ធ្វើតាមឱវាទ គឺបដិបត្តិតាមឱវាទ នៃកល្យាណមិត្តទាំងឡាយ ។ បទថា សម្បជានោ បានដល់ ប្រកបដោយសម្បជញ្ញៈ ៧ យ៉ាង ។ បទថា បតិស្សតោ បានដល់ មានសតិ គឺធ្វើយ៉ាងមានសតិ ដោយសតិដែលអាច ឲ្យកើតសេចក្ដីមាំទាំរបស់កម្មដ្ឋានបាន ។ បទថា អនុបុព្វេន បានដល់ ដោយលំដាប់នៃសីលវិសុទ្ធិជាដើម គឺដោយលំដាប់ នៃវិបស្សនា និងលំដាប់នៃមគ្គក្នុងសីលវិសុទ្ធិជាដើមនោះ ។ បទថា សព្វសំយោជនក្ខយំ សេចក្ដីថា គប្បីដល់ គឺគប្បី សម្រេចព្រះនិព្វានដែលជាអារម្មណ៍នៃព្រះអរហត្ត ដែលជាទី

បំផុតពោលគឺ សេចក្តីអស់ទៅនៃសំយោជនៈទាំងពួង ព្រោះសំយោជនទាំងអស់មានកាមរាគសំយោជនៈជាដើមអស់ទៅ ។

ក្នុងសូត្រទាំង ២ នេះ គប្បីជ្រាបថា ព្រះសាស្តាទ្រង់សំដៅយកអត្ថនៃសេចក្តីព្យាយាម របស់ការសម្រេចអរិយមគ្គ ដោយប្រការដូច្នេះ ។

## ១៤_ការមានមិត្តល្អជាព្រហ្មចរិយធម៌ទាំងមូល

(សុត្តន្តបិដក លេខ៣៧ ទំព័រ៣-៥)

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសក្ករនិគមរបស់ពួកសក្យៈ ក្នុងដែនសក្យៈ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គុណជាតឯណា គឺការមានមិត្តល្អ មានសម្លាញ់ល្អ និងការមានក្លើល្អ គុណជាតនេះ ចាត់ជាពាក់

កណ្តាលនៃព្រហ្មចរិយធម៌ ។ (ព្រះអង្គត្រាស់ថា)

ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ គុណជាតឯណា គឺការមានមិត្តល្អ មានសម្លាញ់ល្អ និងការមានក្លើល្អ គុណជាតនេះឯង ចាត់ជាព្រហ្មចរិយធម៌ទាំងមូល ។ ម្នាលអានន្ទ ព្រហ្មចរិយធម៌នេះឯង ប្រាកដដល់ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានក្លើល្អ នឹងចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។

ម្នាលអានន្ទ ចុះភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានក្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចម្រើននូវសម្មាសង្កប្បៈ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ។បេ។ ចម្រើននូវសម្មាវាចា ។បេ។ ចម្រើននូវ

សម្មាកម្មន្តៈ ។បេ។ ចម្រើននូវសម្មាអាជីវៈ ។បេ។ ចម្រើននូវសម្មាវាយាមៈ ។បេ។ ចម្រើននូវសម្មាសតិ ។បេ។ ចម្រើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលអានន្ទ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានក្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។

ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និងការមានក្លើល្អ ។ ម្នាលអានន្ទ ព្រោះអាស្រ័យតថាគតដែលជាមិត្តល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចស្រឡះចាកមរណៈទៅបាន ពួកសត្វដែលមានសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និង

សេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនុ៎ះដោយ បរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមាន មិត្តល្អ ការមានសម្លាញ់ល្អ និងការមានក្លើល្អ ។

## ១៥_បឋមសុរិយូបមសូត្រ

នៅក្នុងគិលានវគ្គ បឋមសុរិយូបមសូត្រ សុត្តន្តបិដក លេខ៣៧ ឃ្នាប៤១១ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃព្រះអរុណនុ៎ះឯង ជា ប្រធាន ជាបុព្វនិមិត្តនៃព្រះអាទិត្យដែលកើតឡើង (យ៉ាងណា) ភាវៈនៃកល្យាណមិត្តនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្ត នៃការ ញុំាងពោជ្ឈង្គទាំង៧ ឲ្យកើតឡើងដល់ភិក្ខុ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះភិក្ខុដែលចម្រើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ (នោះ) គួរប្រាថ្នានូវភិក្ខុ ដែលជាកល្យាណមិត្ត (កុំខាន) ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានកល្យាណមិត្ត រមែង ចម្រើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសតិ-សម្ពោជ្ឈង្គ អាស្រ័យសេចក្តីស្ងប់ស្ងាត់ ។បេ។ ចម្រើន ឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យ ការប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ ដែលទន់ទោរទៅ រកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត តែងចម្រើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

## ១៦_មេឃិយសូត្រ

(សុត្តន្តបិដក លេខ៥២ ទំព័រ១៩៧)

ព្រះមានព្រះភាគត្រាស់ថា ម្នាលមេឃិយៈ ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លា ឲ្យចាស់ ក្លាបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ បែរទៅរកមិត្តល្អ ។

ម្នាលមេឃិយៈ នេះជាធម៌ទី ១ ប្រព្រឹត្តទៅដើម្បីធ្វើចេតោ-វិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខ បរិបូរណ៍ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ ទី ២ ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវកថាមានសភាពយ៉ាងនេះ គឺ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេក-កថា អសំសគ្គកថា វិរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ដែលជាកថាផូរផង់ ជាទីសប្បាយទូលាយចិត្ត ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះ-និព្វាន ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ

ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លា ឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះអកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ទាំងឡាយឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុមានបញ្ញា ប្រកបដោយបញ្ញាជាគ្រឿងដឹងការកើតឡើង និងសូន្យទៅ ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយកិលេស ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លា ឲ្យចាស់ក្លាបាន ។

ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុ ដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានសីល សង្រួមហើយដោយការសង្រួម ក្នុងបាតិមោក្ខសំវរៈ បរិបូរណ៍ដោយអាចារៈនិងគោចរៈ ជាអ្នក

ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ គុណជាតទី៤ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកបានតាមប្រាថ្នា បាន ដោយមិនលំបាក បានដោយងាយនូវកថាមានសភាពយ៉ាងនេះ គឺ អប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញ្ញាណទស្សនកថា ១ ដែលជាកថាជូរផង់ ជាទីសប្បាយទូលាយចិត្ត ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយ ណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បី ស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលមេឃិយៈ គុណជាតទី៤ រមែងកើតប្រាកដដល់ភិក្ខុដែល មានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះអកុសលធម៌ទាំងឡាយ ដើម្បី ញ៉ាំងកុសលធម៌ទាំងឡាយឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំង

ឡាយ ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាជាគ្រឿង ដឹងការកើតឡើង និងសូន្យទៅ ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿង ទំលុះទំលាយកិលេស ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ។

ម្នាលមេឃិយៈ មួយទៀត ភិក្ខុនោះ តាំងនៅក្នុងធម៌ ៥ យ៉ាងនេះហើយ ត្រូវចម្រើនធម៌ ៤ យ៉ាងតទៅទៀត គឺចម្រើន អសុភ ដើម្បីលះរាគៈ ១ ចម្រើនមេត្តា ដើម្បីលះព្យាបាទ ១ ចម្រើនអានាបានស្សតិ ដើម្បីផ្តាច់បង់វិតក្កៈ ១ ចម្រើនអនិច្ច-សញ្ញា ដើម្បីដកអស្មិមានះ ១ ។ ម្នាលមេឃិយៈ ព្រោះថា កាលភិក្ខុមានសេចក្តីសម្គាល់ថា មិនទៀងហើយ សេចក្តី សម្គាល់ថាមិនមែនខ្លួន រមែងតាំងនៅ (ក្នុងចិត្ត) ភិក្ខុដែលមាន សេចក្តីសម្គាល់ថាមិនមែនខ្លួន រមែងដល់នូវការដកអស្មិមានះ ឈ្មោះថា ដល់និព្វានក្នុងបច្ចុប្បន្ន ។

លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ, ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

វិតក្កៈទាំងឡាយដ៏ថោកទាប វិតក្កៈទាំងឡាយដ៏ល្អិត ដែលចិត្តប្រព្រឹត្តទៅតាមហើយ ធ្វើចិត្តឲ្យធ្មេងកន្ត្រេង បុគ្គល មិនដឹងច្បាស់សេចក្តីត្រិះរិះនៃចិត្តទាំងនុ៎ះទេ ជាអ្នកមានចិត្ត ភ្ញាក់ផ្អើល ស្ទុះទៅស្ទុះមកកាន់អារម្មណ៍ផ្សេងៗ ។ ឯអ្នកប្រាជ្ញ ដឹងច្បាស់សេចក្តីត្រិះរិះនៃចិត្តទាំងនុ៎ះហើយ ជាអ្នកមានព្យា-យាម ជាគ្រឿងដុតបំផ្លាញកិលេស មានស្មារតី បិទខ្ទប់វិតក្កៈទាំងឡាយ ដែលចិត្តប្រព្រឹត្តទៅតាមហើយ ធ្វើចិត្តឲ្យធ្មេងកន្ត្រេង លះបង់វិតក្កៈទាំងនុ៎ះ មិនឲ្យសេសសល់ ។

<u>ក្នុងអដ្ឋកថាបរមត្ថទីបនី ពន្យល់ថា</u> ៖

ព្រះមានព្រះភាគ កាលទឹងទ្រង់សម្តែងធម៌ដែលជាសប្បាយដល់ព្រះមេឃិយៈ ទើបត្រាស់ពាក្យមានជាដើមថា ម្នាលមេឃិយៈ ចេតោវិមុត្តិនៅមិនទាន់ចាស់ក្លា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អបរិបក្កាយ ប្រែថា មិនទាន់ដល់សេចក្តីចាស់ក្លា ។ បទថា ចេតោវិមុត្តិយា បានដល់ចិត្តរួចផុតចាកកិលេស ។ ពិតមែន ក្នុងខាងដើម ចិត្តរមែងរួចផុតចាកកិលេស ដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ខាងក្រោយ

រមែងរួចផុតដោយសមុច្ឆេទវិមុត្តិ និងបដិបស្សទ្ធិវិមុត្តិ ។

ក៏វិមុត្តិនេះនោះ ខ្ញុំពោលទុកពិស្តារហើយក្នុងកាលក្រោយនោះឯង ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយក្នុងអធិការដែលពោលអំពីវិមុត្តិនោះ ។ ក្នុងសេចក្តីនោះ កាលលោកអប់រំ គឺក្រោកឡើងក្នុងអធ្យាស្រ័យឲ្យភ្ញាក់ដោយធម៌ ដែលជាគ្រឿងអប់រំវិមុត្តិ កាលវិបស្សនាកាន់យកបន្ទប់ មគ្គដល់សេចក្តីចាស់ក្លា ចេតោវិមុត្តិ ឈ្មោះថាជាការចាស់ក្លា កាលវិបស្សនាមិនទាន់កាន់យកបន្ទប់ មគ្គ ឈ្មោះថាមិនទាន់ចាស់ក្លា ។ ក៏ធម៌ជាគ្រឿងអប់រំវិមុត្តិ ដូចម្តេច ? គឺគប្បីជ្រាបធម៌ ១៥ យ៉ាង ដោយធ្វើសទ្ធិន្ទ្រិយជាដើមឲ្យបរិសុទ្ធ ។ សមពិតដូចដែលលោកពោលទុកថា ៖

កាលវៀរបុគ្គលដែលមិនមានសទ្ធា, កាលសេពគប់ចូលទៅអង្គុយជិតបុគ្គលដែលមានសទ្ធា, ពិចារណាព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា, សទ្ធិន្ទ្រិយរមែងបរិសុទ្ធដោយអាការទាំង ៣ នេះ ។

កាលវៀរបុគ្គលដែលខ្ជិលច្រអូស, កាលសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលប្រារព្ធសេចក្តីព្យាយាម ពិចារណា

សម្មប្បធាន វីរិយិន្ទ្រិយ រមែងបរិសុទ្ធដោយអាការទាំង៣ នេះ ។

កាលវៀរបុគ្គលដែលវង្វេងភ្លេចសតិ កាលសេពគប់ចូលទៅអង្គុយជិតបុគ្គលដែលមានសតិតាំងមាំ ពិចារណាសតិប្បដ្ឋាន សតិន្ទ្រិយ រមែងបរិសុទ្ធដោយអាការទាំង ៣ នេះ ។

កាលវៀរបុគ្គលដែលមានចិត្តមិនតាំងមាំ កាលសេពគប់ចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តតាំងមាំ ពិចារណាឈាននិងវិមោក្ខ សមាធិន្ទ្រិយ រមែងបរិសុទ្ធដោយអាការទាំង ៣ នេះ ។

កាលវៀរបុគ្គលដែលឥតបញ្ញា, កាលសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលមានបញ្ញា, ពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ បញ្ញិន្ទ្រិយ រមែងបរិសុទ្ធដោយអាការ ៣ ទាំងនេះ, ដូចនោះ កាលវៀរបុគ្គលទាំង ៥ ពួកនេះ, កាលសេពគប់ចូលទៅអង្គុយជិតបុគ្គល ៥ ពួក ពិចារណាព្រះសូត្រ ៥ សូត្រ ឥន្ទ្រិយទាំង ៥ នេះ រមែងបរិសុទ្ធដោយអាការទាំង ១៥ នេះ ។ ធម៌ ១៥ ប្រការស្មើដទៃទៀត ជាគ្រឿងអប់រំវិមុត្តិ គឺឥន្ទ្រិយ ៥ មានសទ្ធាជាដើម សញ្ញាដែលជាចំណែកនៃការត្រាស់ដឹង ៥ ទាំងនេះ គឺ អនិច្ចសញ្ញា ទុក្ខសញ្ញា អនត្តសញ្ញា បហានសញ្ញា

វិរាគសញ្ញា ភាពជាអ្នកមានកល្យាណមិត្ត ការសង្រួមក្នុងសីល ភាពជាអ្នកផុសខាត់យ៉ាងក្រៃលែង ការប្រារព្ធសេចក្ដីព្យាយាម បញ្ញាដែលប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ។

បណ្ដាធម៌ទាំងនោះ ព្រះសាស្ដាទ្រង់ឆ្លាតក្នុងការទូន្មានវេនេយ្យបុគ្គល កាលនឹងទ្រង់សម្ដែងធម៌ដែលជាគ្រឿងអប់រំវិមុត្តិ មានកល្យាណមិត្តជាដើម ក្នុងទីនេះ តាមអធ្យាស្រ័យរបស់ព្រះមេឃិយត្ថេរ អ្នកគួរណែនាំ ទើបត្រាស់ថា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីចាស់ក្លា កាលនឹងឲ្យធម៌ទាំងនោះពិស្ដារ ទើបត្រាស់ពាក្យមានជាដើមថា “ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ” ។

បណ្ដាបទទាំងនោះ បទថា កល្យាណមិត្តោ សេចក្ដីថា ឈ្មោះថា កល្យាណមិត្ត ព្រោះមានមិត្តល្អ គឺបម្រើនល្អ ។ បុគ្គលដែលមានមិត្តបរិបូរណ៍ដោយសីលគុណជាដើម មានឧបការៈដោយអាការទាំងពួងយ៉ាងនេះ គឺបំបាត់ទុក្ខ សាងនូវប្រយោជន៍ ឈ្មោះថា ជាកល្យាណមិត្តមែនពិត ។ ឈ្មោះថា កល្យាណសហាយោ សម្លាញ់ល្អ ព្រោះទៅ គឺដំណើរទៅជាមួយដោយកល្យាណបុគ្គល តាមដែលពោលហើយនុ៎ះឯង

គឺមិនប្រព្រឹត្តទៅប្រាសចាកកល្យាណបុគ្គលទាំងនោះ ។ ឈ្មោះថា កាល្យាណសម្បវង្កោ បែរទៅរកមិត្តល្អ ព្រោះប្រព្រឹត្តទៅដោយការៈដែលបង្អោនទៅផ្លូវចិត្ត និងផ្លូវកាយ ក្នុងកល្យាណបុគ្គលនុ៎ះឯង ។ ដោយ ៣ បទ រមែងញ៉ាំងសេចក្តីអើពើ ឲ្យកើតឡើងក្នុងសួគ៌ជាមួយនឹងកល្យាណមិត្ត ។

ក្នុងសេចក្តីនោះ មានលក្ខណៈកល្យាណមិត្តដូចតទៅនេះ កល្យាណមិត្តក្នុងព្រះសាសនានេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល សុតៈ ចាគៈ វីរិយៈ សតិ សមាធិ និងបញ្ញា ។ ក្នុងលក្ខណៈកល្យាណមិត្តនោះ បុគ្គលមានសទ្ធាសម្បត្តិ រមែងជឿបញ្ញាត្រាស់ដឹងរបស់ព្រះតថាគត កម្មនិងផលនៃកម្ម មិនលះបោលការស្វែងរកប្រយោជន៍ក្នុងពួកសត្វ ដែលជាហេតុនៃព្រះសម្មាសម្ពោធិញាណ ដោយការជឿនោះ ។ មានសីលសម្បត្តិ រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរពសរសើរ ជាអ្នកចោទ ជាអ្នកតិះដៀលបាប ជាអ្នកឆ្លាតក្នុងពាក្យពោល អត់ធន់ចំពោះពាក្យសំដីរបស់សព្រហ្មចារីទាំងឡាយ, មានសុតសម្បត្តិ រមែងធ្វើពាក្យដែលជ្រាលជ្រៅជាប់ដោយសច្ចៈ និងបដិច្ចសមុប្បាទជាដើម, មានចាគសម្បត្តិ រមែងជា

អ្នកប្រាជ្ញាតិច សន្ដោស ស្ងប់ស្ងាត់ មិនប្រឡូកប្រឡល់ដោយពួក, មានវីរិយសម្បត្តិ រមែងជាអ្នកប្រារព្ធសេចក្ដីព្យាយាមដើម្បីបដិបត្តិប្រយោជន៍ដល់សត្វទាំងឡាយ, មានសតិសម្បត្តិរមែងមានសតិតាំងមាំ, មានសមាធិសម្បត្តិ រមែងជាអ្នកមានចិត្តមិនរវើរវាយ មានចិត្តតាំងមាំ, មានបញ្ញាសម្បត្តិ រមែងដឹងសភាវៈដែលមិនវិបរិត ។ បុគ្គលនោះ ជាអ្នកដល់ព្រមដោយគតិធម៌ដែលជាកុសលដោយសតិ ដឹងវត្ថុដែលមានប្រយោជន៍និងមិនមានប្រយោជន៍នៃសត្វទាំងឡាយតាមសេចក្ដីពិត ដោយបញ្ញា ជាអ្នកមានចិត្តតម្កល់មាំក្នុងកុសលធម៌ទាំងនោះ ដោយសមាធិ រមែងរារាំងសត្វទាំងឡាយចាកវត្ថុដែលមិនជាប្រ-យោជន៍ ហើយដឹកនាំចូលទៅក្នុងវត្ថុដែលជាប្រយោជន៍ ដោយវីរិយៈ, ដោយហេតុនោះ ទ្រង់ទើបពោលថា ៖

> ភិក្ខុជាអ្នក(ធ្វើខ្លួន)ឲ្យជាទីស្រឡាញ់ គួរគោរព គួរសរ-សើរ ឧស្សាហ៍ប្រៀនប្រដៅ អត់ធន់ចំពោះពាក្យសំដីជាអ្នកនិយាយពាក្យជ្រៅ និងមិនដឹកនាំក្នុងហេតុដែលមិនគួរ ។

បទថា អយំ បឋមោ ធម្មោ បរិទាកាយ

សំវត្តតិ សេចក្តីថា ធម៌ដែលរកទោសមិនបាននេះ ពោលគឺភាពជាអ្នកមានមិត្តដែលល្អ ឈ្មោះថាជាទី ១ ព្រោះជាខាងដើមនៃព្រហ្មចរិយាវាស និងព្រោះត្រាស់ទុកជាប្រការដំបូងក្នុងធម៌ ៥ ប្រការនេះ ដោយមានឧបការៈច្រើនដល់កុសលធម៌ទាំងពួង និងដោយសេចក្តីជាប្រធាន រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចាស់ក្លានៃចេតោវិមុត្តិ ដោយធ្វើសទ្ធាជាដើម ដែលមិនបរិសុទ្ធិឲ្យបរិសុទ្ធិ ។ ក៏ក្នុងទីនេះ សេចក្តីដែលកល្យាណមិត្តមានឧបការៈច្រើន និងជាប្រធាន គប្បីជ្រាបដោយសុត្តបទមានជាដើមថា "ម្នាលអានន្ទ ភាពជាអ្នកមានមិត្តល្អ មានសម្លាញ់ល្អ នេះជាព្រហ្មចរិយទាំងមូល" ព្រោះទ្រង់បដិសេធព្រះអានន្ទជាធម្មភណ្ឌាគារិក អ្នកពោលថា "បពិត្រព្រះអង្គដ៏ចម្រើន ភាពជាអ្នកមានមិត្តល្អ នេះជាពាក់កណ្តាលនៃព្រហ្មចរិយ" ដល់ទៅ ២ ដង ថា "មា ហេវំ អានន្ទ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ" ។

បទថា បុន ចបរំ ប្រែថា ក៏ធម្មជាតដទៃនៅមានទៀត ។ ក្នុងបទថា សីលវា នេះ មានវិនិច្ឆ័យដូចតទៅនេះ ដែលឈ្មោះថា សីល ព្រោះអត្ថថាដូម្តេច ? ដែលឈ្មោះថា

សីល ព្រោះអត្ថថា តាំងទុកមាំ ។ ដែលឈ្មោះថា តាំងទុកមាំ គឺអ្វី ? គឺកិរិយារួបរួមទុក អធិប្បាយថា សេចក្ដីដែលកាយកម្មជាដើមសមរម្យ មិនរាត់រាយ ព្រោះភាពជាអ្នកមានសីលល្អ ។

ម្យ៉ាងទៀត ជាទីទ្រទ្រង់ទុក អធិប្បាយថា ភាពជាទីទ្រទ្រង់ទុក ដោយភាពជាទីតាំងដល់កុសលធម៌មានឈានជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **សីល** ព្រោះទ្រទ្រង់ទុកឬប្រក្រតី ។ នេះជាអត្ថនៃសីល ដោយន័យនៃលក្ខណៈរបស់ស័ព្ទជាដំបូង ។ តែអាចារ្យមួយពួកទៀត ពណ៌នាអត្ថដោយនិរុត្តិន័យថា អត្ថនៃសីល មានអត្ថថា ជាកំពូល (**សិរដ្ឋោ**) មានអត្ថថា ត្រជាក់ (**សីតលដ្ឋោ**) មានអត្ថថា ជាប្រធាន (**សីសដ្ឋោ**) មានអត្ថថា សំវរៈ (**សំវរដ្ឋោ**) ។ សីលនេះមាននៅក្នុងបុគ្គលនោះដោយគ្រប់គ្រាន់ ឬដោយល្អ ព្រោះដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា **សីលវា** អ្នកមានសីល ។ អធិប្បាយថា អ្នកបរិបូរណ៍ដោយសីល ។

មួយទៀត ដើម្បីនឹងសម្ដែងភាពដែលបុគ្គលជាអ្នកមានសីល បរិបូរណ៍ដោយសីល ទើបត្រាស់ពាក្យមានជាដើមថា "**បាតិមោក្ខសំវរសំវុតោ**" ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា បាតិមោក្ខំ បានដល់ សីលនិងសិក្ខាបទ ។ ពិតមែន សីលនិងសិក្ខាបទនោះ ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ធ្វើបុគ្គលអ្នករក្សាសីលសិក្ខាបទនោះ ឲ្យរួចផុតចាកទុក្ខ មានទុក្ខក្នុងអបាយជាដើម ។ ការបិទការពារ ឈ្មោះថា **សំវរៈ** បានដល់ ការមិនកន្លងល្មើសផ្លូវកាយនិងវាចា ។ សំវរៈគឺ បាតិមោក្ខ ឈ្មោះថា **បាតិមោក្ខ-សំវរៈ** ។ ភិក្ខុអ្នកសង្រួម គឺមានកាយនិងវាចាបិទដោយបាតិមោក្ខសំវរៈនោះ ទើបឈ្មោះថា សង្រួមដោយបាតិមោក្ខ-សំវរៈ ។ នេះជាការសម្ដែងភាវៈដែលភិក្ខុនោះ តាំងនៅក្នុងសីលនោះ ។ បទថា វិហរតិ ជាបទសម្ដែងភាវៈដែលភិក្ខុព្រមព្រៀងដោយការនៅ ដែលសមគួរដោយបាតិមោក្ខសំវរៈនោះ ។ បទថា អាចារគោចរសម្បន្នោ ជាបទសម្ដែងដល់ធម៌ដែលមានឧបការៈដល់បាតិមោក្ខសំវរៈ ក្នុងខាងក្រោម និងដល់សេចក្ដីប្រារព្ធព្យាយាមដើម្បីគុណវិសេសក្នុងខាងលើ ។ បទថា អណុមត្តេសុ វជ្ជេសុ ភយទស្សាវី ជាបទសម្ដែងភាវៈដែលភិក្ខុមិនឃ្លាតចាកបាតិមោក្ខសីលជាធម្មតា ។ បទថា សមាទាយ ជាបទសម្ដែងការប្រកាន់យកសិក្ខាបទ ដោយមិន

មានចំណែកនៅសល់ ។ បទថា សិក្ខតិ ជាបទសម្ដែងភាវៈ ដែលភិក្ខុព្រមព្រៀងដោយការសិក្សា ។ បទថា សិក្ខាបទេសុ ជាបទសម្ដែងធម៌ដែលគួរសិក្សា ។

ន័យមួយទៀត ឈ្មោះថា ចាតិ ព្រោះមានប្រក្រតីធ្លាក់ទៅក្នុងអបាយច្រើនគ្រា ព្រោះកិលេសខ្លាំងក្លា ព្រោះការធ្វើសេចក្ដីអាក្រក់ ធ្វើបានងាយ និងព្រោះការធ្វើបុណ្យធ្វើបានលំបាក បានដល់ បុថុជ្ជន ។ម្យ៉ាងទៀត ឈ្មោះថា **បាតិ** ព្រោះត្រូវកម្លាំងកម្មបោះទៅក្នុងភពជាដើម ដោយភាវៈមិនទៀង និងមានប្រក្រតីទៅដោយការវិលទៅ ដោយកំណត់មិនបាន ដូចផ្ទាំងយន្ត ។ ម្យ៉ាងទៀត ឈ្មោះថា ប្រក្រតី ព្រោះមានប្រក្រតីធ្លាក់ទៅនៃអត្តភាព ក្នុងសត្តនិកាយនោះៗ ដោយអំណាចមរណៈ ឬសន្ដានរបស់សត្វគឺចិត្តនោះឯង ។ ឈ្មោះថា បាតិ-មោក្ខ ព្រោះញ៉ាំងអ្នកធ្លាក់ទៅនោះឲ្យផុតពីសង្សារទុក្ខ ។ ក៏សត្វដែលហៅថា វិមុត្តៈ ព្រោះចិត្តរួចផុត ។ សមពិតដូចពាក្យដែលលោកពោលទុកថា អ្នកមានចិត្តផូរផង់ រមែងបរិសុទ្ធិ និងពោលទុកថា ចិត្តរួចផុតចាកអាសវៈ ព្រោះមិនប្រកាន់មាំ ។ម្យ៉ាងទៀត ឈ្មោះថា ប្រក្រតី ព្រោះធ្លាក់ទៅ គឺទៅ បានដល់

ប្រព្រឹត្តទៅក្នុងសង្សារ ដោយហេតុមានអវិជ្ជាជាដើម ។ សម ពិតដូចពោលទុកថា សត្វអ្នកមានអវិជ្ជាជាគ្រឿងរាំង មាន តណ្ហាជាគ្រឿងចង ត្រាច់ទៅ អន្ទោលទៅ ។ ធម៌ឈ្មោះថា បាតិមោក្ខ: ព្រោះជាហេតុឲ្យសត្វអ្នកធ្លាក់ទៅនោះផុតពីសង្កិ- លេស ៣ មានតណ្ហាជាដើម ។ គប្បីជ្រាបសេចក្តីសម្រេច សមាស ដូចសេចក្តីសម្រេចពាក្យមានជាដើមថា "កណ្ណ- កាលោ" ។

ម្យ៉ាងទៀត ឈ្មោះថា ប្រកតី ព្រោះធ្វើសត្វឲ្យធ្លាក់ទៅ គឺឲ្យធ្លាក់ទៅមិននៅសល់ពីទុក្ខ បានដល់ ចិត្ត ។ ឈ្មោះថា បាតិមោក្ខ ព្រោះជាគ្រឿងធ្វើសត្វអ្នកធ្លាក់ទៅនោះឲ្យរួចផុតទៅ (ចាកទុក្ខ) ។ ម្យ៉ាងទៀត ឈ្មោះថា **បាតិ** ព្រោះជាគ្រឿងធ្លាក់ ទៅក្នុងអបាយទុក្ខ និងសង្សារទុក្ខរបស់សត្វ បានដល់ សង្កិ- លេសមានតណ្ហាជាដើម សមពិតដូចដែលលោកពោលទុកថា "តណ្ហា រមែងញ៉ាំងបុរសឲ្យកើត" និងពោលទុកថា "បុរសមាន តណ្ហាជាសម្លាញ់ទីពីរ" ។ ឈ្មោះថា បាតិមោក្ខ ព្រោះផុតចាក ការធ្លាក់ទៅពីតណ្ហាសង្កិលេសនោះ ។ ម្យ៉ាងទៀត ឈ្មោះថា **បាតិ** ព្រោះជាទីធ្លាក់ទៅរបស់សត្វ បានដល់ អាយតនៈខាង

ក្នុង ៦ និងអាយតនៈខាងក្រៅ ៦ ។

សមពិតដូចដែលលោកពោលទុកថា សត្វលោក កើតព្រមក្នុងអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ រមែងធ្វើការសេរសើរក្នុងអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ ។ ឈ្មោះថា បាតិមោក្ខ ព្រោះផុតពីការធ្លាក់ទៅ ពោលគឺអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នោះ ។ ម្យ៉ាងទៀត ឈ្មោះថា **បាតិ** គឺ សង្សារ ព្រោះមានការធ្លាក់ទៅ គឺការធ្វើឲ្យធ្លាក់ទៅ ឈ្មោះថា បាតិមោក្ខ ព្រោះរួចផុតចាកសង្សារនោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ជាធម្មិស្សរៈ លោកថ្វាយព្រះនាមថា **បតិ** ព្រោះជាអធិបតីរបស់សព្វលោក ។ ឈ្មោះថា **មោក្ខៈ** ព្រោះជាគ្រឿងផុតរបស់សត្វ ។ ឈ្មោះថា **បតិមោក្ខ** ព្រោះជាគ្រឿងផុតនៃព្រះមានព្រះភាគ ទ្រង់បាននាមថា **បតិ** ហេតុទ្រង់បញ្ញត្តិទុក ។ បតិមោក្ខនុ៎ះឯង ជាបាតិមោក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា **បតិមោក្ខ** ព្រោះព្រះមានព្រះភាគនោះ ឈ្មោះថា ជាធំ ដោយអត្ថថា មានគុណទាំងពួងខ្ពស់បំផុត ដែលមានគុណនោះជាមូល និងឈ្មោះថា ជាអ្នកផុត ដោយអត្ថ

តាមដែលពោលហើយ ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ។ សមពិតដូចពាក្យដែលលោកពោលទុកថា "ពាក្យថា **បាតិមោក្ខ** នេះ ធម្មជាតនេះជាប្រធាន ធម្មជាតនេះជាមុនដម្បូង" ។ គប្បីជ្រាបពិស្តារដូចតទៅនេះ ។

ម្យ៉ាងទៀត ស័ព្ទថា ប ប្រើក្នុងអត្ថថា **បការះ** ស័ព្ទថា **អតិ** ជានិបាត ប្រើក្នុងអត្ថថា **អច្ចន្តះ** ។ ព្រោះដូច្នោះ ទើបឈ្មោះថា បាតិមោក្ខ ព្រោះកន្ទងផុតចំណែកដោយគ្រប់ប្រការ ។ ពិតមែន សីលនេះ ឈ្មោះថា **បាតិមោក្ខ** ព្រោះតួសីលធ្វើឲ្យរួចផុតបានពិត ដោយតទង្គវិមុត្តិ ដែលប្រកបដោយសមាធិ និងបញ្ញា ធ្វើឲ្យរួចផុតបានពិត ដោយអំណាចវិក្ខម្ភនវិមុត្តិ និងសមុច្ឆេទវិមុត្តិ ។

ម្យ៉ាងទៀត ឈ្មោះ **បតិមោក្ខ** ព្រោះរួចផុតចំពោះ អធិប្បាយថា រួចផុតចាកវីតិក្កមទោសនោះៗ ដោយចំណែកមួយ ។ បតិមោក្ខនោះឯង ជាបាតិមោក្ខ ។ ឬថា និព្វាន ឈ្មោះថា មោក្ខៈ ។ ឈ្មោះថា **បតិមោក្ខ** ព្រោះប្រៀបផ្ទឹមនឹងមោក្ខៈនោះៗ ពិតមែន សីលសំវរៈ ជាហេតុធ្វើព្រះនិព្វានឲ្យកើត ដូចព្រះអាទិត្យធ្វើអរុណឲ្យកើត និងមានចំណែកប្រៀបធៀបដោយ

ព្រះនិព្វាននោះ ព្រោះធ្វើកិលេសឲ្យរលត់តាមសមគួរ ។ បតិ-
មោក្ខនោះឯង ជាបាតិមោក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា **បតិមោក្ខ**
ព្រោះប្រែទៅ គឺធ្វើទុក្ខឲ្យរួចផុតទៅ ។ បតិមោក្ខនោះឯង ជា
បាតិមោក្ខ ក្នុងសេចក្ដីនេះ គប្បីជ្រាបសេចក្ដីសំពូថា បាតិមោក្ខ
ប៉ុណ្ណោះយ៉ាងនេះ ដោយប្រការដូច្នេះ ។

ឈ្មោះថា ***សំវរៈ*** ព្រោះជាគ្រឿងបិទការពារ ។ *សំវរៈ*
គឺ បាតិមោក្ខ ឈ្មោះថា បាតិមោក្ខសំវរៈ ។ តែកាលពោលអំពី
អត្ថន័យ បានដល់ វៀរចាកទោសដែលគប្បីឈានកន្លងនោះៗ
និងចេតនា ។ ភិក្ខុអ្នកចូលដល់ ប្រកបដោយបាតិមោក្ខសំវរ
នោះ លោកហៅថា អ្នកសង្រួមដោយបាតិមោក្ខសំវរ ។ សម
ពិតដូចដែលត្រាស់ទុកក្នុងគម្ពីរវិភង្គថា ភិក្ខុជាអ្នកចូលដល់
ចូលដល់ព្រម មកដល់ មកដល់ព្រម ចូលជិត ចូលជិតព្រម
ប្រកបដោយបាតិមោក្ខសំវរៈនេះ ដោយហេតុនោះ ទើបត្រាស់
ថា អ្នកសង្រួមដោយបាតិមោក្ខសំវរៈ ។ បទថា វិហរតិ
សេចក្ដីថា រមែងនៅ គឺផ្លាស់ប្ដូរ បានដល់ ផ្លាស់ប្ដូរទៅ
ដោយឥរិយាបថវិហារ ។

បទថា អាចារគោចរសម្បន្នោ សេចក្ដីថា ឈ្មោះថា

ដល់ព្រមដោយអាចារៈនិងគោចរ ព្រោះវៀរអនាចារទាំងពួង ហេតុមិនធ្វើមិច្ឆាជីវៈ មានការឲ្យឫស្សីជាដើម និងការឃ្មើស-ឃ្មងកាយជាដើម ហើយប្រកបដោយអាចារសម្បត្តិ ដែលសមគួរដល់ភិក្ខុដែលត្រាស់ទុកយ៉ាងនេះថា ការមិនកន្លងល្មើសផ្លូវកាយ ផ្លូវវាចា និងទាំងផ្លូវកាយទាំងផ្លូវវាចា និងវៀរអគោចរ មានស្រីពេស្យាជាដើមហើយ ប្រកបដោយគោចរ ពោលគឺកន្លែងដែលសមគួរចូលទៅបិណ្ឌបាតជាដើម ។

ម្យ៉ាងទៀត ភិក្ខុណា មានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា មានសេចក្តីគោរពកោតក្រែងក្នុងមិត្តសព្រហ្មចារីដល់ព្រមដោយហិរិឱត្តប្បៈ ស្លៀកដណ្តប់រៀបរយ មានការឈានទៅមុខ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់ដៃជើង លាដៃជើង គួរជ្រះថ្លាបរិបូរណ៍ដោយឥរិយាបថ យុំគ្រងទ្វារក្នុងឥន្ទ្រិយ ស្គាល់ប្រ-មាណក្នុងភោជន ដល់ព្រមដោយសេចក្តីព្យាយាម ប្រកបដោយសតិនិងសម្បជញ្ញៈ ជាអ្នកប្រាថ្នាតិច សន្តោស ស្ងប់-ស្ងាត់ មិនប្រឡូកប្រឡល់ដោយពួក ធ្វើសេចក្តីគោរព ក្នុងអាភិ-សមាចារិកវត្ត ច្រើនដោយសេចក្តីគោរព និងកោតក្រែង ភិក្ខុនេះ លោកហៅថា បរិបូរណ៍ដោយអាចារៈ ។

ចំណែកគោចរមាន ៣ យ៉ាង គឺ ឧបនិស្សយគោចរ ១ អារក្ខគោចរ ១ ឧបនិពន្ធគោចរ ១ ។ ក្នុង ៣ យ៉ាងនោះ ភិក្ខុណាប្រកបដោយគុណគឺ កថាវត្ថុ ១០ មានមិត្តល្អ មានលក្ខណៈដូចពោលហើយ ដែលអាស្រ័យហើយ រមែងបានស្តាប់វត្ថុដែលមិនទាន់ធ្លាប់បានស្តាប់ រមែងធ្វើវត្ថុដែលធ្លាប់បានស្តាប់ហើយឲ្យផូរផង់ កាត់សេចក្តីសង្ស័យចេញបាន ធ្វើសេចក្តីយល់ឃើញឲ្យត្រង់ ធ្វើចិត្តឲ្យជ្រះថ្លា កាលសិក្សាតាមរមែងចម្រើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយចាគៈ និងដោយបញ្ញា នេះលោកហៅថា **ឧបនិស្សយគោចរ** ។

ភិក្ខុណា ចូលទៅកាន់ចន្លោះផ្ទះ ដើរទៅតាមថ្នល់ មានភ្នែកសំឡឹងចុះ ក្រឡេកមើលមួយជួរនឹម ដើរសង្រួមចក្ខុន្ទ្រិយទៅ មិនដើរក្រឡេកមើលដំរី មិនដើរក្រឡេកមើលសេះ មិនដើរក្រឡេកមើលរថ មិនដើរក្រឡេកមើលពលស្មើជើង មិនដើរក្រឡេកមើលស្រី មិនដើរក្រឡេកមើលប្រុស មិនងើយមើលលើ មិនដើរក្រឡេកមើលខាងក្រោម មិនដើរក្រឡេកមើលទិសតូចធំ នេះលោកហៅថា **អារក្ខគោចរ** ។

ចំណែក **ឧបនិពន្ធគោចរ** បានដល់ សតិប្បដ្ឋាន ៤ ជាទីដែលភិក្ខុចូលទៅចងចិត្តរបស់ខ្លួនទុក ។ សមពិតដូចដែលព្រះ-

មានព្រះភាគ បានត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ចុះទីជាទីគោចររបស់ភិក្ខុ ជាដែននៃបិតារបស់ខ្លួន តើដូចម្តេច ? គឺសតិប្បដ្ឋានទាំង ៤ នេះឯង” ។

ក្នុងគោចរ ៣ យ៉ាងនោះ ព្រោះឧបនិស្សយគោចរ លោកពោលទុកមុនហើយ ក្នុងទីនេះគប្បីជ្រាបគោចរ ២ យ៉ាងក្រៅនោះ ។ ភិក្ខុនោះឈ្មោះថា អ្នកបរិបូរណ៍ដោយអាចារៈ និងគោចរៈ ព្រោះប្រកបដោយអាចារសម្បត្តិ តាមដែលពោលហើយ និងគោចរសម្បត្តិនេះ ដោយប្រការដូច្នេះ ។

បទថា អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សេចក្តីថា អ្នកមានប្រក្រតីឃើញភ័យក្នុងទោស ផ្សេងដោយសេក្ខិយសិក្ខាបទ ដែលភិក្ខុមិនក្លែងឲ្យត្រូវ និងអកុសលចិត្តុប្បាទជាដើម ឈ្មោះថា មានប្រមាណតិច ព្រោះមានប្រមាណបន្តិចបន្តួច ។ ពិតមែន ភិក្ខុណាឃើញទោសមានប្រមាណតិច ធ្វើឲ្យដូចជាភ្នំសិនេរុដែលមានកម្ពស់ ១០០,០៦៨ យោជន៍[១] ចំណែក

១ ដីកាវិសុទ្ធិមគ្គ ថា កម្ពស់ ៦,៨០០,០០០ យោជន៍ (អដ្ឋសដ្ឋិយោជនសតសហស្ស) ។ អដ្ឋកថាវិន័យ និងក្នុងបិដក លេខ៤៧ ថា ផុតពីទឹកទៅលើ ៨៤,០០០ យោជន៍ (ចតុរាសីតិយោជនសហស្សានិ) ។

ភិក្ខុណា ឃើញអាបត្តិត្រឹមតែទុក្កដសិត ដែលជាអាបត្តិស្រាល ជាងអាបត្តិទាំងពួង ធ្វើឲ្យដូចអាបត្តិបារាជិក ភិក្ខុសូម្បីនេះ ឈ្មោះថា មានប្រក្រតីឃើញភ័យក្នុងទោសមានប្រមាណតិច ។ បទថា សមាទាយ សិក្ខតិ សិក្ខាបទេសុ សេចក្តីថា ភិក្ខុ កាន់យកសិក្ខាបទដែលគួរសិក្សាយ៉ាងណាមួយ ក្នុងសិក្ខាបទ ទាំងឡាយទាំងអស់ ដោយមិនមានចំណែកសេសសល់ ដោយ ប្រការទាំងពួងហើយសិក្សា អធិប្បាយថា រមែងប្រព្រឹត្ត គឺ ធ្វើឲ្យបរិបូរណ៍ដោយប្រពៃ ។

បទថា អភិសល្លេខិកា បានដល់ អ្នកមានប្រក្រតី ជុសខាត់កិលេសយ៉ាងក្រៃលែង គឺជាអ្នកសមគួរដើម្បីលះ កិលេសទាំងនោះ ដោយធ្វើឲ្យស្រាលខ្លះ ។ បទថា ចេតោ- វិវរណសប្បាយា បានដល់ ជាសប្បាយរបស់សមថៈ និង វិបស្សនា ពោលគឺបើកចិត្ត ដោយធ្វើនីវរណៈដែលជាគ្របទ- បាំងចិត្តឲ្យឃ្លាតឆ្ងាយ ។ សមថៈនិងវិបស្សនានោះឯងជា សប្បាយ គឺជាឧបការៈដល់ការបើកចិត្ត ឬការធ្វើចិត្តនោះឯង ឲ្យប្រាកដ ហេតុដូច្នោះ ទើបឈ្មោះថា ចេតោវិវរណសប្បាយា ជាសប្បាយក្នុងការបើកចិត្ត ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងហេតុជាគ្រឿងនាំមកនូវសេចក្ដីនឿយណាយជាដើម ដែលជាកថាជុសខាត់កិលេស និងជាសប្បាយក្នុងការបើកចិត្ត ទើបត្រាស់ពាក្យមានជាដើមថា "ឯកន្តនិព្វិទាយ" ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា ឯកន្តនិព្វិទាយ បានដល់ ដើម្បីនឿយនាយចាកវដ្ដទុក្ខដោយពិតប្រាកដតែម្ដង ។ បទថា វិរាគាយ និរោធាយ បានដល់ ដើម្បីបំបាត់និងដើម្បីរលត់វដ្ដទុក្ខនោះៗ ឯង ។ បទថា ឧបសមាយ បានដល់ ដើម្បីស្ងប់សព្វកិលេស ។ បទថា អភិញ្ញាយ បានដល់ ដើម្បីដឹងក្រៃលែង ធម៌ដែលគួរដឹងក្រៃលែងសូម្បីទាំងអស់ ។ បទថា សម្ពោធាយ បានដល់ ដើម្បីត្រាស់ដឹងមគ្គចិត្ត ៤ ។ បទថា និព្វានាយ បានដល់ ដើម្បីអនុបាទិសេសនិព្វានធាតុ ។ ក៏បណ្ដាបទទាំងនេះ ត្រាស់វិបស្សនាដោយ ៣ បទ ខាងដើម ។ ត្រាស់មគ្គដោយបទទាំង ២ ត្រាស់និព្វានដោយបទទាំង ២ ។ លោកសម្ដែងថា ឧត្តរិមនុស្សធម្មទាំងអស់នេះ ចាប់ផ្ដើមតាំងពីសមថៈ និងវិបស្សនាដរាបដល់និព្វានជាទីបំផុត រមែងកើតមានដល់អ្នកបានកថាវត្ថុ ១០ ។

ឥឡូវនេះ កាលនឹងទ្រង់បែកសម្តែងកថានោះ ទើបត្រាស់ពាក្យមានជាដើមថា **អប្បិច្ឆកថា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អប្បិច្ឆោ ប្រែថា អ្នកមិនប្រាថ្នា ។ កថានៃ**អប្បិច្ឆៈ** ដូច្នោះ ឈ្មោះថា **អប្បិច្ឆកថា** ឬកថាដែលជាប់ដោយភាពជាអ្នកប្រាថ្នាតិច ឈ្មោះថា **អប្បិច្ឆកថា** ។ ក៏ក្នុងទីនេះ ពោលដោយអំណាចសេចក្តីប្រាថ្នាមានបុគ្គល ៤ ពួក គឺ អត្រិច្ឆោ អ្នកប្រាថ្នាក្រៃលែងៗឡើង ១ ចាបិច្ឆោ អ្នកប្រាថ្នាលាមក ១ មហិច្ឆោ អ្នកប្រាថ្នាច្រើន ១ អប្បិច្ឆោ អ្នកប្រាថ្នាតិច ១ ។ ក្នុងបុគ្គលទាំង ៤ នោះ អ្នកមិនឆ្អែតលាភតាមដែលខ្លួនបានមក ប្រាថ្នាលាភក្រៃលែងៗ ឡើង ឈ្មោះថា អត្រិច្ឆៈ ដែលលោកសំដៅពោលទុក (បិដក៥៨, ៤៧) ថា ៖

អ្នក (ចេញ) ពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨
(ចេញ) ពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦
(ចេញ) ពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២
(ក៏នៅតែមិនស្កប់ស្កល់) ចក្រក៏វិលលើក្បាលនៃបុរស
កាលប្រាថ្នាក្នុងទីនោះៗ ទើបមកដល់កង់ចក្រ កង់ចក្រ
រមែងវិលលើក្បាល បុគ្គលដែលមានសេចក្តីប្រាថ្នា

គ្របសង្កត់ ដូច្នេះ ។

និងដែលត្រាស់ថា បុគ្គលដែលចង់បានលើសចំណែក រមែងសាបសូន្យចាកប្រយោជន៍ ព្រោះលោភពេកទៅ និងព្រោះស្រវឹងក្នុងសេចក្ដីលោភពេកទៅ ។ អ្នកមានសេចក្ដីប្រាថ្នាក្នុងការលើកតម្កើងគុណដែលមិនមាន ឈ្មោះថា អ្នកប្រាថ្នាលាមក ព្រោះមានសេចក្ដីត្រូវការក្នុងលាភសក្ការៈ និងការសរសើរ ដែលលោកសំដៅពោលទុកថា ក្នុងបាបធម៌ទាំងនោះ កុហនា ដូចម្ដេច ? ការតម្រង់ឥរិយាបថ កិរិយាដែលតម្រង់ឥរិយាបថ សេចក្ដីតម្រង់ឥរិយាបថទុកដោយល្អ ដោយការសេពបច្ច័យ ឬដោយការនិយាយដោយជុំវិញ របស់អ្នកប្រាថ្នាលាមក ត្រូវសេចក្ដីចង់បានគ្របសង្កត់ អាស្រ័យក្នុងលាភសក្ការៈ និងការសរសើរ ដូច្នេះជាដើម ។ អ្នកមានសេចក្ដីប្រាថ្នាក្នុងការលើកតម្កើងគុណដែលមាន និងមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា អ្នកប្រាថ្នាច្រើន ដែលលោកសំដៅ ពោលទុកថា ៖

“បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសទ្ធា ប្រាថ្នាថា សូមអ្នកចូរស្គាល់យើងថា ជាអ្នកមានសទ្ធា ជាអ្នកមានសីល រមែងប្រាថ្នាថា សូមអ្នកចូរស្គាល់យើងថា ជាអ្នកមានសីល”

ដូច្នេះជាដើម ។ ពិតយ៉ាងនោះ សូម្បីមាតាបង្កើត ក៏មិនអាចនឹងយកចិត្តគេបាន ដោយហេតុនោះ លោកទើបពោលពាក្យនេះទុកថា ៖

បុគ្គលដែលឲ្យបច្ច័យជាច្រើនរេទះ ក៏មិនគប្បីញុំាងសូម្បីសភាវៈទាំង ៣ នេះ គឺ គំនរភ្លើង ១ មហាសមុទ្រ ១ បុគ្គលដែលប្រាថ្នាច្រើន ១ ឲ្យពេញបាន ។

បុគ្គលវៀរទោស មានសេចក្តីជាអ្នកប្រាថ្នាច្រើនជាដើមទាំងនេះ ឲ្យឃ្លាតឆ្ងាយ ហើយមានសេចក្តីប្រាថ្នាលាក់គុណដែលមាន និងស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ជាអ្នកប្រាថ្នាតិច ។ ព្រោះគេប្រាថ្នានឹងបិទបាំងគុណសូម្បីដែលមាននៅក្នុងខ្លួន និងមានសទ្ធា ក៏មិនប្រាថ្នាថា សូមជនចូរស្គាល់យើងថា មានសទ្ធា និងមានសីល មានសុតៈច្រើន ស្ងប់ស្ងាត់ ប្រាថ្នាសេចក្តីព្យាយាម មានសតិតាំងមាំ មានចិត្តជាសមាធិ មានបញ្ញា ក៏មិនប្រាថ្នាថា សូមជនស្គាល់យើងថា មានបញ្ញា ។ បុគ្គលប្រាថ្នាតិចនេះនោះ មាន ៤ ពួក គឺអ្នកប្រាថ្នាតិចក្នុងបច្ច័យ (បច្ចយប្បិច្ឆោ) ១ អ្នកប្រាថ្នាតិចក្នុងធុតង្គ (ធុតង្គ-ប្បិច្ឆោ) ១ អ្នកប្រាថ្នាតិចក្នុងបរិយត្តិ (បរិយត្តិអប្បិច្ឆោ) ១

អ្នកប្រាថ្នាតិចក្នុងអធិគម (អធិគមប្បិច្ឆោ) ១ ។ ក្នុង ៤ ពួកនោះ អ្នកប្រាថ្នាតិចក្នុងបច្ច័យ ៤ ត្រូវមើលអ្នកឲ្យបច្ច័យ ទេយ្យធម៌ និងកម្លាំងរបស់ខ្លួន ក៏សូម្បីបើទេយ្យធម៌មានច្រើន ទាយកប្រាថ្នានឹងថ្វាយតិច ក៏ទទួលតែបន្តិច ដោយអំណាចទាយក ។ បើទេយ្យធម៌មានតិច ទាយកប្រាថ្នានឹងថ្វាយច្រើន ក៏ទទួលតែបន្តិច ដោយអំណាចទេយ្យធម៌ ។ បើសូម្បីទេយ្យធម៌មានច្រើន ទាំងទាយកក៏ប្រាថ្នានឹងថ្វាយច្រើន គួរនឹងដឹងកម្លាំងរបស់ខ្លួន ហើយទទួលតែល្មមប្រមាណប៉ុណ្ណោះ ។ ក៏ភិក្ខុបែបនេះ រមែងធ្វើលាភដែលនៅមិនទាន់កើតឲ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយឲ្យមាំមួន ញុំាងចិត្តទាយកទាំងឡាយឲ្យត្រេកអរ ។ ក៏អ្នកមិនប្រាថ្នានឹងឲ្យដឹងថា ការសមាទាន-ធុតង្គ មាននៅក្នុងខ្លួន ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងធុតង្គ ។ អ្នកណាមិនប្រាថ្នាដើម្បីនឹងឲ្យអ្នកដទៃដឹងថា ខ្លួនជាពហុស្សូត អ្នកនេះឈ្មោះថា អ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។ ចំណែកអ្នកណាជាព្រះអរិយបុគ្គលថ្នាក់សោតាបន្នជាដើម រូបណាមួយ ក៏មិនប្រាថ្នានឹងឲ្យដើម្បីសព្រហ្មចារីដឹងថា ខ្លួនជាព្រះសោតាបន្នជាដើម អ្នកនេះឈ្មោះថា អ្នកប្រាថ្នាតិចក្នុងអធិគម ។ កថា

ដែលប្រព្រឹត្តទៅដោយអំណាចការប្រកាសទោស និងអានិសង្ស មានអាការជាអនេក និងដោយអំណាចការប្រកាសទោសរបស់ឥច្ឆាចារ ដែលមានភាពជាអ្នកប្រាថ្នាច្រើនជាដើម ជាបដិបក្ខ ចំពោះសេចក្ដីប្រាថ្នាតិចនោះ ព្រមទាំងវិធីមានការចង្អុលដល់សេចក្ដីត្រេកអរ សេចក្ដីប្រាថ្នាតិចរបស់បុគ្គលដែលប្រាថ្នាតិចនេះ ឈ្មោះថា កថាពោលដោយសេចក្ដីប្រាថ្នាតិច ដោយប្រការដូច្នេះ ។

បទថា សន្តុដ្ឋិ ក្នុងពាក្យថា **សន្តុដ្ឋិកថា** នេះ បានដល់សេចក្ដីត្រេកអរដោយរបស់ខ្លួន គឺដោយរបស់ដែលខ្លួនបានមក ឈ្មោះថា **សន្តុដ្ឋិ** ។ មួយវិញទៀត ការលះបង់សេចក្ដីប្រាថ្នាបច្ច័យដែលមិនស្មើ ហើយត្រេកអរបច្ច័យដ៏ស្មើ ឈ្មោះថា **សន្តុដ្ឋិ** ។ មួយវិញទៀត សេចក្ដីត្រេកអរដោយរបស់ដែលមាន គឺប្រាកដ ឈ្មោះថា **សន្តុដ្ឋិ** ។ សមពិតដូចពាក្យដែលលោកពោលទុកថា ៖

> អ្នកមិនសោកស្ដាយចំពោះវត្ថុជាអតីត: មិនរអ៊ូរទាំដល់វត្ថុដែលជាអនាគត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុជាបច្ចុប្បន្ន លោកហៅថា អ្នកសន្តោស ។

ម្យ៉ាងទៀត សេចក្ដីត្រេកអរដោយបច្ច័យដោយវិធីដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ដោយញៀយ្យធម៌ដោយប្រពៃ ឈ្មោះថា **សន្តុដ្ឋិ** ដោយអត្ថ បានដល់ សេចក្ដីសន្ដោសក្នុងបច្ច័យតាមមានតាមបាន ។ សន្ដោសនោះមាន ១២ យ៉ាង។ អ្វីខ្លះ គឺសេចក្ដីសន្ដោសក្នុងចីវរមាន ៣ យ៉ាង គឺ យថាលាភសន្ដោស ១ យថាពលសន្ដោស ១ យថាសារុប្បសន្ដោស ១។ សន្ដោសក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។

ក្នុងសន្ដោសទាំងនោះ មានសំវណ្ណនាដោយប្រភេទដូចតទៅនេះ ភិក្ខុក្នុងព្រះធម៌វិន័យនេះ បានចីវរល្អក៏ដោយ មិនល្អក៏ដោយ លោកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះឯង មិនប្រាថ្នាចីវរដទៃ សូម្បីបានក៏មិនទទួល អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា **យថាលាភសន្ដោសក្នុងចីវរ** ។ តែគ្រាលោកទុព្វលភាពតាមប្រក្រតី ឬត្រូវសេចក្ដីឈឺចាប់ និងជរាគ្របសង្កត់ លោកដណ្ដប់ចីវរធ្ងន់ រមែងលំបាក លោកផ្លាស់ប្ដូរចីវរធ្ងន់នោះ ជាមួយភិក្ខុដែលជាសភាគគ្នា សូម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ឈ្មោះថា ជាអ្នកសន្ដោសពិត អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា **យថាពលសន្ដោស**

ក្នុងចីវរ ។ ភិក្ខុមួយរូបទៀត បានចីវរមានតម្លៃច្រើនផ្ទាំងណាមួយ មានចីវរសំពត់ជាដើម គិតថា នេះសមគួរដល់ព្រះ-ថេរៈអ្នកបួសយូរ នេះសមគួរដល់ព្រះថេរៈអ្នកជាពហុស្សូត នេះសមគួរដល់ព្រះថេរៈអ្នកមានជំងឺ នេះសមគួរដល់ព្រះថេរៈអ្នកមានលាភតិច ទើបថ្វាយដល់ព្រះថេរៈទាំងនោះ ហើយស្វែងរកសំពត់ដែលមានជាយពីគំនរសម្រាមជាដើម ដោយខ្លួនឯងធ្វើសង្ឃាដិ ឬទទួលចីវរចាស់របស់លោកទាំងនោះមកគ្រងក៏ចាត់ថា ជាអ្នកសន្តោសដោយពិត ។ អាការរបស់ភិក្ខុនោះនេះឈ្មោះថា **យថាសារុប្បសន្តោសក្នុងចីវរ** ។

មួយទៀត ភិក្ខុក្នុងព្រះធម្មវិន័យនេះ បានបិណ្ឌបាតដែលសៅហ្មង ឬប្រណីត លោកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះឯង មិនប្រាថ្នាបិណ្ឌបាតដទៃ សូម្បីបានក៏មិនទទួល អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាលាភសន្តោសក្នុងបិណ្ឌបាត ។ ក៏គ្រាលោកអាពាធ បរិភោគបិណ្ឌបាតដែលសៅហ្មង ដែលជារបស់គួរជៀសវៀងតាមប្រក្រតី ឬគួរជៀសវៀងចំពោះព្យាធិ ដល់ភាពជាអ្នកមានរោគធ្ងន់ លោកថ្វាយដល់ភិក្ខុអ្នកជាសភាគគ្នា បរិភោគភោជនដែលជាសប្បាយពីដៃ

របស់ភិក្ខុអ្នកជាសភាគគ្នានោះ ធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាពលសន្តោសក្នុងបិណ្ឌបាត ។ ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដែលប្រណីត លោកគិតថា បិណ្ឌបាតនេះ សមគួរដល់ព្រះថេរៈដែលបួសយូរជាដើម ថ្វាយដល់ព្រះថេរៈទាំងនោះដូចចីវរ ឬកាន់យកបាត្រដែលជារបស់នៃព្រះថេរៈទាំងនោះ ត្រាច់ទៅបិណ្ឌបាតដោយខ្លួនឯង ហើយឆាន់អាហារលាយគ្នា ចាត់ថាជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនោះ ឈ្មោះថា យថាសារុប្បសន្តោសក្នុងបិណ្ឌបាត ។

ក៏សេនាសនៈដែលដល់ភិក្ខុក្នុងព្រះធម៌វិន័យនេះ នឹងជាទីពេញចិត្ត ឬមិនពេញចិត្តក៏ដោយ ដោយហោចទៅកុដិដែលប្រក់ដោយស្មៅក្តី ដែលក្រាលដោយស្មៅក្តី លោករមែងត្រេកអរដោយសេនាសនៈនោះឯង ឬសេនាសនៈដទៃដែលល្អជាងដែលមកដល់ទៀត ក៏មិនទទួល អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាលាភសន្តោសក្នុងសេនាសនៈ ។ ក៏កាលលោកអាពាធមានរាងកាយទុព្វល បានសេនាសនៈដែលគួរជៀសវៀងតាមប្រក្រតី ឬគួរជៀសវៀងដល់ព្យាធិ កាលនៅ

ក៏មិនមានសេចក្តីសប្បាយ លោកថ្វាយសេនាសនៈនោះដល់ភិក្ខុដែលជាសភាគគ្នា ចេញទៅនៅក្នុងសេនាសនៈដែលជាសប្បាយ ជារបស់ភិក្ខុដែលជាសភាគគ្នានោះ ធ្វើសមណធម៌ ក៏ចាត់ថា ជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាពលសន្តោសក្នុងសេនាសនៈ ។ ភិក្ខុមួយរូបទៀតមិនទទួលសេនាសនៈដែលល្អ សូម្បីដែលចូលដល់(ខ្លួន) ដោយគិតថា សេនាសនៈនេះជារបស់ប្រណីត ជាទីតាំងនៃសេចក្តីប្រមាទ ឬបានសេនាសនៈដែលប្រណីត មានល្ហាង មណ្ឌប និងកូដាគារជាដើម ព្រោះតម្លៃដែលលោកមានបុណ្យច្រើន លោកថ្វាយសេនាសនៈទាំងនោះដល់ព្រះថេរៈអ្នកបួសយូរជាដើម ដូចចីវរជាដើម សូម្បីនឹងនៅក្នុងទីណាមួយ ក៏ចាត់ថា ជាអ្នកសន្តោសដោយពិត អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាសារុប្បសន្តោសក្នុងសេនាសនៈ ។

មួយទៀត ភិក្ខុក្នុងព្រះធម៌វិន័យនេះ បានភេសជ្ជៈសៅហ្មង ឬប្រណីត លោកត្រេកអរដោយភេសជ្ជៈនោះឯងមិនប្រាថ្នាភេសជ្ជៈដទៃ សូម្បីបានក៏មិនទទួល អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថាលាភសន្តោសក្នុងគិលានបច្ច័យ ។

ក៏គ្រាលោកត្រូវការប្រេង បានទឹកអំពៅ លោកថ្វាយទឹកអំពៅនោះដល់ភិក្ខុដែលជាសភាគគ្នា ប្រកបភេសជ្ជៈដោយប្រេងអំពីដៃរបស់ភិក្ខុដែលជាសភាគគ្នានោះ ធ្វើសមណធម៌ ក៏ចាត់ថាជាអ្នកសន្តោសពិត អាការរបស់ភិក្ខុនោះនេះ ឈ្មោះថា យថា-ពលសន្តោសក្នុងគិលានបច្ច័យ ។ ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានភេសជ្ជៈដែលប្រណីត មានប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើមជាច្រើន លោកថ្វាយភេសជ្ជៈនោះ ដល់ព្រះ-ថេរៈដែលបួសយូរជាដើម ដូចចីវរជាដើម ប្រកបភេសជ្ជៈដោយវត្ថុយ៉ាងណាមួយដែលខ្លួនបានមកដល់ព្រះថេរៈទាំងនោះ ក៏ចាត់ថា ជាអ្នកសន្តោសពិត ចំណែកភិក្ខុណា ដាក់សម៉ត្រាំដោយទឹកមូត្រស្អុយ ក្នុងភាជនៈមួយ ដាក់ចតុមធុរសទុកក្នុងភាជនៈមួយ កាលគេនិយាយថា វត្ថុណាដែលលោកត្រូវការយកទៅចុះ ទទួលបើភោគរបស់លោក រម្ងាប់ទៅដោយភេសជ្ជៈណាមួយបណ្ដាភេសជ្ជៈទាំងនោះ លោករលឹកដល់ព្រះតម្រាស់ថា ឈ្មោះថា សម៉ត្រាំដោយទឹកមូត្រស្អុយនេះ បណ្ឌិតមានព្រះពុទ្ធជាដើម សរសើរហើយ បព្វជ្ជាអាស្រ័យភេសជ្ជៈ ដែលត្រាំដោយទឹកមូត្រស្អុយ លោកគប្បីធ្វើសេចក្ដីឧស្សាហ៍ក្នុង

សេចក្តីនោះរហូតអស់មួយជីវិតចុះ ទើបហាមចតុមធុរសប្រកប
កេសជ្ជៈដោយសម៉ត្រាំដោយទឹកមូត្រស្អុយ ចាត់ថាជាអ្នក
សន្តោសយ៉ាងក្រៃលែងតែម្តង អាការរបស់ភិក្ខុនោះនេះ
ឈ្មោះថា យថាសារុប្បសន្តោសក្នុងគិលានបច្ច័យ ។ សន្តោស
ទាំងអស់ដែលមានប្រភេទ ដូចពោលហើយនោះ លោកហៅថា
**សន្តុដ្ឋី** ។ ដោយហេតុនោះ លោកទើបពោលថា ដោយអត្ថក៏គឺ
**ឥតរីតរបច្ចយសន្តោស** សន្តោសដោយបច្ច័យតាមមានតាម
បាន ។ កថាដែលប្រព្រឹត្តទៅដោយអំណាចប្រកាសអានិសង្ស
របស់សន្តុដ្ឋិនោះ ព្រមទាំងវិធីដែលចង្អុលបង្ហាញជាដើម និង
ដោយអំណាចប្រកាសទោសរបស់ភិក្ខុ អ្នកធ្លាក់នៅក្នុងសេចក្តី
ចង់បាន ដែលផ្សេងដោយសេចក្តីប្រាថ្នាច្រើនជាដើម ដែលជា
បដិបក្ខចំពោះសេចក្តីសន្តោសនោះ ឈ្មោះថា **សន្តុដ្ឋិកថា** ។
សូម្បីក្នុងកថាដទៃពីនេះ ក៏ន័យនេះដូចគ្នា ។ ខ្ញុំនឹងពោល
ត្រឹមតែសេចក្តីប្លែកគ្នាប៉ុណ្ណោះ ។

វិវេក ក្នុងបទថា **បវិវេកកថា** នេះ មាន ៣ យ៉ាង គឺ
កាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។ ក្នុង ៣ យ៉ាងនោះ
សេចក្តីដែលភិក្ខុលះការនៅប្រឡូកប្រឡល់ដោយពួក ហើយនៅ

ស្ងាត់ក្នុងកិច្ចទាំងពួង ក្នុងគ្រប់ឥរិយាបថយ៉ាងនេះគឺ ទៅម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង ដេកម្នាក់ឯង ចូលទៅកាន់ស្រុកបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង ដើរទៅមុខម្នាក់ឯង (អង្គុយនៅក្នុងទីស្ងាត់ម្នាក់ឯង) អធិដ្ឋានទីចង្ក្រមម្នាក់ឯង ត្រាច់ទៅម្នាក់ឯង នៅម្នាក់ឯង ឈ្មោះថា **កាយវិវេក** ។ មួយទៀត សមាបត្តិ ៨ ឈ្មោះថា **ចិត្តវិវេក** ។ ព្រះនិព្វាន ឈ្មោះថា **ឧបធិវិវេក** ។ សមពិត ដូចពាក្យដែលលោកពោលទុកថា ៖

**កាយវិវេក** (កើតមាន) ដល់ពួកបុគ្គលអ្នកចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង, **ចិត្តវិវេក** (កើតមាន) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធិ ដល់នូវសេចក្តីផូរផង់ក្រៃលែងផង, **ឧបធិវិវេក** (កើតមាន) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វាន ដែលប្រាសចាកសង្ខារផង[១] ។ វិវេកនោះឯង គឺ **បវិវេក** ។ កថាដែលជាប់ដោយសេចក្តីស្ងាត់ ឈ្មោះថា **បវិវេកកថា** ។

**សំសគ្គា** ក្នុងបទ **អសំសគ្គកថា** នេះ មាន ៥ យ៉ាង

---

១ សុត្តន្តបិដក លេខ ៦៤ ទំព័រ៤៩ ក្នុងគុហដ្ឋកសូត្រ ។

គឺ សវនសំសគ្គៈ ១ ទស្សនសំសគ្គៈ ១ សមុល្លបនសំសគ្គៈ ១ សម្ភោគសំសគ្គៈ ១ កាយសំសគ្គៈ ១, ក្នុង ៥ យ៉ាងនោះ ភិក្ខុរូបខ្លះ ក្នុងព្រះធម៌វិន័យនេះ បានឮថា ស្រីក្នុងស្រុក ឬនិគមឯណោះ មានរូបល្អ គួរសរសើរ គួរជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរកាយល្អយ៉ាងក្រៃលែង លោកបានឮដូចនោះហើយ (មានចិត្ត) ជ្រួតជ្រាបទៅ ផ្សាយទៅ មិនអាចនឹងតាំងព្រហ្មចរិយបាន ទើបលាសិក្ខាជាគ្រហស្ថ សេចក្តីស្និទ្ធស្នាលដោយកិលេសកើតឡើង ដោយបានស្តាប់វិសភាគារម្មណ៍ ដោយអាការយ៉ាងនេះ ឈ្មោះថា **សវនសំសគ្គៈ** ។ ភិក្ខុមិនបានស្តាប់ដូច្នោះទេ លោករមែងឃើញស្រីល្អនោះឯងគួរមើល គួរជ្រះថ្លា ប្រកបដោយសម្បុរកាយស្រស់ល្អយ៉ាងក្រៃលែង លោកលួចមើលប៉ុណ្ណោះ (មានចិត្ត) ជ្រួតជ្រាបទៅ ផ្សាយទៅ មិនអាចនឹងតាំងព្រហ្មចរិយបាន ទើបលាសិក្ខាជាគ្រហស្ថ សេចក្តីស្និទ្ធស្នាលដោយកិលេសដែលកើតឡើង ដោយបានឃើញវិសភាគារម្មណ៍ ដោយអាការយ៉ាងនេះ ឈ្មោះថា **ទស្សនសំសគ្គៈ** ។ ក៏ឯព្រោះបានឃើញ សេចក្តីស្និទ្ធស្នាលដោយកិលេស កើតឡើងដោយការចរចាប្រាស្រ័យគ្នានឹងគ្នា

ឈ្មោះថា **សមុល្លបនសំសគ្គៈ** ។ ដោយការចរចាប្រាស្រ័យនេះឯង ទើបរួមចូលជាមួយនឹងការចូលជិតជាដើមក៏បាន ។ ក៏ព្រោះវត្ថុណាមួយជារបស់ខ្លួនដែលឲ្យក៏ដោយ មិនឲ្យក៏ដោយដល់មាតុគ្រាម សេចក្ដីស្និទ្ធស្នាល ដោយកិលេសកើតឡើងដោយការឲ្យវត្ថុដែលមានតម្លៃដែលខ្លួនឲ្យជាដើម ឈ្មោះថា **សម្ភោគសំសគ្គៈ** ។ សេចក្ដីស្និទ្ធស្នាលដោយកិលេសកើតឡើង ដោយការចាប់ដៃមាតុគ្រាមជាដើម ឈ្មោះថា **កាយ-សំសគ្គៈ** ។ សេចក្ដីដែលភិក្ខុលះការច្របូកច្របល់ដោយគ្រហស្ថដែលមិនប្រព្រឹត្តទៅតាមអនុលោម និងការច្របូក-ច្របល់ ដែលជាហេតុកើតកិលេស នឹងសម្លាញ់សព្រហ្មចារីទាំងឡាយ ដែលលោកពោលទុកយ៉ាងនេះថា ភិក្ខុច្របូក-ច្របល់ដោយគ្រហស្ថ មានការច្របូកច្របល់ដែលមិនប្រព្រឹត្តទៅតាមអនុលោម មានសោកជាមួយគ្នា ត្រេកអរជាមួយគ្នាកាលគេសុខក៏សុខ កាលគេទុក្ខក៏ទុក្ខ ដល់សេចក្ដីខ្វល់ខ្វាយក្នុងករណីយកិច្ចដែលកើតឡើងដោយខ្លួនឯង ដូច្នេះ ទាំងអស់ចេញបាន ចូលទៅតាំងចំពោះនូវធម៌ទាំងពួង គឺសេចក្ដីសង្វេគក្នុងសង្សារដែលមាំមួនជាង សេចក្ដីសម្គាល់ក្នុងវត្ថុដែលមាន

សង្ខារ ជាជាភ័យយ៉ាងខ្លាំងក្លា សេចក្ដីសម្គាល់ក្នុងរាងកាយថា ជាវត្ថុបដិកូល មានហិរិនិងឱត្តប្បៈដែលមានការខ្ពើមរអើមអកុសលទាំងអស់ ជាតួនាំមុខ ទាំងមានសតិនិងសម្បជញ្ញៈ ក្នុងការធ្វើគ្រប់យ៉ាង ហើយមិនមានសេចក្ដីជាប់ជំពាក់ក្នុងធម៌ទាំងពួង ដូចតំណក់ទឹកមិនជាប់លើស្លឹកឈូកដូច្នោះនេះ ឈ្មោះថា **អសំសគ្គៈ** ព្រោះជាបដិបក្ខចំពោះសំសគ្គៈទាំងពួង កថាដែលជាប់ដោយអសំសគ្គៈ ឈ្មោះថា **អសំសគ្គកថា** ។

ក្នុងបទថា **វីរិយារម្ភកថា** នេះ មានវិនិច្ឆ័យដូចតទៅនេះ ។ ភាវៈនៃបុគ្គលដែលក្លៀវក្លា ឬកម្មនៃបុគ្គលដែលក្លៀវក្លា ព្រោះដូច្នោះ ទើបឈ្មោះថា វីរិយៈ, ម្យ៉ាងទៀត ឈ្មោះថា វីរិយៈ ព្រោះដែលបុគ្គលគប្បីឲ្យដំណើរការទៅ គឺគប្បីឲ្យប្រព្រឹត្តទៅតាមវិធី ក៏សេចក្ដីព្យាយាមនោះ គឺការចាប់ផ្ដើមដើម្បីលះអកុសលធម៌ (និង)ឲ្យកុសលធម៌កើតឡើង ឈ្មោះថា វីរិយារម្ភៈ ប្រារព្ធសេចក្ដីព្យាយាម ។ វីរិយារម្ភៈនោះ មាន ២ យ៉ាង គឺ ប្រព្រឹត្តទៅផ្លូវកាយ ១ ប្រព្រឹត្តទៅផ្លូវចិត្ត ១, មាន ៣ យ៉ាង គឺ អារម្ភធាតុ ១ និក្កមធាតុ ១ បរក្កមធាតុ ១, មាន ៤ យ៉ាង ដោយអំណាចសម្មប្បធាន ៤ ។ វីរិយារម្ភៈទាំងអស់នោះ គប្បី

ជ្រាបដោយអំណាចការប្រារព្ធសេចក្ដីព្យាយាមយ៉ាងនេះ របស់ភិក្ខុអ្នកមិនឲ្យកិលេសដែលកើតឡើង ក្នុងពេលដើរដល់ពេលឈរ ដែលកើតក្នុងពេលឈរមិនឲ្យដល់ពេលអង្គុយ ដែលកើតឡើងក្នុងពេលអង្គុយមិនឲ្យដល់ពេលដេក គ្របសង្កត់ដោយកម្លាំងសេចក្ដីព្យាយាម មិនឲ្យងើបក្បាលឡើងបានក្នុងឥរិយាបថនោះៗ ដូចអ្នកយកឈើមានលក្ខណៈដូចជើងពពែទុក និងដូចយកដាវដ៏មុត កាប់កសត្រូវដូច្នោះ ។ កថាដែលជាប់ដោយវីរិយារម្ភៈនោះ ឈ្មោះថា វីរិយារម្ភកថា ។

សីលក្នុងបទថា សីលកថាជាដើម មាន ២ យ៉ាង គឺ លោកិយសីល ១ លោកុត្តរសីល ១ ។ ក្នុងសីល ២ យ៉ាងនោះ លោកិយសីល បានដល់ បារិសុទ្ធិសីល ៤ មានបាតិមោក្ខសំវរសីលជាដើម ។ លោកុត្តរសីល បានដល់ មគ្គសីលនិងផលសីល ។ មួយទៀត សមាបត្តិ ៨ ព្រមដោយឧបចារៈដែលជាបាទនៃវិបស្សនា ឈ្មោះថា លោកិយសមាធិ ក៏ក្នុងទីនេះ សមាធិដែលសម្បយុត្តដោយមគ្គ ឈ្មោះថា លោកុត្តរសមាធិ ។ ចំណែកបញ្ញាក៏ដូចគ្នា ដែលសម្រេចដោយការស្ដាប់ សម្រេចដោយការគិត ដែលសម្បយុត្តដោយឈាន និង

វិបស្សនាញាណ ចាត់ជាលោកិយបញ្ញា តែក្នុងទីនេះ កាល ពោលដោយពិសេស គប្បីកាន់យកវិបស្សនាបញ្ញា ។ បញ្ញា ដែលសម្បយុត្តដោយមគ្គនិងផល ចាត់ជាលោកុត្តរបញ្ញា ។ សូម្បីវិមុត្តិ ក៏បានដល់ វិមុត្តិដែលសម្បយុត្តដោយអរិយផល និងនិព្វាន ។ ចំណែកអាចារ្យមួយពួកទៀត ពណ៌នាសេចក្ដីក្នុង សេចក្ដីនេះទុក ដោយអំណាចសូម្បីតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ និង សមុច្ឆេទវិមុត្តិ ។ សូម្បីវិមុត្តិញាណទស្សនៈ ក៏បានដល់បច្ច-វេក្ខណញ្ញាណ ១៩ ។ កថាដែលប្រព្រឹត្តទៅដោយអំណាចការ ប្រកាសទោស និងអានិសង្ស មានអាការជាអនេកនៃគុណមាន សីលជាដើមទាំងនេះ ព្រមដោយវិធីមានការចន្លុលបង្ហាញ ជាដើម និងដោយអំណាចការប្រកាសទោសនៃសេចក្ដីជាអ្នក ទ្រុស្តសីលជាដើម ដែលជាសត្រូវចំពោះគុណមានសីលជា-ដើមនោះ ឬកថាដែលជាប់ដោយអានិសង្ស និងទោសរបស់ សីលនោះ ឈ្មោះថា កថាពោលអំពីសីលជាដើម ។

ក៏ក្នុងទីនេះ ព្រោះព្រះបាលីមានជាដើមថា ភិក្ខុជាអ្នក ប្រាថ្នាតិចដោយខ្លួនឯង ទាំងធ្វើកថាពោលដោយសេចក្ដីប្រាថ្នា តិចដល់អ្នកដទៃ និងឈ្មោះថា ជាអ្នកសន្តោសដោយចីវរតាម

មានតាមបាន ទាំងប្រកាសគុណនៃសេចក្ដីសន្ដោសដោយចីវរតាមមានតាមបាន កថាបែបនោះ ដែលភិក្ខុអ្នកប្រកបដោយគុណ មានភាពជាអ្នកប្រាថ្នាតិចជាដើម ដោយខ្លួនឯង គប្បីឲ្យទោសប្រព្រឹត្តទៅតាមអធ្យាស្រ័យជួយសង្គ្រោះ សូម្បីដល់អ្នកពួកដទៃ ដើម្បីប្រយោជន៍ដល់សេចក្ដីប្រាថ្នាតិច និងសន្ដោសនោះ ដែលលោកពោលទុកដោយពិសេសដោយភាពជាអ្នកដុសខាត់យ៉ាងក្រៃលែងជាដើមក្នុងទីនេះ គប្បីជ្រាបថា កថាពោលដោយសេចក្ដីប្រាថ្នាតិចជាដើម ។ ពិតមែន កថារបស់អ្នកធ្វើនុ៎ះឯង រមែងធ្វើប្រយោជន៍តាមដែលប្រាថ្នាឲ្យសម្រេចដោយពិសេស ។ សមពិតដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ ។ល។ ជាការបានដោយមិនលំបាក" ។

បទថា ឯវរូបាយ បានដល់ ដូច្នេះ គឺតាមដែលពោលហើយ ។ បទថា និកាមលាភី សេចក្ដីថា ជាអ្នកបានតាមប្រាថ្នា គឺបានតាមសេចក្ដីពេញចិត្ត បានដល់ បានតាមសប្បាយ ដើម្បីនឹងស្ដាប់ និងពិចារណាកថាទាំងនេះគ្រប់វេលា ។ បទថា អកិច្ឆលាភី បានដល់ ជាអ្នកបានដោយមិនលំបាក ។

បទថា អកាសិរលោភី បានដល់ ជាអ្នកបានដោយបរិបូរណ៍ ។

បទថា អារទ្ធវីរិយោ បានដល់ ផ្គងសេចក្ដីព្យាយាមទុក ។ បទថា អកុសលានំ ធម្មានំ បហានាយ បានដល់ ដើម្បីលះបង់បាបធម៌ ដែលឈ្មោះថា អកុសល ព្រោះអត្ថថា កើតពីភាពជាអ្នកមិនឆ្លាត ។ បទថា កុសលានំ ធម្មានំ បានដល់ ធម៌ដែលសម្បយុត្តដោយមគ្គនិងផល ព្រមទាំងវិបស្សនា ដែលឈ្មោះថា កុសល ព្រោះអត្ថថា កាត់បាបធម៌ដែលបណ្ឌិតស្អប់ខ្ពើមជាដើម និងព្រោះអត្ថថា មិនមានទោស ។ បទថា ឧបសម្បទាយ បានដល់ ឲ្យដល់ព្រម គឺឲ្យកើតឡើងក្នុងសន្ដានខ្លួន ។ បទថា ថាមវា បានដល់ អ្នកប្រកបដោយកម្លាំងសេចក្ដីព្យាយាម ពោលគឺសេចក្ដីឧស្សាហ៍ ។ បទថា ទឡ្ហបរក្កមោ បានដល់ មានសេចក្ដីព្យាយាមមាំ គឺមានសេចក្ដីព្យាយាមមិនអន់ថយ ។

បទថា បញ្ញវា បានដល់ អ្នកមានបញ្ញាដោយបញ្ញាដែលសម្បយុត្តដោយវិបស្សនា ។ បទថា ឧទយត្ថគាមិនិយា បានដល់ ត្រាស់ដឹងដល់ការកើតឡើង និងសេចក្ដីរលត់ទៅនៃ

បញ្ចេខន្ធ ។ បទថា អរិយាយ បានដល់ ឃ្លាតឆ្ងាយ គឺតាំងនៅក្នុងទីឆ្ងាយចាកកិលេស ដោយអំណាចវិក្ខម្ភនវិមុត្តិ គឺប្រាសចាកទោស ។

បទថា និព្វេធិកាយ ប្រែថា ជាចំណែកនៃការត្រាស់ដឹង ។ បទថា សម្មាទុក្ខក្ខយាគាមិនិយា បានដល់ សម្រេចដោយប្រពៃគឺ ដោយហេតុ ដោយន័យនូវអរិយមគ្គដែលបាននាមថា ទុក្ខក្ខយៈ ព្រោះធ្វើវដ្តទុក្ខឲ្យអស់ទៅ ។

ក៏ឯក្នុងធម៌ ៥ ប្រការទាំងនេះ សីល វីរិយៈ និងបញ្ញាជាអង្គខាងក្នុង, អង្គ ២ ក្រៅនេះជាអង្គខាងក្រៅ សម្រាប់ព្រះ-យោគី សូម្បីយ៉ាងនោះព្រះយោគីក៏នៅប្រាថ្នាធម៌ ៤ ប្រការក្រៅនោះ ព្រោះជាទីអាស្រ័យរបស់កល្យាណមិត្តទុំះឯង ។ ក្នុងទីនេះ ព្រះសាស្តាកាលទ្រង់សម្តែងថា កល្យាណមិត្តទុំះឯង ជាអ្នកមានឧបការៈច្រើន ទើបទ្រង់បន្ថែមព្រះធម៌-ទេសនាដោយន័យមានជាដើមថា ម្នាលមេឃិយៈ គុណជាតទុំះរមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ បានដោយមិន-លំបាក ។

បណ្តាបទទាំងនោះ បទថា ចាដិកង្ខំ ប្រែថា គប្បីប្រាថ្នា

ដោយចំណែកតែមួយ អធិប្បាយថា មានការៈពិតប្រាកដ ។ បទថា យំ ជាកិរិយាបរាមាស ។ លោកអធិប្បាយពាក្យនេះថា ក្នុងពាក្យថា សីលវា ភវិស្សតិ នេះ មានអធិប្បាយថា ការដែលភិក្ខុជាអ្នកមានមិត្តល្អ មានសីល គឺបរិបូរណ៍ដោយសីលនោះ គប្បីប្រាថ្នាបាន ព្រោះភិក្ខុនោះ ជាអ្នកបរិបូរណ៍ដោយសីល គឺជាអ្នកមានការៈពិតប្រាកដ ព្រោះបបួលលោកក្នុងសេចក្ដីនោះ ដោយពិតប្រាកដតែម្ដង ។ សូម្បីក្នុងពាក្យថា ចាតិមោក្ខសំវរសំវុតោ វិហរិស្សតិ ដូច្នេះជាដើមក៏ន័យនេះដូចគ្នា ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងសាសនសម្បត្តិទាំងអស់ ដោយភាពជាអ្នកមានកល្យាណមិត្តជាដើម តែព្រះមេឃិយៈអ្នកមិនអើពើព្រះតម្រាស់របស់ព្រះអង្គ ទ្រង់ជាកល្យាណមិត្តដ៏ខ្ពស់បំផុត ក្នុងលោកព្រមទាំងទេវលោក ហើយចូលទៅកាន់ព្រៃស្រោងនោះ ដល់ប្រការដែលប្លែកដូច្នោះ ឥឡូវនេះ ទើបទ្រង់ប្រកាសការនាន័យ ដល់លោកអ្នកកើតសេចក្ដីអើពើក្នុងព្រៃស្រោងនោះ ព្រោះលោកត្រូវកាមវិតក្កៈជាដើមប្រទូសរ៉ាយក្នុងគ្រាមុន និងព្រោះកាមវិតក្កៈជាដើមទាំងនោះ ជាសត្រូវ

ដោយត្រង់ចំពោះកម្មដ្ឋាន ទើបមិនសម្រេចដល់លោក, តអំពីនោះកាលនឹងត្រាស់ប្រាប់កម្មដ្ឋាននៃព្រះអរហត្ត ទើបត្រាស់ពាក្យមានជាដើមថា “ម្នាលមេឃិយៈ មួយទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ ៥ យ៉ាងនេះហើយ ត្រូវចម្រើនធម៌ ៤ យ៉ាងតទៅទៀត” ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា តេន បានដល់ អ្នកប្រកបដោយគុណមានសីលជាដើមតាមដែលពោលហើយ ដោយមានកល្យាណមិត្តជាទីអាស្រ័យយ៉ាងនេះ ។ ដោយហេតុនោះឯងទើបត្រាស់ថា តាំងនៅក្នុងធម៌ ៥ យ៉ាងទាំងនេះជាដើម ។ បទថា ឧត្តរឹ សេចក្តីថា បើអន្តរាយមានរាគៈជាដើម គប្បីកើតឡើងដល់អ្នកប្រារព្ធតរុណវិបស្សនា ដើម្បីជម្រះអន្តរាយទាំងនោះឲ្យហ្មត់ចត់ ខាងមុខអំពីនោះត្រឹមតែចម្រើន គឺធ្វើឲ្យកើតនិងកពូនធម៌ ៤ ប្រការនោះ ។ បទថា អសុភា បានដល់ចម្រើនអសុភកម្មដ្ឋានយ៉ាងណាមួយតាមសមគួរ បណ្តាអសុភ-កម្មដ្ឋានក្នុងឯកទេសមួយ ។ បទថា រាគស្ស បហានាយ បានដល់ ដើម្បីលះបង់កាមរាគៈ ។ បណ្ឌិតគប្បីប្រកាសសេចក្តីនេះ ដោយឧបមាបុគ្គលដែលច្រូតស្រូវសាលី ។

ពិតមែន ប្រុសម្នាក់កាន់កណ្ដៀវច្រូតស្រូវសាលី ក្នុងស្រែស្រូវសាលី តាំងពីទីបំផុតទៅ គ្រាពួកគោហែករបងរបស់គេចូលទៅ គេក៏ដាក់កណ្ដៀវកាន់ឈើដេញគោឲ្យចេញទៅដោយផ្លូវនោះឯង ហើយធ្វើរបងឲ្យដូចពីដើមហើយកាន់កណ្ដៀវច្រូតស្រូវសាលីទៀត ។

ក្នុងឧបមាប្រការនោះ ព្រះពុទ្ធសាសនា គប្បីឃើញដូចស្រែស្រូវសាលី ព្រះយោគាវចរដូចអ្នកច្រូតស្រូវ មគ្គបញ្ញាដូចកណ្ដៀវ វេលាធ្វើកម្មក្នុងវិបស្សនាដូចវេលាច្រូត អសុភកម្មដ្ឋានដូចឈើ សំវរៈដូចរបង ការដែលរាគៈកើតឡើងព្រោះអាស្រ័យសេចក្ដីប្រមាទ ដោយមិនពិចារណាពេលភ្លាមនោះដូចការដែលគោទាំងឡាយទម្លាយរបងទៅ វេលាដែលគ្រប សង្កត់រាគៈដោយអសុភកម្មដ្ឋាន ហើយផ្ដើមធ្វើកម្មក្នុងវិបស្សនាទៀត គប្បីឃើញដូចអ្នកច្រូតស្រូវ ដាក់កណ្ដៀវកាន់ឈើដេញគោឲ្យចេញទៅ ដោយផ្លូវដែលចូលមកនុ៎ះឯង ធ្វើរបងឲ្យដូចពីដើមហើយច្រូតស្រូវតាំងពីកន្លែងដែលខ្វះនយរទៀត ក្នុងសេចក្ដីនេះ មានការប្រៀបផ្ទឹមឧបមាដូចពោលមកនេះ ។ ទ្រង់សំដៅយកការនាវិធីដែលដូចពោលមកនេះ ទើបត្រាស់ថា

គប្បីចម្រើនអសុភៈ ដើម្បីលះរាគៈ ។

បទថា មេត្តា បានដល់ កម្មដ្ឋានមានមេត្តាជាអារម្មណ៍ ។ បទថា ព្យាបាទស្ស បហានាយ បានដល់ ដើម្បីលះសេចក្តីក្រោធដែលកើតឡើង ដោយន័យដូចពោលហើយនុ៎ះឯង ។ បទថា អានាបានស្សតិ បានដល់ អានាបានស្សតិដែលមានវត្ថុ ១៦ ។ បទថា វិតក្កុបច្ឆេទាយ បានដល់ ដើម្បីកាត់វិតក្កដែលកើតឡើងហើយ ដោយន័យដូចពោលហើយនុ៎ះឯង ។ បទថា អស្មិមានសមុគ្ឃាតាយ បានដល់ ដើម្បីដកមានៈ ៩ យ៉ាង ដែលកើតឡើងថា យើងមាន ។ បទថា អនិច្ចសញ្ញិនោ បានដល់ អ្នកមានសេចក្តីសម្គាល់ថា មិនទៀង ដោយអនិច្ចានុបស្សនាដែលប្រព្រឹត្តទៅថា សង្ខារទាំងពួង ឈ្មោះថា មិនទៀង ព្រោះមានហើយត្រឡប់មិនមាន ព្រោះមានការកើតឡើងនិងរលត់ទៅជាទីបំផុត ព្រោះមានការបែកធ្លាយ ព្រោះប្រព្រឹត្តទៅមួយខណៈៗ ព្រោះបដិសេធសេចក្តីជារបស់ទៀង ។ បទថា អនត្តសញ្ញា សណ្ឋាតិ បានដល់ អនត្តសញ្ញា ពោលគឺអនត្តានុបស្សនាដែលប្រព្រឹត្តទៅយ៉ាងនេះថា ធម៌ទាំងពួង

ឈ្មោះថា ជាអនត្តា ព្រោះមិនមានខ្លឹមសារ ព្រោះមិនប្រព្រឹត្ត ទៅក្នុងអំណាច ព្រោះជារបស់ដទៃ ព្រោះជារបស់សោះសូន្យទទេ និងព្រោះសូន្យ រមែងមិនតាំងនៅ គឺមិនតាំងមាំនៅក្នុងចិត្ត ។ ពិតមែន កាលឃើញអនិច្ចលក្ខណៈ ក៏ជាកាលដែលឈ្មោះថា ឃើញអនត្តលក្ខណៈដូចគ្នា ។ ក៏បណ្ដាលក្ខណៈទាំង ៣ កាលឃើញលក្ខណៈមួយ ក៏ជាកាលដែលឈ្មោះថា ឃើញលក្ខណៈ ២ យ៉ាងក្រៅនេះដូចគ្នា ។ ដោយហេតុនោះ ទើបត្រាស់ថា "ម្នាលមេឃិយៈ ព្រោះថា កាលភិក្ខុមានសេចក្ដីសម្គាល់ថា មិនទៀងហើយ សេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងតាំងនៅ (ក្នុងចិត្ត)" ។ កាលឃើញអនត្តលក្ខណៈ មានះដែលកើតឡើងថា យើងមាន ក៏ឈ្មោះថា លះបានផងនុ៎ះឯង ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា ភិក្ខុដែលមានសេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងដល់នូវការដកអស្មិមានះចេញបាន ។ បទថា ទិដ្ឋេវ ធម្មេ និព្វានំ សេចក្ដីថា រមែងសម្រេចព្រះនិព្វាន ដែលមិនមានបច្ច័យក្នុងបច្ចុប្បន្ននេះឯង គឺក្នុងអត្តភាពនេះឯង ។ ក្នុងទីនេះមានសេចក្ដីសង្ខេបត្រឹមតែប៉ុណ្ណោះ តែកាលពោលដោយពិស្ដារ ន័យនៃការនាដែល

ពោលដោយអសុភកម្មដ្ឋានជាដើម អ្នកត្រូវការ គប្បីត្រួតមើលដោយន័យដែលពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា ឯតមត្ថំ វិទិត្វា សេចក្តីថា ទ្រង់ជ្រាបសេចក្តីនេះ ពោលគឺការដែលព្រះមេឃិយៈត្រូវពួកចោរគឺ មិច្ឆាវិតក្កប្លន់កណ្ឋៈ គឺកុសល ។ បទថា ឥមំ ឧទានំ សេចក្តីថា ទ្រង់បន្លឺឧទាននេះ ដែលសម្តែងទោសក្នុងការមិនបន្ទោបង់កាមវិតក្កជាដើម និងអានិសង្ស ក្នុងការបន្ទោបង់កាមវិតក្កជាដើម ។

បណ្តាបទទាំងនោះ បទថា ខុទ្ទា បានដល់ អាក្រក់គឺលាមក ។ បទថា វិតក្កា បានដល់ បាបវិតក្ក (អកុសលវិតក្ក) ៣ មានកាមវិតក្កជាដើម ។ ក៏អកុសលវិតក្កទាំងនោះលោកហៅ **ខុទ្ទៈ** ក្នុងទីនេះ ព្រោះត្រូវវិតក្កទាំងពួងធ្វើឲ្យអាក្រក់ដូចក្នុងប្រយោគមានជាដើមថា មិនគប្បីប្រព្រឹត្តអាក្រក់ ។ បទថា សុខុមា លោកប្រាថ្នាយកសេចក្តីត្រិះរិះដល់ញាតិជាដើម ។ ក៏វិតក្កទាំងនេះ គឺសេចក្តីត្រិះរិះដល់ញាតិ ត្រិះរិះដល់ជនបទ ត្រិះរិះដល់ទេវតា សេចក្តីត្រិះរិះដែលជាប់ទាក់ទងនឹងសេចក្តីអាណិតអ្នកដទៃ សេចក្តីត្រិះរិះដែលជាប់ដោយលាភសក្ការៈ និងឈ្មោះសំឡេង សេចក្តីត្រិះរិះដែលជាប់ទាក់ទងនឹង

សេចក្ដីមិនមើលងាយ រមែងមិនប្រទូស្តកម្លាំងដូចកាមវិតក្ក ជាដើម ព្រោះដូច្នោះ លោកទើបពោលថាសុខុមល្អិតល្អន់ ព្រោះ មានសភាវៈមិនគ្រោតគ្រាត ។ បទថា អនុគតា បានដល់ អនុវត្តន៍ទៅតាមចិត្ត ។ ពិតមែន កាលវិតក្កកើតឡើង ចិត្តក៏ទៅ តាមវិតក្កនោះឯង ព្រោះលើកវិតក្កនោះឡើងកាន់អារម្មណ៍ ។ បាលីថា អនុគ្គតា ដូច្នេះក៏មាន សេចក្ដីថា អនុដ្ឋិតា មិនតាំង មាំ ។ បទថា មនសោ ឧប្បិលាវា ប្រែថា ធ្វើចិត្តឲ្យរវើ- រវាយ ។ បទថា ឯតេ អវិទ្វា មនសោ វិតក្កេ សេចក្ដីថា មិនដឹងតាមសេចក្ដីពិតនូវមនោវិតក្ក មានកាមវិតក្កជាដើម ទាំងនោះ ដោយញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា, ដោយរលោស់ចេញចាកទោសគឺ សេចក្ដីត្រេកអរ ។ បទថា ហុរា ហុរំ ធាវតិ ភន្តចិត្តោ សេចក្ដីថា ឈ្មោះថា មាន ចិត្តមិនតាំងមាំ ព្រោះលះមិច្ឆាវិតក្កមិនបាន ទើបត្រាច់ទៅ គឺវិលទៅមកៗ ដោយអំណាចសេចក្ដីត្រេកអរជាដើម ក្នុង អារម្មណ៍នោះៗ ដោយន័យមានជាដើមថា "ពេលខ្លះក្នុងរូបា- រម្មណ៍ ពេលខ្លះក្នុងសទ្ទារម្មណ៍",ម្យ៉ាងទៀត បទថា ហុរា

ហុរំ ធាវតិ ភន្តចិត្តោ សេចក្ដីថា មានចិត្តវិលទៅដោយអំណាចអវិជ្ជា និងតណ្ហាដែលមានវិតក្កនោះជាហេតុ ព្រោះកំណត់វិតក្កមិនបាន ទើបត្រាច់ទៅ គឺអន្ទោលទៅមកៗ ដោយចុតិនិងបដិសន្ធិ អំពីលោកនេះទៅកាន់លោកខាងមុខ ។ បទថា ឃតេ ច វិទ្វា មនសោ វិតក្កេ សេចក្ដីថា តែដឹងតាមសេចក្ដីពិតដោយសេចក្ដីត្រេកអរជាដើម ដែលមនោ-វិតក្កមានកាមវិតក្កជាដើម មានប្រភេទតាមដែលពោលហើយនោះ ។ បទថា អាតាបិយោ ប្រែថា មានសេចក្ដីព្យាយាម ។

បទថា សំវរតិ ប្រែថា រមែងបិទ ។ បទថា សតិមា ប្រែថា បរិបូរណ៍ដោយសតិ ។ បទថា អនុគ្គតេ បានដល់មិនកើតឡើង ដោយអំណាចការបានដោយលំបាក ។ លោកពោលពាក្យអធិប្បាយនេះទុកថា ដឹងមនោវិតក្កមានកាមវិតក្កជាដើម មានប្រការដូចពោលហើយនោះថាជាសេចក្ដីរវើរវាយនៃចិត្ត ព្រោះជាហេតុធ្វើចិត្តឲ្យរវើរវាយ គឺដឹងដោយប្រពៃតែម្ដង ដោយមគ្គបញ្ញា ដែលប្រកបដោយវិបស្សនាញាណឈ្មោះថា អ្នកមានសេចក្ដីព្យាយាម មានសតិ ព្រោះមានសម្មាវាយាមៈ និងសម្មាសតិ ដែលមានមគ្គបញ្ញានោះ ជា

សម្លាញ់ បិទមនោវិតក្កទាំងនោះដែលគួរនឹងកើតទៅ មិនឲ្យកើត គឺមិនឲ្យផុសឡើងក្នុងខណៈមគ្គ ដោយអរិយមគ្គភាវនា គឺបិទការពារដោយញាណសំវរៈ បានដល់ កាត់ការប្រាកដ (របស់វិតក្កៈទាំងនោះ) ក៏ព្រះអរិយសាវកដែលជាយ៉ាងនោះ ឈ្មោះថា ពុទ្ធ ព្រោះដឹងសច្ចៈទាំង ៤ លះបង់ដាច់ គឺកាត់ដាច់កាមវិតក្កៈជាដើមទាំងនោះ ដោយមិនទៅសេសសល់ គឺមិនមានចំណែកនៅសេសសល់ ហេតុសម្រេចព្រះអរហត្ត ។ សូម្បីក្នុងបទនេះ អាចារ្យពួកខ្លះពោលថា អនុគតេ ដូច្នេះក៏មាន ។ សេចក្តីនៃបទ អនុគតេ នោះ បានពោលទុកក្នុងកាលក្រោយហើយនោះឯង ។

(ចាកអដ្ឋកថា បរមត្ថទីបនី)

៚ ចប់ ៚

## II. អត្ថបទកំណាព្យ

### ១-មិត្តប្លម ៤ ប្រការ

-អ្នកត្រូវស្គាល់មិត្តប្លម ៤ ប្រការ ដែលព្រះសាស្តាទ្រង់បានត្រាស់ទុក
វាតែងនាំព្រួយនាំឱ្យស្វាញស្វុក នាំឱ្យសោយទុក្ខនៅក្នុងអបាយ ។
-ទី១ មិត្តគិតតែប្រយោជន៍ខ្លួន ដឹងចុះណាស្ងួនគួរវៀរឱ្យឆ្ងាយ
យកច្រើនឱ្យតិច ពេលភ័យអន្តរាយ ទើបជួយខ្វល់ខ្វាយធ្វើកិច្ចការមិត្ត ។
-ទី២ មិត្តនោះល្អតែសម្តី ទទួលអ្វីៗដែលកន្លងពិត
កាលកិច្ចទាំងឡាយកើតឡើងដល់មិត្ត របស់ខូចពិតទើបសម្តែងអាង ។
-ទី៣ មិត្តនិ-យាយចាក់បណ្តោយ ខុសត្រូវក៏ដោយព្រមតាមគ្រប់យ៉ាង
ពោលគុណនៅមុខឬនៅជិតខាង ពោលទោសច្រើនយ៉ាងក្នុងទីកំបាំង ។
-ទី៤ ជាមិត្តក្នុងផ្លូវវិនាស បើអ្នកមិនជៀសនឹងរងទុក្ខខ្លាំង
ធ្លាក់ក្នុងការល្បែងដ៏មានកម្លាំង ដែលជាទីតាំងនៃក្តីប្រមាទ ។
-ល្បែងស្រាល្បែងភ្នាល់និងល្បែងច្រើនទៀត កុំយកខ្លួនបៀតវានាំខូចខាត
ត្រូវមានស្មារតីព្យាយាមសង្វាត ដោយមិនប្រមាទដើរតាមបណ្ឌិត ។
-មិត្តទាំង ៤ នេះអ្នកចូរចាំចុះ ជាមិត្តប្លមសោះអ្នកត្រូវចេះគិត
មុននឹងសេពគប់គួរតែពិនិត្យ ថានេះជាមិត្តប្លមឬមិត្តល្អ ។

ដោយភិក្ខុ **សុវណ្ណជោតោ ភ.ស.វ.**

# ២-មិត្តមានសន្តានល្អ ៤ ប្រការ

-មិត្តមានសន្តានល្អ ៤ ប្រការ ដែលព្រះសាស្តាទ្រង់សម្តែងហើយ
ចូរយើងរាល់គ្នាកុំបីកន្តើយ កុំធ្វើតោះតើយសិក្សាឱ្យចេះ ។
-ទី១ មិត្តមានឧបការៈ មានចិត្តស្មោះស្ម័គ្រពិតដោយវិសេស
ជួយរក្សាមិត្តដែលធ្វេសប្រហែស ជួយផ្តល់ចំណេះនិងភោគៈផង ។
-ទី២ នោះគឺមិត្តរួមសុខទុក្ខ នៅចំពោះមុខឬនៅក្រោយខ្នង
មានភ័យអន្តរាយចិត្តឥតមានហ្មង លះជីវិតផងជាមួយនឹងមិត្ត ។
-ទី៣ នោះមិញមិត្តប្រាប់ប្រយោជន៍ តិចច្រើនដោយហោចមានចិត្តស្មោះពិត
ឱ្យវៀរចាកបាបហើយឱ្យប្រព្រឹត្ត អំពើសុចរិតប្រាប់សួគ៌និព្វាន ។
-ទី៤ មិត្តមានសេចក្តីឈឺឆ្អាល ចិត្តស្រស់គ្រាកាលឥតមានលាក់លៀម
ជួយព្រួយជួយអរអ្វីដែលមិត្តមាន ឥតមានទាក់ទាមសរសើរគុណមិត្ត ។
-មិត្តទាំង ៤ នេះ សែនមានឧបការ សន្តានថ្លៃថ្លាគួរចូលទៅជិត
ស្និទ្ធស្នាលជាមួយនឹងរុងរឿងពិត ដែលពួកបណ្ឌិតស្គាល់ថាមិត្តល្អ ។

ដោយភិក្ខុ **សុវណ្ណជោតោ ភ.ស.វ.**

# ៣-ការគប់មិត្ត

-អហំ វីខ្ញុំនាមភួងសុវណ្ណ សូមលើកបុិចកាន់ចារអក្ខរា
រៀបរាប់រាយរាប់បានជាធមិអាចិ គ្រាន់គិតពិចារទុកជាគំនិត ។

-នៅក្នុងសាសនានៃព្រះសម្ពុទ្ធ ជាព្រះសុគតទ្រង់ត្រាស់ពីមិត្ត
នេះជាសំខាន់ក្នុងការប្រព្រឹត្តិ នឹងបានសុខពិតព្រោះសេពគប់ត្រូវ ។
-មិត្តមានច្រើនយ៉ាងដែលព្រះទ្រង់ត្រាស់ ជាក់ប្រាកដណាស់យើងកុំស្រងូវ
មិត្តបាបមិនល្អមានច្រើនពេកកូវ យល់ឱ្យត្រឹមត្រូវគួរវៀរបាបមិត្ត ។
-គប់ពាលនឹងនាំឱ្យយើងលិចលង់ ធ្លាក់ក្នុងអន្លង់នៃសង្សារពិត
តែប្រសិនបើគប់នឹងបណ្ឌិត រួចចាកទុក្ខពិតមិនមានអន្តរាយ ។
-គប់ជនថោកទាបនឹងសាបសូន្យឆាប់ នាំឱ្យយ៉ាកយ៉ាប់អស់កាលវែងឆ្ងាយ
នឹងសោយទុក្ខធំនៅក្នុងអបាយ ស្រេកទឹកឃ្លានបាយខ្លោចផ្សាខ្លាំងណាស់ ។
-គប់រកនូវជនដែលស្មើៗគ្នា ព្រះភគវាព្រះអង្គបានត្រាស់
តែងមិនសាបសូន្យពិតប្រាកដណាស់ ព្រោះធ្វើឱ្យច្បាស់នូវសីលជាអាទិ៍ ។
-បើគប់នូវជនដែលប្រសើរជាង ពិតជាមិនឃ្លៀងចាកពុទ្ធោវាទ
តែងចម្រើនឆាប់ព្រោះមិនប្រមាទ ខំប្រឹងសង្វាតប្រព្រឹត្តធម្មា ។

ដោយភិក្ខុ **សុវណ្ណជោតោ ភ.ស.ថ.**

## ៤-សេពគប់មិត្តល្អត្រាស់ដឹងធម៌ពិត

-មិត្តសម្លាញ់ល្អប្រកបដោយអង្គ មែនពិតព្រះអង្គទ្រង់ជាភគវា
បានសម្តែងប្រាប់ក្នុងសូត្រនានា មានគុណមហិមាប្រាំពីរប្រការ ។
-មិត្តធ្វើខ្លួនគួរឱ្យស្រឡាញ់ផង គួរគោរពផងដ៏មានឧបការ
គួរសរសើរផង និងលោកឧស្សាហ៍ ប្រដៅផងណានូវធម៌វិន័យ ។

-អត់ធន់ចំពោះពាក្យសម្ដីផង លោកឥតមានហ្មងកាយចិត្តប្រពៃ
វាចាក៏ល្អលោកចេះលកលៃ សម្ដីងរំពៃដោយចិត្តដ៏ល្អ ។
-ជាអ្នកនិយាយពាក្យជ្រាលជ្រៅផង សម្ដីហ្មត់ហ្មងដ៏មានលំអ
ពន្យល់សច្ចៈធម៌ពិតបវរ វែកញែកល្អិតល្អតាមពុទ្ធដីកា ។
-មិនដឹកនាំក្នុងហេតុមិនគួរផង នេះល្អកន្លងវិសេសអស្ចារ្យ
ឱ្យវៀរចាកបាបសព្វគ្រប់ប្រការ ចម្រើនបញ្ញាត្រាស់ដឹងធម៌ពិត ។

ដោយភិក្ខុ **សុវណ្ណជោតោ ភ.ស. វ.**

## ៥-មិត្តល្អបំណងឱ្យរួចចាកទុក្ខ

-មិត្តល្អមានគុណប្រសើរពេកពិត ល្អទាំងគំនិតល្អទាំងវាចា
ល្អទាំងមារយាទគុណធម៌ថ្លៃថ្លា ចេះមានមេត្តាដល់មិត្តកល្យាណ ។
-មិត្តល្អតែងជួយសង្គ្រោះដល់គ្នា ជួយគ្រប់វេលាដែលអាចធ្វើបាន
ជួយប្រាប់ផ្លូវត្រូវប្រាប់ធម៌កល្យាណ ជួយមិត្តឱ្យបានប្រព្រឹត្តធម៌អាថិ ។
-មិត្តល្អគឺមិត្តចេះអនុគ្រោះ សម្ដីពីរោះពិតមិនមុសា
ល្អក្នុងល្អក្រៅល្អសព្វកិច្ចការ ល្អដោយសីលាល្អឥតមានហ្មង ។
-សីលប្រាំ ប្រាំបី មានគុណអស្ចារ្យ មិត្តមានបញ្ញាសែនល្អកន្លង
រក្សាខ្លួនឯងដឹកនាំមិត្តផង ព្រោះមានបំណងឱ្យរួចចាកទុក្ខ ។

ដោយសារិកា **នូ ចរិយា**

## ៦_មិត្តធម៌

-ពេលថ្ងៃនិងយប់ជាគូនឹងគ្នា សត្វគ្រប់អង្គារស់ក្នុងលោកា
កើតមកជាមនុស្សសែនល្អថ្លៃថ្លា គួរតែរក្សាអាត្មាឱ្យបាន ។
-បើសេពគប់មិត្តគួរគប់បណ្ឌិត នឹងបានល្អពិតប្រសើរថ្កើងថ្កាន
ទៅជាសប្បុរសរូបអ្នកនឹងបាន សិរីសួគ៌ឋានសុខយូរអង្វែង ។
-តែប្រសិនបើគប់អសប្បុរស មានចិត្តមិនស្មោះនាំឱ្យចម្បែង
ប្រព្រឹត្តបាបធម៌គ្មានគិតកោតក្រែង វិនាសជាក់ស្តែងអន្តរាយគុណធម៌ ។
-មិត្តនាំប្រយោជន៍មិនហោចធ្លាក់បុណ្យ នាំចម្រើនគុណបានទាំងក្តីល្អ
បានទាំងសួស្តីបានសុខបវរ ព្រោះមានគុណធម៌សម្បូរដូចគ្នា ។
-មិត្តល្អមានឈ្មោះពីរោះពេកក្រៃ ល្អទាំងសម្តីល្អទាំងឫកពា
ល្អទាំងសីលធម៌ ស្មោះសររកគ្នា មានឈ្មោះមិត្តជាក្នុងន័យមិត្តធម៌ ។

ដោយសាវិកា **នូ ចរិយា**

## ៧_សមុទ្រ ៤ ប្រការ

១-អហំ សុវណ្ណជោតោសមណា សូមលើកយកកាចាររថែងរ៉ាយរ៉ាប់
រៀបរាប់ធម៌អាចិទុកបានជាច្បាប់ ដែលព្រះត្រាស់ប្រាប់អំពីសមុទ្រ ។
២-រីសមុទ្រនេះមានន័យជ្រាលជ្រៅ ធំទូលាយទៅដែលព្រះសម្ពុទ្ធ
ទ្រង់ត្រាស់ប្រៀបធៀបស្តីពីសមុទ្រ ន័យជ្រៅបំផុតក្នុងធម៌វិន័យ ។

៣-គប្បីជ្រាបចុះសមុទ្រនេះណា មាន ៤ ប្រការគួរយើងលកលៃ
សិក្សាឱ្យចេះឱ្យបានយល់ន័យ ខំប្រឹងរំពៃគិតគួរឱ្យជ្រៅ ។
៤-ទី១ នេះគឺ**សមុទ្រសង្សារ** សត្វមានតណ្ហាតែងអន្ទោលទៅ
ធ្លាក់ក្នុងវដ្តៈទុក្ខច្រើនពេលកូវ តែងអន្ទោលទៅគ្មានទីបំផុត ។
៥-ទី២ ក៏គឺ**ជលសាគរ** គឺជាគំនរនៃទឹកសមុទ្រ
ទឹកច្រើនពេកណាស់ផ្ទៃធំបំផុត សំដៅសមុទ្រដែលមានទឹកប្រៃ ។
៦-ទី៣ នេះមិ**ញ្ញនយសាគរ** គឺជាគំនរនៃព្រះធម៌ថ្លៃ
មានន័យជ្រាលជ្រៅមិនងាយឧបមេយ្យ ហួសពីវិស័យយើងគិតពិចារណា ។
៧-ទី៤ ក៏គឺ**ញាណសាគរ** ខ្ទរខ្ទាយទូទ័រម៉ឺនសែនចក្រវាឡ
នេះជាព្រះញាណនៃព្រះសាស្តា ជាព្រះសម្មាសម្ពុទ្ធជិនស្រី ។
៨-សាគរទាំង ៤ ប្រការនេះឯង ដូចបានសម្តែងសង្ខេបយ៉ាងខ្លី
សាគរប្រសើរលើសសាគរបី ញាណព្រះជិនស្រីពិតប្រសើរជាង ។

ដោយភិក្ខុ **សុវណ្ណជោតោ ត.ស.ច.**

## ៨-សមុទ្រ ១៦ ប្រការ

១-សមុទ្រសង្សារសមុទ្រទឹកប្រៃ សមុទ្រធម៌ថ្លៃមានន័យជ្រាលជ្រៅ
សមុទ្រព្រះញាណធំទូលាយទៅ ដឹងចុះណាពៅគ្មានអ្វីរាំងបាន ។
២-សមុទ្រចក្ខុសោតៈឃានៈ ជិវ្ហាកាយៈដែលជាអង្គប្រាណ
រីឯមនោក្នុងធម៌កល្យាណ ក៏ព្រះទ្រង់បានត្រាស់ថាសមុទ្រ ។

៣-រូបសំឡេងក្លិនរសផោដ្ឋព្វៈ ធម្មារម្មណ៍ជាក់ក៏ជាសមុទ្រ
ដែលព្រះលោកនាថប្រសើរបំផុត ត្រាស់ថាសមុទ្រក្នុងធម៌វិន័យ ។
៤-ទឹកភ្នែកនិងឈាមទឹកដោះមាតា មួយៗប្រការច្រើនហួសឧបមេយ្យ
ច្រើនជាងសមុទ្រយើងត្រូវយល់ន័យ គួរឱ្យស្លុតភ័យគួរខ្លាចរអា ។
៥-គួរឱ្យសង្វេគគួរឱ្យនឿយណាយ ជួបហើយឃ្លាតឆ្ងាយនៅក្នុងសង្សារ
ទួញយំសោយសោកច្រើនបែបប្រការ ព្រោះតែតណ្ហានិងអវិជ្ជា ។
៦-គួរខំប្រឹងស្រាយខំប្រឹងលះបង់ ដើរក្នុងផ្លូវត្រង់ គឺមជ្ឈិមា
សិក្សាប្រព្រឹត្តនូវព្រះធម្មា តាមព្រះភគវាពិតរួចចាទុក្ខ ។

ថ្ងៃ១៣រោច ខែផល្គុន ព.ស.២៥៥៥

ដោយភិក្ខុ **សុវណ្ណជោតោ ភ.ស.វ.**

# ៩-វៀរចាកបាបធម៌

-វៀរអំពើបាប ជាគ្រឿងឆ្អេះឆ្អាប កខ្វក់សាមាន្យ
អុកឡុករុកគួន ឆាឆៅរំខាន មិនឱ្យយើងបាន
សុខសាន្តឡើយណា ។
-ជួបទុក្ខលំបាក ក្រីក្រតោកយាក ចុកចាប់ឈឺផ្សា
ទោះចង់បានអ្វី មិនដូចប្រាថ្នា ស្គាល់តែទុក្ខា
ចិន្ដារីងរៃ ។

-ងប់ល្បែងលង់លិច ខាតបង់ជានិច្ច សាបសូន្យកម្រៃ
ជំពាក់លុយគេ គេទាររាល់ថ្ងៃ យសសក្តិអ្វីៗ
វិនាសសាបសូន្យ ។
-គ្រួសារបាក់បែក ជេរឈ្លោះប្រកែក ប្តីប្អូននិងកូន
សុភមង្គល ក្រៀមស្វិតស្រពោន ញាតិមិត្តបងប្អូន
ស្អប់លែងរាប់អាន ។
-ទោះបាបតូចតាច គួរវៀរគួរខ្លាច ប្រឹងគេចឱ្យបាន
បើមិនចង់ជួប ទុក្ខសោកខកប្រាណ សេពធម៌កល្យាណ
វៀរចាកបាបធម៌ ។

ដោយសារិកា **នួន ម៉ុំ**

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅមិត្តល្អ

-ភិក្ខុ **សុវណ្ណជោតោ** ........................................................ ១២៦,០០០៛

-ភិក្ខុ **ឡាយ ចន្ទី** វត្តនិរោធរង្សី ........................................ ១០០,០០០៛

-ភិក្ខុ **អត្តញ្ញាណ ស្រេង សុខា** វត្តនិរោធរង្សី ......................... ៧៥,០០០៛

-ភិក្ខុ **សុមេធបណ្ឌិតោ ស៊ិន ផល្លា** ....................................... ៥០,០០០៛

-ឧ.សិ. **ហ៊្គិច សាយ** និង ឧ.ស. **តាំង សុខ** និងកូនចៅ ......... ៥០០ $

-ឧ.ស. **អ៊ុក ចិត្រា** ឧ.សិ. **វ៉ុន ចិន្តា** និងបុត្រ .............. ២៥០ $ + ៤០,០០០៛

-ឧ.ស. **ជា ពិចិត្រ** ......................................................... ២០០ $

-ឧ.ស. **ហង់ ចំនួនរិទ្ធ** និង ឧ.សិ. **ដួង រ៉ាវី** ព្រមទាំងបុត្រ ... ១០០ $ + ១៦,០០០៛

-ឯកឧត្តមឧកញ៉ា បណ្ឌិត **ទុយ គី** លោកជំទាវ **កង វុទ្ធា** ( ស្រីម៉ៅ) +បុត្រ ១០០ $

-ឧ.សិ. **តាំង អៀវងស៊ុយ** + ស្វាមី ........................................ ១០០ $

-លោក **ង៉ូ លីហុង** + **តាំង យូហ៊ាង** + បុត្រ .......................... ១០០ $

-ឧ.ស. **គួច គួងឡេង** + ឧ.សិ. **តាំង យូគាង** + កូនចៅ ............ ១០០ $

-ឧ.សិ. **លី ស៊ូហ៊្គិច** + បុត្រនិងចៅ ....................................... ១០០ $

-ឧ.ស. **អ៊ីវ វិសាល** ឧ.សិ. **សុង ចន្ថា** + បុត្រនិងចៅ ............ ១០០ $

-ឧ.ស. **ជា សុខុម** ឧ.សិ. **អ៊ុន ពួន** + បុត្រ ............................ ៤០០,០០០៛

-ឧ.សិ. **នៅ សុខឃឿន** + អ្នកម្តាយ ......................................... ៣០០,០០០៛

-ឧ.ស. **ធម្មប៊ុន ស្រ៊ុន** + ឧ.សិ. **យ៉ែម សួស្តី** ............................ ២០០,០០០៛

-ឧ.សិ. **លន ឡុងឌី** និងក្រុមគ្រួសារ ..................................... ២០០,០០០៛

-ឧ.សិ. **នូ ចរិយា** + អ្នកម្តាយ **ឌុល ស៊ីថា** ................................ ១៩០,០០០៛

-លោកគ្រូ **កែវ វិមុត្តិ** ... ៥០ $ -លោក **ហេង ពៅ** និងភរិយា ... ៥០ $

-ឧកញ៉ា **សេង ឆាយអ៊ីវ** និង ឧបាសិកា **កាំង ហ៊្គិចណៃ** + បុត្រ ...... ៥០ $

-ឧ.ស.បណ្ឌិត **ស៊ិន ម៉េងស្រ៊ុន** + ឧ.សិ.**បណ្ឌិត ស៊ីន ជុំបូ** + គ្រួសារ ... ៥០ $

-ឧ.សិ. **ថៃ សុខធីម** ...... ៤០ $ -ឧ.ស. ហាង គិន + កូនចៅ ... ៣០ $

-ឧ.សិ. អ៊ុម យ៉ាន ........ ៣០ $ -ឧ.សិ. ហ៊ីង ស៊ុំ ............. ៣០ $

-ឧ.សិ. **ហុង ចេង** ...... ២៥ $ -ឧ.សិ. វ៉ូ គឹមតេង + កូនចៅ ... ២០ $

-ឧ.សិ. **តាំង ត្រៀន** ព្រមទាំងបងប្អូន និងក្មួយៗ ..................... ១៥០,០០០៛

-ក្រុមវេនថ្ងៃ ៥ កើត ឧ.សិ. **កង យូផា** ពុទ្ធបរិស័ទចាក់អង្រែ .... ១៥០,០០០៛

-ឧ.សិ. **អ៊ឹង មួយគា** + ប្អូន + **ហ៊ា** + កូន + **អ៊ឹង ហ្គិចធីង** ............. ១០៥,០០០៛

-ឧ.សិ. **យឹម សុផល** + បុត្រ ................................................ ១០០,០០០៛

-ឧ.សិ. **មុំ ឡៃ** + បុត្រ ...................................................... ១០០,០០០៛

-ឧ.ស. ភឹង + ឧ.សិ. រ៉ង + ឧ.សិ. ផូ +កូនចៅ ......................... ១០០,០០០៛

-ក្រុមឧបាសក វ៉ង់ តូ + បុត្រ +កម្មការិនីរោងចក្រ នៅភូមិព្រៃព្រីង ១០៥៨០០៛

-លោក ជាម ប៉ុងគុយ លោក លឹម ប៉ស្រ៊ុន និងភរិយា+ បុត្រ ....... ២០ $

-ឧ.ស. ប៉ែន សារឿង + ឧ.សិ. ចេវ សោរិន + បុត្រ ................. ២០ $

-ឧ.ស. តាំង សុងឈីម ឧ.សិ. លី ឡៃហ៊ាង ............................. ២០ $

-ឧ.ស. ទ្រី ឆាវ + ឧ.សិ. សៀក លៀងជាវ ២០ $ -ឧ.សិ. នូ ម៉ាលី ២០ $

-ឧ.សិ. ផាំង ស្រួយ + កូនចៅ ... ២០ $ -ឧ.សិ. គី ង៉ោ + កូនចៅ ២០ $

-ឧ.សិ. ហួស៊ាង អ៊ាក .......... ២០ $ -ឧ.សិ. ងួន គឹមអ៊ីវ ..... ២០ $

-ឧ.សិ. ជិន សាវ៉េត ........... ២០ $ -ឧ.ស. ទន់ កាណែល .... ២០ $

-កញ្ញា ជឹប ស្រីពេជ្រ ......... ១៥ $ -ឧ.សិ តិន អេង + កូនចៅ ១០ $

-ឧ.សិ. នួន មុំ +ប្អូន +ក្មួយ ៥០,០០០៛ -ឧ.សិ. ចេង + កូនចៅ .... ៥០,០០០៛

-ឧ.សិ. គឹម ហ៊ាន + បុត្រ ៥០,០០០៛ -ក្រុមពុទ្ធបរិស័ទវត្តកែវមណីវ័ន ៥៥,០០០៛

-ឧ.សិ. ហែម ណារី + បុត្រ ៥០,០០០៛ -ឧ.សិ. តាំង គឹមណៃ + បុត្រ ៥០,០០០៛

-ឧ.សិ. ហាវ សារុំធ និងអ្នកម្ដាយ .............................................. ៥៦,០០០៛

-ឧ.សិ. សុខ ឆវី ឧ.ស. តេង ប៉េង និងបុត្រ ................................ ៥០,០០០៛

-ឧ.សិ. សួស សាមី + បុត្រ ៥០,០០០៛ -កញ្ញា សៀង សុខសោភា ៥០.០០០៛

-ក្រុមពុទ្ធបរិស័ទវត្តឫស្សីស្រុក ៤៨,០០០៛ -ឧ.សិ. អួន ហេម៉ារ៉ា ... ៤០,០០០៛

-ឧ.សិ. តុង គីមហេង + កូនចៅ ១០ $ -ឧ.សិ. ឌិន ហឿន ........ ១០ $

-ឧ.សិ. លី ឡេងហួយ+កូនចៅ ១០ $ -ឧ.សិ. អ៊ុំ លន់ ........... ១០ $

-ឧ.សិ. ប៊ុល លីន+កូនចៅ ១០ $ -ឧ.សិ. ឌិន យឿន ........ ១០ $

-ឧ.សិ. នួន សុវណ្ណ+បុត្រ ១០ $ -ឧ.សិ. ថេង ហៀង ...... ១០ $

-លោក សុក ហួត + ភរិយា +បុត្រ ១០ $ -ឧ.សិ. ងួន គីមលី ...... ១០ $

-លោក សុក អៀក + ភរិយា +កូន ១០ $ -ឧ.សិ. ផាន់ ណាគា ..... ១០ $

-លោក សុខ ទ្រី +ភរិយា +បុត្រ ១០ $ -ឧ.សិ. លាន សុខទី .... ១០ $

-ឧ.សិ. អ៊ឹង លីហួង + កូនចៅ ១០ $ -លោកស្រី ជុំ ណារ៉ា ..... ១០ $

-ឧ.សិ. លៀង សេង + ស្វាមី + បុត្រ ១០ $ -ឧ.សិ. មាស អួន + កូនចៅ ១០ $

-ឧ.ស. ប៊ុត សម្បត្តិ ឧ.សិ. ប៊ុត ប៊ុនថន ១០ $ -ឧ.សិ. នុត ណានឡា .... ១០ $

-ក្រុមធម្មមិត្ត អ្នកស្រី ទឹម លក្ខណា ៤៤,០០០៛ -ភិក្ខុ ប៉ែន សេដ្ឋា ..... ០៥ $

-ឧ.សិ. ផេង នាង និង កូនចៅ ៤០០០០៛ -ឧ.សិ. លី សុណាត +កូនចៅ ៤០០០០៛

-ឧ.ស. មុំ សាវី +ឧ.សិ. អ៊ុន ពុំ +កូនចៅ ៤០,០០០៛ -ក្រុមវេនថ្ងៃ ៤កើត ៤០,០០០៛

-ឧ.ស លី វាសនា ឧ.សិ អ៊ុង រតនា +បុត្រ ៤០,០០០៛ -ឧ.សិ. លី វណ្ណថន ៥ $

-ឧ.ស ក្រុយ ចេញហាំង +ភរិយា +កូនចៅ ៤០,០០០៛ -ឧ.សិ.ប៉ាង សំបូរ ៥ $

-ឧ.សិ. ជា កែវមុនី +ស្វាមី +បុត្រ ៣០,០០០៛ -ឧ.ស. ម៉ោញ ថន ពៅ ៣០,០០០៛

-គង់ ច័ន្ទតារា +ភរិយា +បុត្រ ៣០,០០០៛ -ឧ.សិ. ឡាច នុំ +កូនចៅ ៣០០០០៛

-ឧ.សិ. ហែម ណយ + បុត្រ ២១,០០០៛ -ឧ.សិ. ហាក់ មុំ ២១,០០០៛

-ឧ.សិ. មាន កែវមុន្នី ៥$ -ឧ.សិ. ស ចន្ទថា ៥$ -ឧ.សិ ចាន់ សុខា +កូនចៅ ៥$
-ឧ.ស. ស្វាយ ឈាត +ឧ.សិ. ឈាវ ចាន់ថន +កូនចៅ ៥$ -ឧ.សិ. ទ្រី ជូ +កូនចៅ ៥$
-ឧ.សិ ហេង សុខឡឹង+ស្វាមី ៥$ -ឧ.សិ. ស៊ុយ ស៊ីណេត ៥$ -សុទ្ធ សាធ + បុត្រ ៥$

**ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ២០,០០០៛**

-ភិក្ខុ វីរ វណ្ណា +ភិក្ខុ ប៉ាត់ វ៉ា -សាមណេរ នៅ ហៃឡុន -ឧ.សិ. ឡេង ញូ + កូនចៅ
-ឧ.ស. ជៀម ហេង + ឧ.សិ សុខ ធនផល្លា +កូនចៅ -ឧ.សិ. យឹម សាវ៉ាត -ហុក ហៀង
-ឧ.សិ. ជា គីមហុង -ឧ.ស. នូ ជីនសេរី+ឧ.សិ. យ៉ូ សាម៉េត +បុត្រ -ផេង យូសេង
-ឧ.ស. ប្រាក់ សំណាង +ឧ.សិ. នៅ អុត +កូនចៅ -ឧ.សិ. ប៊ិន ផូ -ឧ.សិ. ហួរ អ៊ី
-ឧ.ស. ឡុង ផូ +ឧ.សិ ហង្ស ប៊ុន ថុល+កូនចៅ -សុទ្ធ ស្រីមុំ នឹងស្វាមី + បុត្រ ,
-ឧ.ស. ភាវ សារ+ឧ.សិ. ប៉ក់ សុបុណ្យ +កូនចៅ -លោកយាយ ប៉េង លន់ +បុត្រ
-ឧ.ស. ម៉ី សារ៉ន + ឧ.សិ ឡាំង គីមជាង+កូនចៅ -ឧ.សិ. មាស គាត +បុត្រ
-ឧ.សិ. មុំ រឿន -ឧ.សិ. សូត្រ+គិន +បុត្រ -ឧ.ស. ឧត្តនា វត្តី + ឧ.សិ. យឹម សាមាន
-ឧ.សិ. ក្រចេវ ហៅ ឧ.សិ. អ៊ិម នាងនួន -ឧ.សិ. គួច មុយអេង +ស្វាមី +កូនចៅ
-ឧ.សិ. ស វ៉ាន់ណៃ+ស សុធារី +បុត្រ -ឧ.សិ. អាង ទៀង +បុត្រ -ឧ.សិ. ពៅ រុំ
-សួស ភីរ៉ា ចិន្តា + បុត្រ -យី គង់ អាខូច +អាប៊ិច +អាហេង -ឧ.ស. ស្មោញ ប៉ោហៀត
-ឧ.សិ. កែវ ណៃអ៊ីម -ឧ.សិ. កែវ ជានិត +ក្មួយ, -ឧ.សិ. គីង ផេង -ឧ.ស. សួន ផាន
-ឧ.សិ. ហ៊ុង គីម +បុត្រ -ឧ.សិ. អ៊ុច ណារ៉ុ +កូនចៅ -ឃ្លោក ប៉េងឆាង -ឱម វ៉ាន់ឌី
-ឧ.សិ. ជីវ យួង ។ -ឧ.សិ នរោត្តមធានី និងកញ្ញា ជា សុជាតា -ឧ.សិ. ចាន់ សុជាតា
-ឧ.សិ. ឡេង សុធន្នី -ឧ.សិ. តាំង គីមណៃ -ឧ.សិ. ហៃម ណារី -ឧ.សិ. សួស សាមី
-ឧ.សិ. លឹម មួយលី -ឧ.ស. អឹង ស្មោញង៉ៅ -យ៉ាំ ផេង+រស់ នី -ឧ.សិ. យូ ស៊ីម +បុត្រ
-ឧ.សិ. នួន សុវណ្ណា +កូនចៅ -ឧ.សិ. ហុក ឈិន +កូន ចៅ -ឧ.សិ. ឆៃ ម៉ៅ +ប្អូនៗ
-ឧ.សិ. យោក សា -ឧ.សិ. យ៉ាង ផាន +បុត្រ ។ -ឧ.សិ. កក់ ចន្ថា + អ្នកម្តាយ
-ឧ.សិ. ឡាយ បានហួន ១៦,០០០៛ -កៅ សុវណ្ណា ២ ដូល្លា + ៣,០០០៛

**ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ១៥,០០០៛**

-ក្រុមពុទ្ធបរិស័ទបឹងត្របែក ២ -ឧ.ស. គង់ ហ៊ុន+ភរិយា +បុត្រ

-លោក ឯក សុខថង+ភរិយា +កូនចៅ -កញ្ញា នូ សុភាព + នូ សុធារី

-ឧ.សិ. កែវ ជីន +កូនចៅ -ឧ.សិ. សោម ផាន់ -ឧ.ស. ប៉ោក ឡឿង + បុត្រ

-អ៊ុក ងីម + ទៀបសាវីន + បុត្រ -ឧ.ស. សៀក ឡេង + ភរិយា -ឧ.សិ. វិញ ពូន

-ឧ.ស. ពេជ សឿន + បុត្រ ក្រុមរោងចក្រ ១២០០០៛

-នួន សុខណាន ក្រុមបង្អើយការ ១០១០០៛

**ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ១០,០០០៛**

-ភិក្ខុ ហ៊ុត សានី -ភិក្ខុ សោ សម្ផស្ស -សាមណេរ យ៉ាន គឹមសាន -សាមណេរ កែម វ៉ន

-ឧ.សិ. ប៉ាល់ ធីតា+ស្វាមី +កូនចៅ -លោក សិរិតភាព + អ្នកស្រី គឹម សុខឡេង

-ឧ.សិ. រស់ សៀវ និងលោក ចាប សុខហឿន -ឧ.សិ ឡុង ចាន់ថារី + កូនចៅ

-លោក អួម ផេន + ឧ.សិ ថេង មុំ + កូនចៅ -ឧ.សិ ប៉ាក សុភារី + កូនចៅ

-ឧ.សិ. ឡោ ហ៊ុន + កូន -ឧ.សិ ចេប ពេង -ឧ.សិ ហ៊ុយ ណៃ+ស្វាមី + កូនចៅ

-សុខ វណ្ណាថា នឹងសុទ្ធ សាលីស + បុត្រ -លោក នូ វុធារិទ្ធ+សេង សុខមាន

-ឧ.ស. ឆាយ ណារិទ្ធ+ប៉ាន យុឹគឹម + បុត្រ -លោកស្រី អ៊ិត ស្រីល័ក្ខ+ស្វាមី + កូន

-លោក ជា វណ្ណា នឹងអ្នកស្រី គុណ សុខគី -ឧ.សិ. សុខ សុគុំ+ជួន + បុត្រ -វ៉ាន់ មុំ

-ឧ.សិ ជា ប៊ុនហួ + កូនចៅ -ឧ.សិ សំ ញឹម -ឧ.សិ នួវ ថុល -ឧ.សិ. ណាត ស្រីទូច

-ឧ.សិ. ម៉ែន ណេម + បុត្រ -ឧ.ស. តុល យ៉ួន -ឧ.សិ. ស្រីម៉ាច + ស្វាមី -គង់ ប៊ុនឡួត

-ឧ.សិ ងួន វួចអេង + កូនចៅ -លោក ហោ+អ្នកស្រី ហួលី -ឧ.ស. ភឿក ង៉ែត

-ឧ.សិ ឈន ប៉ុច + កូនចៅ -ឧ.សិ តឹម ជូ + កូនចៅ -ឧ.សិ. ណេង -ប៊ុន លីណា

-ឧ.សិ. ហ៊ឹម ចិន្តា+ស្វាមី +បុត្រ -ឧ.សិ. ស៊ុន ជៀម +កូនចៅ -កញ្ញា នូ សុភក្រ្ត

-ឧ.សិ.កា ពួយ វ៉ាន់ស៊ី កូនស្រី រស់ ច័ន្ទកញ្ញា +កូនចៅ -ឧ.សិ សេង ស្រួយ + កូនចៅ

-ឧ.សិ. វ៉ង អឿន + បុត្រ -ឧ.សិ. កួយ សុខហេង+យឿន ស៊ីម -បង ទឹកអំពៅ

-ឧ.សិ. ផាន់ ខុម+ឧ.ស. វង្ស សុវណ្ណា+ផាន់ សុភា -ឧ.សិ. សោម រៀម -ប៊ិន សំអាត
-លោក ស៊ឹម ប៊ុនរឿន+អ្នកស្រី ប៉ូច លឿម +បុត្រ -ឧ.សិ. តេង ឧត្តរា+តេង ចិន្តា
-ឧ.សិ. យូ គីមលាង +បុត្រ -ឧ.សិ. លឹម ណៃអេង +បុត្រ -ឧ.សិ. រ័ត្ន គីមឆុន
-ឧ.សិ. គ្រូភ័ស -ឧ.ស. ផា+ឧ.សិ. លី -ស៊ឹម មន្ថា -ឧ.សិ. ស៊ីវ ស៊ីនួន +កូនចៅ
-ឆាយ គីមឡេង -ឧ.សិ. ម៉ម ណេត -ឧ.ស. ឡៅ ហ៊ុន+ឧ.សិ. មឿង ទួត +កូនចៅ
-ឧ.សិ. ហួ ញ៉េប -តាំង គីមតួយ -ឈីវ វណ្ណារី -ឃួន ស្រេង -ទ្រី ឈូក -ស៊ីវ ហួង
-ឧ.សិ. រស់ វណ្ណា +កូនចៅ -ឧ.សិ. សេង ស៊ីនួន +កូនចៅ -ឧ.សិ. ខៀវ សំ +កូនចៅ
-ឧ.សិ. ឡេនី + បុត្រ -ឧ.សិ. ឌឹម សុខហេង+ឧ.សិ. ហួត ថាវី -ចាន់ គីមវួច +កូនចៅ
-ឧ.សិ. ពេជ្រ ប៊ិនបុប្ផា+ស្វាមី +បុត្រ -លោកស្រី គង់ សុភាព+ស្វាមី -ឧ.សិ. ភួន ផូ
-ឧ.សិ. ប៊ុត ស៊ីម -ឧ.សិ. ចាន់ សុខខេង -ឧ.សិ. កើត ស្រ៊ុន -ឧ.សិ. ស៊ុន សៀកមុំ
-ឧ.សិ. អ៊ិច ស៊ូដា+ស្វាមី +កូនចៅ -ឧ.សិ. មាស រស់ + ប្អូន + ក្មួយ + កូនចៅ
-ឧ.ស. សៅ សាង+ឧ.សិ. អ៊ុត គី -ឧ.សិ. វួច ស្រ៊ុន -តាំង គីមគួយ -ឧ.សិ. សូ ជីន
-ឧ.ស. ង៉ិន ថន+ឧ.សិ ព្រំ សុខលីម -ឧ.សិ. ពៅ ចិន្តា -ឧ.សិ. អ៊ុន លៃវេត -ជា សុភី
-ឧ.សិ. ងួន សុខហ៊ុន -ឧ.សិ. ឡាក់ យ៉េក -ឧ.សិ. ហេង វីរិន្ទ +ក្រុមគ្រួសារ
-លោក សេង សុភា +ភរិយា +បុត្រ -ឧ.សិ. តាំង សាំងយេង -ឧ.សិ. ធិន វឌ្ឍនា
-ឧ.សិ. រុន ចរណៃ -ឧ.សិ. តិប ឡៃ ហ៊ូ -ឧ.ស. ម៉ុន + ឧ.សិ.អាន +កូនចៅ
-កញ្ញា ធិន រតនា +ធិន រដ្ឋា -ឧ.សិ. ផល សៀក +ឧ.សិ. បិន ជួន -ឧ.សិ. ផល សាង
-លោក ស៊ុយ +អ្នកស្រី ភី +បុត្រ -លោក កែវ ចាន់ណាក់ -ឧ.សិ. ព្រំ យ៉ាន់ផល្លី
-ឧ.សិ. ប៉ែន ថៃ + ឧ.ស. ខឹម ភិន -លោក គ្រូ វ៉ា គីម ឈាន និង ឆាយ យៀត
-ឧ.សិ. ឡុង ស្រីមិញ +ស្វាមី -លោក ឡុង រិន +ភរិយា +បុត្រ -ឧ.សិ. មុំ ខិត
-ឧ.សិ. ទេព សាលី + កូនចៅ -លោក គង់ វណ្ណា +ភរិយា -ឧ.សិ. ឈាង លាត
-ឧ.សិ. ជា សារ៉េត -ឧ.សិ. ឌឿ ស្រឿង ឧ.សិ. អ៊ាង ស៊ីមលី + បុត្រ -អ៊ី ភាព

-ឧ.សិ. វីរៈ ម៉ាឡា + បុត្រ -ផាន ផូនី + ភរិយា + បុត្រ -ទូច សាយ + កូនចៅ
-ហាវ ម៉ាស៊ី -ហាវ សុគន្ធ -ឧ.សិ. ទូត ជុនឡេង -ញិប ឆេងអ៊ីន +កូនចៅ
-ឧ.សិ. កង ម៉េង ហ៊ាង + កូន ប្រាក់ សុខអេង -ទៀប អច + ទ្រីណៃហួយ
-ឧ.សិ. កៅ ផល្លី -ឧ.សិ. ចេង គៀង -អ្នកស្រី ជា សុផល -ឧ.សិ. វង អឿន
-ហ៊ុក សុខអ៊ី + ឆឿង គឹមថេត -ឈាង ដវី -ឧ.សិ. ណេន -លោក ខាត់ ផល្លា
-អ្នកស្រី ខាត់ ផល្លី + ស្វាមី -កញ្ញា ខាត់ បញ្ញារី -ឧ.ស. យន់ នៃអៀង + ភរិយា
-លោក ធិន សាលុត + ភរិយា + បុត្រ -លុត ជុំនោ ។

**ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ៨,០០០៛ + ២ដុល្លា**

-ឧ.ស. មាស យិន + ឧ.សិ. ជា សារ៉ន +កូនចៅ -ជា ឡៃហួយ -ឧ.សិ. សួង ខេន
-ឧ.សិ. លឿង សំអុល -ឧ.សិ. ព្រហ្ម សំយី -ឧ.សិ. អ៊ុក សន្តិភាព -ឧ.សិ. សុផារី
-អ្នកនាង ងួន ប៉ូលី -ឧ.សិ. វន វ៉ាន់នី -ឧ.សិ. យឹម ប៊ុន -ហ៊ួត ស្រៀត ហៅ ស៊ីម
-ចេវ ខាន់+លីន ខន +បុត្រ -លោក រី ចាន់ថា -ឧ.សិ. លឹម អេង -ឧ.សិ. ទឹម សារឹម
-ឧ.សិ. រស់ គង់ +កូនចៅ -វ៉ាន់ ចាន់ថា+ស្វាមី +បុត្រ -ឧ.សិ. រស់ សូរិយា +កូនចៅ
-លោកយាយ ជឹង គីមយី -ឧ.សិ. ដួង សារ៉េ +បុត្រ -លោក ងួន ណារិទ្ធ+ស៊ុន សុធារី
-លោក ប៉ែន ពេរ+លោកស្រី ងួន ណារី +កូនចៅ -ឧ.សិ. ឆឹង សាន នឹង ស្វាមី+បុត្រ
-លោក នួន ទេវីភា+អ្នកស្រី ឌឹប ស្រីមុំ +បុត្រ -សួន ប៊ុក -សួន សុផល -បូ រ៉ែន +ធារី
-ឧ.សិ. អ៊ាន គង់+ឧ.សិ. ហេង សីថា +កូនចៅ -ឧ.សិ. ស៊ឹមណែម +កូនចៅ
-ឧ.សិ. សោម សុវណ្ណារ៉េត + ឧ.សិ. ហ៊ុយ ផានី -ឧ.សិ. នៅ សុផល +កូនចៅ
-លោក អ៊ាន ដុល្លា+ភរិយា +ប្អូនៗ -លោក ស៊ុយ សុធា+ម៉ៃ សុគន្ធា -ឧ.សិ. គឹម គី
-ឧ.សិ. កប យ៉ប +កូនចៅ -អ៊ុំ ទួច +កូនចៅ ២ ដូល្លា -នូ មាន+ស្វាមី +កូនចៅ
-ឧ.សិ. គង់ គឹមហួយ +គ្រួសារ -ឧ.សិ. ជាម ចន្ទី បងប្អូន តូន –sok romy 2 $.

### ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ៧,០០០៛

-មែន ធឿន+នាង មុំ +បុត្រ -ឧ.សិ. សយ គឹមហួយ +ជា សុខហេង -ហឿន + រ៉ាត
-លោកតា ពេជ្យ បាក់ +ភរិយា +បុត្រ -ឧ.សិ. យឹម ចាន់ណា -ឧ.សិ. ម៉ម ស្រីម មុំ
-លោក ឆាយ ណារិទ្ធ ឧ.សិ. បារយីគីម +បុត្រ -ឧ.សិ. កង ប៊ិច +កូនចៅ ។
-ឧ.ស. ហាក់ ចាន់គ្រីស្នា ៦០០០៛ -យាយ ម៉ៅ + យាយ មឿន ៦,០០០៛
-ឧ.ស. មៀច មុត+ឧ.សិ. ម៉ក់ សាវ ៦០០០៛ -ឡុង ផាសុគា ៦០០០៛

### ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ៥,០០០៛

-សាមណេរ ពួន សីហា -និស្សិត សូរ ប៊ុនណ្ណារ័ត្ន -ឧ.សិ. សុត លន +តា រ៉េត +បុត្រ
-ឧ.សិ. ម៉ាសិន + កូនចៅ -ឧ.សិ ចាន់ ញ៉ុច -ឧ.សិ វង្ស សារឹម -ឧ.សិ. សំ សុភឿន
-ឧ.សិ. បាន សាគីម +កូនចៅ -ឧ.សិ. អ៊ួន សុធា -ឧ.ស. ម៉ែន ប៉ាល់ ឧ.ស. ពុំ ណាត
-ឧ.សិ. ណៃម លក្ខណ៍ + កូនចៅ -ឧ.សិ. ឈុម ណាំគា + កូនចៅ -កញ្ញា នូ ស្រីឈូក
-ឧ.សិ. ទី ស៊ីនឿន + កូន -ឧ.សិ. អ៊ុច សុភាព -ឧ.ស. លាង ងួន -ឧ.សិ. រេជ សន
-ឧ.ស. ណៃម សុខ +ឧ.សិ. ទួត ណយ -ឧ.ស. ស៊ីន គាហេង+ភរិយា -ឧ.សិ. វង យឿន
-កញ្ញា នូ ម៉ារីយ៉ាត -រ៉ា -ម៉ាប់ -សារ៉ុន -ឧ.ស. សាត+តា ភួង -លោកស្រី ឡុងភូ
-អាហ៊ួយ+ស្វាមី +បុត្រ -លោក ម៉ៅ បូរី+ពន់ មុំ + កូនចៅ -ឧ.សិ. សន សុំអន
-ឧ.សិ. គីម កន្និថា -ឧ.សិ. ឈិល -នាង សឿនសេងហ៊ាន -ឧ.សិ. គួច វ៉ារុណ +បុត្រ
-សេង ហួរហ៊ាន -ឧ.សិ. សើប -ឧ.សិ. សេង ណៃគីម +កូនចៅ -ទិន ថូល +កូនចៅ
-មឿង គីមណៃ -ឧ.សិ. ចាន់ អ៊ីម -អ្នកស្រី ពេជ្រស្រីមុំ +ចៅ -ឧ.សិ. ឡាក់ ញឹម
-ឧ.សិ. ពៅ សាមុត + ឧ.សិ. អាស់ សារឿន +កូនចៅ -ឧ.សិ. សេង ណៃហាង +បុត្រ
-ឧ.សិ. អ៊ាង ពត +កូនចៅ -ចាន់ ប៊ុន្នី -ប៊ី វិន -ហួយ សុខលី -ឧ.សិ. កូ សុផល
-ឧ.សិ. ម៉ី ស៊ីតុន -ឡុង គន់ ស៊ាង ហេង -ឡៃ ឃីម +បុត្រ -បូ សេរី -ឃិន ច័ន្ទរដ្ឋា
-ឧ.សិ. សេង សេត +បុត្រ -ឧ.សិ. អ៊ឹ ថុន -រស់ ស៊ីវុទ្ធី+ភរិយា លាវ រា +បុត្រ
-ឧ.សិ. ភួង គិមហេង +បុត្រ -រស់ ស៊ីវត្ថា+ភរិយា ណារី -លោក គិត សេដ្ឋ +បុត្រ

-ឧ.សិ. ប៊ូច សារឿន +កូនចៅ -ឧ.សិ. គី ប៊ួយ +បុត្រ -តាក ច្រឹប+សេង ប៊ុយ +បុត្រ
-ឧ.សិ. ប៊ូ យ៉ាត+ ប៊ូ សំអាត -ហេ សឿង -គ្រូ ណាត -ព្រំ វណ្ណា -ព្រំ វណ្ណនី
-ឧ.សិ. ឃុន គន +បុត្រ -ហេង អៀន+ស្វាមី -ឈិវ គៀម -ឧ.សិ. ហុង សារ៉េន
-ឧ.សិ. ឈុន ចំណាន +កូនចៅ -អ៊ាង ហុលវណ្ណ -ព្រំ ភារម្យ -ឈើន មិ -ប៊ុត ផៃ
-កញ្ញា ឡា -ឧ.សិ. គង់ ម៉ឺន -ឧ.សិ. ចាន់ ឌី -ឧ.សិ. ហ៊ុយ ស៊ីម -ឧ.សិ. ជួន គង់
-សេង ពៅ -ឧ.សិ. យ៉ាន់ -នាង ហេង -ឧ.សិ. គឹម ថេង -ឧ.សិ. ហេង សុចិន្តា
-ឧ.សិ. ឡុង សារុធ -ឧ.សិ. ជា ទៀង -ឧ.សិ. ឆឹម រិន -ឧ.សិ. វង្ស យ៉ាន
-ឧ.សិ. សេន សារឿន -សល់+ភរិយា -ឧ.សិ. ហេ វៃវ៉ាន+ស្វាមី +បុត្រ -ចាប ផេន
-ឧ.ស. ទឹម ផែង +កូនចៅ -ដុង ស៊ីយឿន +ស្វាមី -ឧ.សិ. ឆាយ គា +បុត្រ
-ផេង សុខឡេង និង មិត្តរួមការងារ -ឧ.សិ. អ្នកស្រី វ៉ាន់ ពិសាល + ស្វាមី+បុត្រ
-ឧ.សិ. យន់ ស្រី -សុខ កឹម ហ៊ន់ -កញ្ញា កឹម រក្សា -គាន ណារី -ម៉ា គីម +កុង កុយ
-ឧ.សិ. មុំ ឆ្វយ +ភរិយា +បុត្រ -ម៉ា ឌេន -ម៉ា មុំ -ឧ.សិ. ចាន់ ណារុន +កូនចៅ
-ឧ.សិ. នូ យុត លោកតា ថេង + យាយ ស៊ុត -ឧ.ស. ម៉ាន ស៊ីម និង ស្ងួន វ៉ាន +បុត្រ
-សួង វុទ្ធី និង ភរិយា +បុត្រ -ណេង ពុំ -ឈាង កុសល +ភរិយា - ឧ.សិ. មុំ អឿន
-លោក ស្រី គឹមស្រី អួន +ស្វាមី +បុត្រ -សោម អៀម ប៉ុង ស្លើង -ឧ.ស. ណប សុខុម
-លោក អ៊ុន សុផល +ភរិយា +បុត្រ -អ៊ឹម សុវណ្ណលីន និង ស្វាមី -លោក សូត្រ សុខច័ន្ទ
-ផុន សំបាន -កញ្ញា ថៃ គន្ធា -លោកស្រី ឈុន ពុទ្ធី +បុត្រ -ឧ.សិ. គឹម អឿន +កូនចៅ
-ឧ.សិ. ឆាយ ស៊ុន ហេង -ឧ.សិ. ឈុន រុង -លោក រ៉ាយ សាក់ នឹង អ្នកស្រី សុខលី
-ឧ.សិ. យុល ឌឿន -ឧ.សិ. ប៉ក់ ណយ និងឧ.សិ. ហំ ភិន -គ្រូពេទ្យ លឹម គឹមសាន្ត
-លោក ឡែន សំអួន នឹង ភរិយា +បុត្រ -យាយ ជួន +បុត្រ -អ្នកស្រី ពៅ សុវិសាល
-ឧ.សិ. សោម ង៉ង +កូនចៅ -ឧ.សិ. ហ៊ឹម ផេង +កូនចៅ -កុង សាន់ +ម៉ា មួយ +បុត្រ
-យាយ រុំ +កូនចៅ -លោក រុំ ធី +ថូយ ពៅ +បុត្រ -លោក ប៊ុន ធឿន +ភរិយា

-ឧ.សិ. ហោ កុសុន -ឧ.សិ. យូ ឡាង -ឧ.សិ. លាង ចាន់ថន -លោក ស្រី វ៉ា ស៊ីយេត

-ឧ.សិ. ជុំ តាងអ៊ុម +ស្វាមី +បុត្រ -ឧ.សិ. សុខ យីន +បុត្រ -ឧ.សិ. ម៉ែន នឹម ហៅ ប៉ុច

-អ្នកស្រី វ៉ាន់ ពិសី +ស្វាមី +បុត្រ -អ្នកស្រី ហ៊ុន ចន្ទី +ស្វាមី+បុត្រ -ឧ.សិ. សុទ្ធ លឹម

-យុវសិស្ស សូរ ប៊ុនណ្ណារាជ្យ -ឧ.សិ. ចេះ សេង លី +បុត្រ -អ្នកស្រី កាន សុគន្ធា

-លោក សូ សារ៉ាត់ + ឈាង គឹមលាង +បុត្រ -ឧ.សិ. កែវ ជឿន +បុត្រ -ថូ ចាន់ណា

-ឧ.សិ. ឈិន ស្រីម៉ៅ -ឧ.សិ. ជួន គង់ + កូនចៅ -ឧ.សិ. អែម អេម + ប្អូន១

-សេង គីម -គឹម យឿន -ឧ.សិ. យូ លន់ + ចៅ -ខន សុខឃួន -ឧ.សិ. អែម លិន

-លោក ង៉ាប វុត្ថា អ្នកស្រី ជួប សារុំ -ឧ.ស. កាក់ សាយ ឧ.សិ. ទីវ សាបេត

-ឧ.សិ. ជីវ សុខថាន + អ្នកម្តាយ -ឧ.ស. ទង អាង ឧ.សិ. ឡេាសារ៉ាត + បុត្រ

-ឧ.ស. កុង ច្រឹង ឧ.សិ. ម៉ារឿន -លោក ស៊ុយ អូន -ស្រួង នារិន -ឧ.សិ. សួន គីន

-ចេង ឆុន + ប៉ោក សុគា -ឧ.សិ. អ៊ាង គង់ -ឧ.សិ. ឈីវ គៀម + បុត្រ

-លោក អំ រ៉ុង + ភរិយា -ឧ.សិ.អ៊ុំវ ស្រួយ -ឧ.សិ. ជ ស្រឿន + សំ ភារិន

-ទឹម បុត្ថា -ទឹម អង្វារ -ឧ.សិ. កេះ ថុន -ឧ.សិ. អ៊ាន មេត -ស៊ឹម ឡា

-ឧ.ស. គៀម ឃាន -លោកគ្រូ ទិវ ម៉ាន់ ឧ.សិ. ឯម ចន្ថា -លោកតា ជា វែម ។

ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ១ ដុល្លា មានចំនួន ១១ នាក់

ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ៤,០០០៛ មានចំនួន ៨ នាក់

ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ៣,០០០៛ មានចំនួន ២២ នាក់

ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ២,០០០៛ មានចំនួន ២២ នាក់

ពុទ្ធបរិស័ទចូលបោះពុម្ពម្នាក់ៗ ចំនួន ១,០០០៛ មានចំនួន ០២ នាក់ ។

**សូមអនុមោទនាធម្មទានរបស់ពុទ្ធបរិស័ទទាំងឡាយ !!!**

**ធម្មទានឈ្មោះអស់ទានទាំងពួង ។**